# ប្រវត្តិសាស្ត្រ
# នៃ
# ប្រទេសកម្ពុជា

## ថ្នាក់ទី ៩,៨,៧



ដោយ

**ផា-អ៊ុម**
អធិការបឋមសិក្សា
ចូលនិវត្តន៍

**ផៃ-ផេង**
អធិការបឋមសិក្សា
ក្រុងភ្នំពេញ

អ្នកស្រី **សោម-អុិម**
គ្រូបង្រៀន

CA 35

ជា-អ៊ួម
អធិការបឋមសិក្សាចូលនិវត្តន៍

ឆ៉ៃ-ឆេង
អធិការបឋមសិក្សាក្រុងភ្នំពេញ

អ្នកស្រី សោម-អ៊ិម
គ្រូបង្រៀន

# ប្រវត្តិសាស្ត្រ
# នៃ
# ប្រទេសកម្ពុជា

សម្រាប់

## ថ្នាក់ទី ៩, ទី ៨ និង ទី ៧

បោះពុម្ពលើកទី២

– រក្សាសិទ្ធិ –

១៩៧៣

ព្រះរាជាណាចក្រកម្ពុជា

---

លេខ [illegible]

គណៈរដ្ឋមន្ត្រី

---

ប្រកាសក្រសួង

---

រដ្ឋលេខាធិការ ក្រសួងអប់រំជាតិ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រ ។
- បានឃើញ ព្រះរាជក្រឹត្យ លេខ [illegible] ចុះថ្ងៃទី [illegible] ខែ [illegible] គ.ស. [illegible] [illegible] ។
- បានឃើញ ព្រះរាជក្រម លេខ [illegible] ចុះថ្ងៃទី [illegible] ខែ [illegible] គ.ស. [illegible] [illegible] ។
- បានឃើញ [illegible] ចុះថ្ងៃទី ៦ ខែ [illegible] គ.ស. [illegible] [illegible] ។
- បានឃើញ [illegible] ។

សំរេច [illegible] :

ប្រការ ១.- [illegible] ។

ប្រការ ២.- [illegible] ។

ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] គ.ស. [illegible]

រដ្ឋលេខា : [illegible]

[illegible] :

[illegible]

រដ្ឋលេខា : [illegible]

ចំលង :

- [illegible]
- [illegible]
- [illegible]
- [illegible]

[illegible] :

[illegible]

[illegible]

# អារម្ភកថា

សៀវភៅ ‹‹ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា››នេះ យើងខ្ញុំបានរៀបរៀងឡើង ដើម្បីបំពេញសេចក្ដីត្រូវការនៃលោកគ្រូ-អ្នកគ្រូ ដែលបង្រៀននៅថ្នាក់ទី៩ ទី៨ និង ទី៧ ក្នុងសាលាបឋមសិក្សាសព្វថ្ងៃហើយមានការលំបាកនឹងរកសៀវភៅច្បាស់លាស់ យកមកបង្រៀនឲ្យបានប្រសិទ្ធិភាព ។

ក្នុងការរៀបរៀងសៀវភៅនេះ យើងខ្ញុំបានស្រាវជ្រាវឯកសារសំខាន់ៗ ដូចតទៅ:

«ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា រៀបរៀងដោយកញ្ញា Giteau ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា រៀបរៀងដោយលោក A. Dauphin Meunier ព្រះបាទជ័យវរ្ម័នទី ៧ ដោយលោក Georges Cœdés ។ល។»

មេរៀននីមួយៗ មានចែកជាបីវគ្គ ។

វគ្គទី ១ គឺសេចក្ដីអធិប្បាយ នៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ។ ក្នុងទំព័រនេះ យើងខ្ញុំបានដកចេញនូវចំណុចបន្ទាប់បន្សំ ហើយបានចំរាញ់ទុកតែចំណុចសំខាន់ៗ សម្រាប់ឲ្យសិស្សយើងងាយយល់ ងាយចាំ ។

វគ្គទី ២ គឺសេចក្ដីសង្ខេប ដែលជាខ្លឹមសារនៃមេរៀន ។ សេចក្ដីសង្ខេបនេះ យើងខ្ញុំបានខិតខំរៀបរៀងឲ្យបានខ្លី ហើយធ្វើយ៉ាងណាឲ្យសិស្សអានទៅឆាប់យល់ ឆាប់ចាំ ។

វគ្គទី ៣ នៅពីក្រោមសេចក្ដីសង្ខេប សម្រាប់ចុះសំណួរពីចំណុចសំខាន់ៗ នៃមេរៀន ។ សំណួរទាំងនេះ បានណែនាំសិស្សឲ្យពិចារណានូវមូលហេតុនីមួយ ៗ ហើយឲ្យចេះទាញសេចក្ដីសន្និដ្ឋានរបស់ខ្លួនយកមកចងជាគតិ ក្នុងន័យស្រលាញ់ និងគោរពជាតិ- សាសនា ។

ក្រៅអំពីនេះ យើងខ្ញុំបានជ្រើសរើសរករូបភាព យកមកបញ្ចូលក្នុងទំព័រនីមួយៗ ដើម្បីឲ្យសិស្សធ្វើការសង្កេត ការពិចារណា និងជាប់ចិត្តទៅលើព្រឹត្តិការណ៍ខ្លះក្នុងមេរៀន ។

ចំណែកពាក្យពេចន៍ទាំងឡាយ ដែលយកមកប្រើក្នុងប្រយោគ យើងខ្ញុំជៀសវាងពាក្យពិបាក ហើយប្រឹងរិះរកតែពាក្យណាដែលសិស្សថ្នាក់ទី ៧ ទី ៨ ទី ៩ ងាយយល់យកមកឲ្យប្រើប្រាស់ ។

ឯពាក្យពិបាកខ្លះ ដែលយើងខ្ញុំបានគំកល់ទុក សុទ្ធសឹងជាពាក្យមានលក្ខណៈជាការចាំបាច់ក្នុងសៀវភៅប្រវត្តិសាស្ត្រ ។

សរុបសេចក្ដីទៅគឺ សៀវភៅ «ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា» មានគោលបំណងតែពីរយ៉ាងគឺ:

១– ទាក់ទាញសិស្សានុសិស្ស ឲ្យស្គាល់ព្រឹត្តិការណ៍រុងរឿងរបស់ប្រទេសរបស់ខ្លួន ។
២– បំផុសចិត្តស្នេហាជាតិឲ្យកាន់តែរីកខ្លាំងឡើង ។

មុននឹងបញ្ចប់ យើងខ្ញុំសូមសំដែងនូវអំណរគុណ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះគណៈកម្មការជាតិផ្នែករងទី ២ ដែលបានពិនិត្យសៀវភៅនេះយ៉ាងល្អិតល្អន់ ហើយបានផ្ដល់គោលការណ៍សំខាន់ៗ ដល់យើងខ្ញុំក្នុងការរៀបរៀងសៀវភៅនេះឲ្យមានលក្ខណៈបរិបូណ៌ជាសៀវភៅសិក្សា ។

**អ្នកនិពន្ធ**

# ជំពូកទី១-សម័យបុរេប្រវត្តិ

## ១- សម័យបុរេប្រវត្តិ

«ជីវភាពនៅកម្ពុជាក្នុងសម័យនោះ»

**សម័យបុរេប្រវត្តិ–** *សម័យដ៏យូរលង់ណាស់មកហើយ ដែលប្រវត្តិសាស្ត្រពុំអាចកត់ត្រាបាន ហៅថា សម័យបុរេប្រវត្តិ ។ គេអាចសន្និដ្ឋានបានថា ក្នុងសម័យនោះ មនុស្សមានការរស់នៅយ៉ាងណា ឬ យ៉ាងណាអាស្រ័យដោយសំអាងទៅលើកំណាយ និងដំណែលដែលរកឃើញសព្វថ្ងៃនៅស្ថានីយបុរេប្រវត្តិសំរោងសែន ( ក្នុងខេត្តកំពង់ឆ្នាំង ) អន្លង់ផ្ដៅ ( ខាងអាគ្នេយ៍នៃសំរោងសែន ប្រមាណ ៣០ គ.ម.) ម្លូព្រៃ (ក្នុងខេត្តព្រះវិហារ ) ។*

*សម័យបុរេប្រវត្តិនៃកម្ពុជាយើង ដែលបានចាប់ផ្ដើមឡើងក្នុងយុគថ្មរលីង មកទល់នឹងសតវត្សទី ១ នៃគ្រិស្តសករាជ មានថេរកាលប្រហែលម្ភៃប្រាំសតវត្ស ។*

**ជីវភាពនៅកម្ពុជាក្នុងសម័យបុរេប្រវត្តិ–**

**បណ្ដាជន :–** *ជនជាតិដែលតមកដល់សព្វថ្ងៃ ហៅខ្មែរយើងនេះជាជនជាតិ ដែលបានមកតាំងនៅស្រុកយើងមុនគេបង្អស់ ។ ឯជនជាតិយួន ថៃ និងភូមា ទើបនឹងមកតាំងនៅឧបទ្វីបឥណ្ឌូចិននេះក្នុងរវាង*

សតវត្សទី១៣ ទេ  គឺមកនៅក្រោយខ្មែរយើងច្រើនសហស្សវត្សណាស់ៗ

ជនជាតិខ្មែរសម័យនោះមានមាឌមាំ មុខជ្រុង ឆ្អឹងចិញ្ចើមខ្ពស់ ៗ

**ជីវភាព:**— ជនជាតិខ្មែរជំនាន់នោះ ធ្វើគ្រឿងឧបករណ៍ផ្សេងៗ ពីថ្ម ឆ្អឹង ដីឥដ្ឋ លង្ហិន ដែក ៗ គេយកថ្មធ្វើជាពូថៅ ញញួរ ពន្លាក ប្រដាប់រូស ៗ គេយកឆ្អឹងធ្វើផ្លែព្រួញ ផ្លែច្បូក ផ្លែសន្ទូច



ជើងពានធ្វើអំពីដីដុត រកឃើញនៅសំរោងសែន (ទស្សនាវដ្ដីខេមរយានកម្ម)

ផ្លែកណ្ដៀវ ៗ គេយកដីឥដ្ឋធ្វើក្អមឆ្នាំង ប្រកបដោយក្បូរក្បាច់យ៉ាងល្អ ៗ ចំណែកវត្ថុធ្វើពីលង្ហិននិងដែកពុំសូវសម្បូណ៌ទេ ៗ គេធ្វើកីត្បាញសម្រាប់ត្បាញសំពត់អំបោះ ៗ ចំណែកលំនៅវិញ គេសង់ផ្ទះពីឈើខ្ពស់ពីដី ៗ ដើម្បីចិញ្ចឹមជីវិត គេដាំស្រូវនៅក្បែរផ្ទះ គេចិញ្ចឹមសត្វដូចជា ជ្រូក គោ ក្របី គេធ្វើការប្រមាញ់ និងការនេសាទត្រី ៗ

អ្នកស្រុកជឿខ្មោច អ្នកតា ៗ កាលណាមានមនុស្សស្លាប់ គេយកសាកសពទៅកប់ ៗ

**ការទាក់ទងនឹងបរទេស** : — មកក្នុងកំលុងសតវត្សទី ១ នៃគ្រិស្តសករាជ ខ្មែរយើងបានទទួលឥទ្ធិពលឥណ្ឌា យ៉ាងខ្លាំង ដោយធ្លាប់មានការទាក់ទងនឹងឥណ្ឌានេះជាយូរអង្វែងណាស់មកហើយ ៗ ភាគ




ផែនទី អឺរុប អាស៊ី

*ច្រើននៃជនជាតិឥណ្ឌាទាំងនោះ បានចាកចេញពីប្រទេសខ្លួនមកកាន់បរទេស ច្រើនមានគោលបំណងខាងសេដ្ឋកិច្ច ។ ក្រោយពីបានចេញរកមាសនៅអាស៊ីភាគកណ្ដាលនិងអឺរ៉ុបភាគខាងត្បូងមក ជនទាំងនោះក៏បានចូលមកជ្រោយឥណ្ឌូចិន ដោយបាននាំទាំងអារ្យធម៌ខ្លួនមកផង ។ គឺនៅពេលនោះហើយ ដែលប្រទេសខ្មែរបានចាប់ផ្ដើមចូលក្នុងប្រវត្តិកាល ។*

—oOo—

**សេចក្ដីសង្ខេប** : — សម័យបុរេប្រវត្តិ គឺសម័យដ៏យូរលង់ណាស់មកហើយ ដែលប្រវត្តិសាស្ត្រពុំអាចកត់ត្រាបាន ។

សម័យបុរេប្រវត្តិនៃកម្ពុជាយើង បានចាប់ផ្ដើមតាំងពីយុគថ្មរលីង មកទល់នឹងសតវត្សទី ១ នៃគ្រិស្តសករាជ ។

ក្នុងចំណោមជនជាតិទាំងឡាយដែលនៅជ្រោយឥណ្ឌូចិនសព្វថ្ងៃ ជនជាតិខ្មែរជាជនជាតិដែលបានតាំងស្ថិតនៅមុនគេបង្អស់ ។ ក្នុងសម័យនោះខ្មែរយើងបានចេះធ្វើឧបករណ៍ផ្សេងៗ ដោយថ្ម ឆ្អឹង ដីឥដ្ឋ លោហធាតុ សង់ផ្ទះពីឈើ ត្បាញសំពត់ ដាំស្រូវ ចិញ្ចឹមជ្រូក គោ ក្របី ធ្វើការប្រមាញ់ និងនេសាទ ។

អ្នកស្រុកជឿខ្មោច អ្នកតា ។ កាលណាមានមនុស្សស្លាប់ គេកប់សាកសពក្នុងដី ។ តាំងពីសម័យដ៏យូរលង់នោះ ខ្មែរយើងក៏ធ្លាប់មានការទាក់ទងនឹងជនជាតិឥណ្ឌាដែរ ។

**សំណួរ** : — យ៉ាងម្ដេចហៅសម័យបុរេប្រវត្តិ? សម័យបុរេប្រវត្តិនៃកម្ពុជាយើង មានថេរវេលាពីកាលណាដល់កាលណា? នៅឥណ្ឌូចិន ជនជាតិណានៅមុនគេបង្អស់? មនុស្សសម័យនោះយកអ្វីធ្វើគ្រឿងឧបករណ៍? ចូរនិយាយពីជីវភាពនៃជនទាំងនោះ។ គេជឿអ្វី? ក្នុងសម័យនោះ ខ្មែរយើងមានការទាក់ទងនឹងជនបរទេសទេ?

# ជំពូកទី២-សម័យមុនអង្គរ

## ២– នគរហ្វូណន

### «ព្រះបាទកៅណ្ឌញ្ញទី ១ និងព្រះរាជាសោយរាជ្យក្រោយព្រះអង្គ»

**ព្រះរាជាណាចក្រ** – *នៅខាងដើមប្រវត្តិកាល កម្ពុជាយើងខ្លះហៅគោកធ្លក ខ្លះហៅនគរភ្នំ តាមចិនហៅហ្វូណន ។ ប្រទេសហ្វូណនស្ថិតនៅត្រង់ភាគខាងត្បូងនៃជ្រោយឥណ្ឌូចិន ។ ដោយហ្វូណនមានព្រំដែន*




ផែនទីអាស៊ីភាគអគ្នេយ៍នៅសម័យហ្វូណន

វែងជាប់នឹងសមុទ្រ ប្រទេសនេះមានសកម្មភាពផ្សេងៗ ច្រើនជាមួយនឹងប្រទេសជិតឆ្ងាយ មានប្រទេសចំប៉ា ជ្វា ចិន និងឥណ្ឌាជាដើម ។

ហ៊្វូណន ជារាជាណាចក្រ គ្រប់គ្រងដោយព្រះរាជនីមួយអង្គព្រះនាម ខ្លះហៅនាងនាគ ខ្លះហៅសោមា តាមចិនហៅ លៀវ-យី ។

**ព្រឹត្តិកាលនៃព្រះបាទហ៊ុន - តៀន ឬ កោណ្ឌញ្ញ ទី ១ -** នៅសម័យនោះ គឺក្នុងសតវត្សទី ១ មានជនជាតិឥណ្ឌាច្រើន បានចាកចេញពីប្រទេសខ្លួន ហើយឆ្ពោះមកកាន់ផ្នែកអគ្នេយ៍ នៃទ្វីបអាស៊ី ។ ក្នុងចំណោមជនឥណ្ឌាទាំងនោះ មានព្រាហ្មណ៍មួយរូបឈ្មោះ កោណ្ឌញ្ញ ដែលតាមរឿងព្រេងខ្មែរហៅព្រះថោង ហើយតាមភាសាចិនហៅហ៊ុន-តៀន បានមកកាន់ព្រះរាជាណាចក្រ ហ៊្វូណន ហើយបានឡើងគ្រងរាជ្យបន្ទាប់ពីបានយកព្រះរាជនី លៀវ-យី ធ្វើជាមហេសី ។

ព្រះបាទហ៊ុន-តៀន ឬ កោណ្ឌញ្ញទី ១ ព្រះអង្គឡើងគ្រងរាជ្យរវាងពាក់កណ្ដាលនៃសតវត្សទី១ ។ ព្រះរាជធានីឈ្មោះ វ្យាធបុរៈ(ជិតបាភ្នំ) ។

**ឥណ្ឌានីយកម្ម**:- ក្រៅពីបង្រៀនឲ្យស្រីៗ ចេះស្លៀកសំពត់ ព្រះបាទកោណ្ឌញ្ញទី ១ ព្រះអង្គបានរៀបចំទំនៀមប្រពៃណី ព្រះរាជាណាចក្រហ៊្វូណនឲ្យប្រព្រឹត្តទៅតាមហិណ្ឌូនិយម គឺបាននាំមកនូវអារ្យធម៌ឥណ្ឌា ។

**ព្រះរាជាដែលសោយរាជ្យក្រោយព្រះបាទកោណ្ឌញ្ញទី ១ –**

**ព្រះបាទហ៊ុន ផាន់ ហ្វាន់** ( HOUEN PHAN HOUANG ) : – ព្រះ

អង្គជាព្រះរាជបុត្រព្រះបាទ ហ៊ុន-តៀន ។ ព្រះអង្គបានពង្រីកអំណាចព្រះអង្គដោយវាយពង្រាបស្តេចសមន្តរាជទាំងឡាយ ហើយព្រះអង្គប្រគល់ឲ្យព្រះរាជបុត្រ និងព្រះរាជនត្តាព្រះអង្គឲ្យគ្រប់គ្រងនគរទាំងឡាយ ។ ព្រះអង្គសុគតនៅខាងដើមសតវត្សទី ៣ ក្នុងព្រះជន្មាយុ ៩០ ព្រះវស្សា ។

**ព្រះបាទ ផាន់ ផាន់** ( PHAN PHAN ) :— ព្រះអង្គជាព្រះរាជបុត្រព្រះបាទហ៊ុន ផាន់ ហ្វាន់ ។ ជាប់ព្រះទ័យតែក្នុងរឿងសាសនាព្រះសិវៈ ព្រះអង្គប្រគល់ការគ្រប់គ្រងរដ្ឋទៅឧត្តមសេនីយម្នាក់ឈ្មោះហ្វាន់សឺម៉ាន់។

**ព្រះបាទ ហ្វាន់ សឺ ម៉ាន់** ( FAN - CHE - MAN ) ឬ **ស្រីមារ** :— បន្ទាប់ពីព្រះបាទផាន់ ផាន់ ឧត្តមសេនីយ ហ្វាន់ សឺ ម៉ាន់ ឡើងគ្រងរាជ្យ ។ ព្រះអង្គទ្រង់បានពង្រីកព្រំដែនហ៊្វូណនបានធំមួយជាពីរ ។ ព្រះអង្គទ្រង់សុគតក្នុងចន្លោះ គ.ស. ២០៤ ទៅ ២១០ ។

**ព្រះបាទ ហ្វាន់ ចាន់** (FAN-CHAN):— ព្រះអង្គត្រូវជាព្រះភាគិនេយ្យព្រះបាទហ្វាន់ សឺ ម៉ាន់ ។ ព្រះអង្គដណ្តើមយករាជ្យបាន ដោយបានធ្វើគតព្រះរាជបុត្រច្បងព្រះបាទហ្វាន់ សឺ ម៉ាន់។ សោយរាជ្យបាន២០ ឆ្នាំ ព្រះអង្គត្រូវព្រះរាជបុត្រព្រះបាទហ្វាន់ សឺ ម៉ាន់ មួយអង្គទៀតធ្វើគត ។

**ព្រះបាទ ស៊ី យុន** ( SIUN ) ឬ **អស្សចេយ្យ** :— ដោយយកការសងសឹកធ្វើជាលេស ឧត្តមសេនីយម្នាក់ឈ្មោះអស្សចេយ្យ „ហៅតាមចិនថា ស៊ី យុន„ បានធ្វើគតព្រះរាជបុត្រព្រះបាទហ្វាន់ សឺ ម៉ាន់ ទៅទៀត

*ហើយឡើងគ្រងរាជ្យព្រះអង្គឯង ។ ព្រះអង្គជាមបាក្យត្រស្នេហាសន្តិភាព ។ ក្នុងរជ្ជកាលព្រះអង្គ ប្រទេសហ្វូណនមានការទាក់ទងជាមួយចិននិងឥណ្ឌា ព្រមទាំងបានចងមេត្រីភាពជិតស្និទ្ធនឹងប្រទេសចំប៉ាផង ។*

—oOo—

**សេចក្ដីសង្ខេប:**– កាលពីដើម ប្រទេសយើងឈ្មោះហ្វូណន ។ ហ្វូណនស្ថិតនៅខាងត្បូងនៃជ្រោយឥណ្ឌូចិន ។ ប្រទេសនេះមានការទាក់ទងច្រើនជាមួយនឹងប្រទេសចំប៉ា ជ្វា ចិន ឥណ្ឌា ។ ហ្វូណនជារាជាណាចក្រគ្រប់គ្រងដោយព្រះរាជនីមួយព្រះអង្គព្រះនាម លៀវ-យី ។

នៅវាងពាក់កណ្ដាលសតវត្សទី ១ មានជនជាតិឥណ្ឌាម្នាក់ឈ្មោះ កោណ្ឌញ្ញ តាមចិនហៅ ហ៊ុន-តៀន បានមកសោយរាជ្យនៅហ្វូណន ព្រមទាំងបានយកព្រះនាងលៀវ-យី ធ្វើជាមហេសីផង ។ ព្រះរាជធានីហ្វូណនឈ្មោះ វ្យាធបុរៈ (នៅជិតបាភ្នំ) ។

ព្រះបាទ ហ៊ុន-តៀន ឬកោណ្ឌញ្ញទី ១ ព្រះអង្គបានរៀបចំទំនៀមប្រពៃណីព្រះរាជាណាចក្រហ្វូណនឲ្យប្រព្រឹត្តទៅតាមហិណ្ឌូនិយម ។

ព្រះរាជាដែលសោយរាជ្យបន្តបន្ទាប់គ្នា ក្រោយព្រះបាទកោណ្ឌញ្ញ គឺព្រះបាទហ៊ុនផាន់ ហ្វាន់ ព្រះបាទ ផាន់ ផាន់ ព្រះបាទហ្វាន់សឺ ម៉ាន់ (ស្រីមារៈ) ព្រះបាទ ហ្វាន់ចាន់ ព្រះបាទស៊ុយុន (អស្សចេយ្យ) ។

**សំណួរ:**– កាលពីដើមកម្ពុជាយើងឈ្មោះអ្វី? ប្រទេសហ្វូណននៅឯណា? មានការទាក់ទងនឹងប្រទេសណាខ្លះ? ព្រះនាងលៀវ-យីជាអ្វី ? នៅសតវត្សទីប៉ុន្មាន ព្រះបាទហ៊ុន-តៀន បានឡើងគ្រងរាជ្យនៅហ្វូណន? ឥណ្ឌានីយកម្ម មានន័យថាម្ដេច? ព្រះរាជាណាខ្លះដែលសោយរាជ្យក្រោយព្រះបាទហ៊ុន-តៀន ?

* *

# ៣- ព្រះបាទកោណ្ឌញ្ញទី២

## «អារ្យធម៌នៅសម័យហ្វូណន»

**ព្រឹត្តិកាលនៃព្រះបាទកោណ្ឌញ្ញទី២ :–** ក្នុងសតវត្សទី ៤ មានព្រឹត្តិការណ៍ខ្លះពុំបានកត់ត្រា ខ្លះក៏សាំញ៉ាំពេក ។ ឯព្រឹត្តិកាលនៃព្រះបាទកោណ្ឌញ្ញទី ២ កើតឡើងនៅចុងសតវត្សទី ៤ ។ តាមរឿងនិទានថា : មានព្រាហ្មណ៍ម្នាក់ឈ្មោះកោណ្ឌញ្ញ បានឮសម្លេងអាទិទេព ប្រាប់ឲ្យមកសោយរាជ្យនៅប្រទេសហ្វូណន ។ គ្រាន់តែព្រាហ្មណ៍នោះមកដល់ អ្នកស្រុកនាំគ្នាទៅទទួល ហើយលើកជាស្ដេច ដែលទ្រង់ព្រះនាមថា ព្រះបាទកោណ្ឌញ្ញទី ២ ។

ដោយព្រះអង្គគោរពព្រះសិវៈ លទ្ធិសិវៈក៏បានលូតលាស់យ៉ាងខ្លាំង តែព្រះពុទ្ធសាសនាមហាយាន ក៏ចេះតែមានល្បឿនដែរ ។

**ព្រះរាជាដែលសោយរាជ្យក្រោយព្រះបាទកោណ្ឌញ្ញទី ២ :–** ក្នុងចំណោមមហាក្សត្រដែលសោយរាជ្យក្រោយព្រះអង្គ ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន (៤៨០-៥១៤) ជាព្រះមហាក្សត្រមានវិជ្ជានុភាពជាងគេ ។ ព្រះអង្គបានបន្តការចងស្ពានមេត្រីជាមួយនឹងប្រទេសចិន ។

បន្ទាប់ពីរជ្ជកាលព្រះបាទកោណ្ឌញ្ញជ័យវរ្ម័នមក មានការដណ្ដើមរាជសម្បត្តិ ។ គឺដំណើរបែកបាក់គ្នានេះហើយ ដែលជាឱកាសឲ្យប្រទេសចេនឡា ដែលជាប្រទេសចំណុះ ហ៊ានក្រោកឡើងតទល់នឹង

ប្រទេសហ្វូណន ។

## អារ្យធម៌នៅសម័យហ្វូណន–

**ខាងទំនៀមទំលាប់ :–** ចាប់តាំងពីសតវត្សទី ៣ មក អ្នកស្រុកទាំងឡាយបានចេះស្លៀកសំពត់ទាំងអស់គ្នា ។ ដើម្បីរកយុត្តិធម៌ គេពឹងផ្អែកទៅលើទេវរិទ្ធ មានធ្វើការស្បថនិងការអធិដ្ឋានជាដើម ។ កាលណាមានមនុស្សស្លាប់ គេយកសាកសពទៅចោលក្នុងទឹក ឬ កប់ ឬ បូជា ឬដាក់ចោលឲ្យសត្វស៊ី ។

**ខាងសាសនា :–** ព្រះរាជវង្សានុវង្ស និងនាម៉ឺនមុខមន្ត្រី ច្រើនកាន់ព្រហ្មញ្ញសាសនា ដែលមានព្រះវិស្ណុ និងព្រះសិវៈជាដើម ។ ឯរាស្ត្រប្រជា កាន់ព្រះពុទ្ធសាសនាតាមលទ្ធិមហាយាន ។

**សង្គមមនុស្ស :–** តាមរបៀបឥណ្ឌា សង្គមមនុស្សចែកជាបួនវណ្ណៈ ។ គឺវណ្ណៈព្រាហ្មណ៍ វណ្ណៈខត្តិយៈ វណ្ណៈវេស្សៈ និងវណ្ណៈសូទ្រៈ ។ តែដោយឥទ្ធិពលនៃព្រះពុទ្ធសាសនា ដែលមិនទទួលស្គាល់រឿងវណ្ណៈ ការចែកវណ្ណៈនៅសម័យនោះ ក៏ពុំសូវតឹងរឹងពេកទេ ។

**ខាងសេដ្ឋកិច្ច :–** កសិកម្មមានការលូតលាស់ច្រើន ។ ដីសណ្តនៃទន្លេមេគង្គ បានត្រូវបង្ហូត ដើម្បីដាំដំណាំ ។ ផលិតខាងសិប្បកម្ម ដូចជាសំពត់ គ្រឿងកែវ មាស ប្រាក់ បាននាំទៅបរទេស មានប្រទេសចិនជាដើម ។ ប្រទេសហ្វូណនធ្វើជំនួញជាមួយនឹងចិន ឥណ្ឌា

*ចំប៉ា ផ្កា ។*

**របបគ្រប់គ្រង** :- *ព្រះរាជាមានសេវកាមាត្យ ជាព្រះរាជបរិវារ ។ ឯមន្ត្រីជាន់ខ្ពស់ទាំងឡាយ ជាអ្នកកាន់រាជរដ្ឋាភិបាល ។ ម្យ៉ាងទៀត ព្រះរាជានៃហ៊្វូណន មានប្រទេសចំណុះច្រើន ដែលព្រះអង្គគ្រប់គ្រង តាមរបបសក្ដិភូមិ ។ របបនេះពុំមានជំហររឹងប៉ឹងទេ ។ តែកាលណាព្រះរាជាហ៊្វូណនពុំមានវិទ្ធានុភាពបរិបូណ៌ ស្រុកចំណុះទាំងឡាយរមែងបះបោរឡើង ។*

—oOo—

**សេចក្ដីសង្ខេប** :- នៅចុងសតវត្សទី ៤ មានព្រាហ្មណ៍មួយរូបទៀត ឈ្មោះកោណ្ឌញ្ញដែរ បានមកសោយរាជ្យនៅប្រទេសហ្វ៊ូណន ហើយទ្រង់ព្រះនាមថា ព្រះបាទកោណ្ឌញ្ញទី២។ ព្រះរាជាដែលសោយរាជ្យក្រោយព្រះអង្គ ហើយមានវិទ្ធានុភាពជាងគេ គឺព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន ។

នៅសម័យហ្វ៊ូណន អ្នកស្រុកចេះស្លៀកសំពត់ តាំងពីសតវត្សទី៣ ។ ដើម្បីរកយុត្តិធម៌ គេពឹងផ្អែកទៅលើការស្បថ និងអធិដ្ឋានដល់ទេវតា ។ កាលណាមានមនុស្សស្លាប់ គេយកសាកសពទៅចោលក្នុងទឹក កប់ បូជា ឬ ដាក់ឲ្យសត្វស៊ី ។ ខាងសាសនា មានព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា ។ សង្គមមនុស្សចែកជាបួនវណ្ណៈ គឺពួកព្រាហ្មណ៍ ខត្តិយៈ វេស្សៈ និងសូទ្រៈ ។ ខាងសេដ្ឋកិច្ច កសិកម្ម និងជំនួញ មានការលូតលាស់ច្រើន ។ របបគ្រប់គ្រង គឺរបបសក្តិភូមិ ។ កាលណាព្រះរាជាហ្វ៊ូណនពុំសូវមានវិទ្ធានុភាព ស្ដេចចំណុះទាំងឡាយរមែងបះបោរ ។

**សំណួរៈ–** ព្រះបាទកោណ្ឌញ្ញទី២ សោយរាជ្យនៅហ៊្វូណនក្នុងសតវត្សទីប៉ុន្មាន? អ្នកស្រុកចេះស្លៀកសំពត់ពីត្រឹមណាមក? ដើម្បីរកយុត្តិធម៌ គេធ្វើម្ដេច? មានសាសនាអ្វីខ្លះក្នុងសម័យនោះ? សង្គមមនុស្សចែកជាប៉ុន្មានវណ្ណៈ? គឺវណ្ណៈអ្វីខ្លះ? កាលណាមានមនុស្សស្លាប់គេយកសាកសពទៅធ្វើម្ដេច? ខាងសេដ្ឋកិច្ច មានអ្វីសំខាន់ជាងគេ? ហេតុអ្វីបានជារបបសក្តិភូមិមិនមានជំហរថិតថេរ?

* *

*

## ៤– ប្រទេសចេនឡា

### «ការធ្វើសញ្ជ័យយកហ៊្វូណន»

**ព្រះរាជាណាចក្រចេនឡាៈ–** *ពាក្យ "ចេនឡា" ក៏ដូចជាពាក្យ "ហ៊្វូណន" សុទ្ធតែពាក្យចិន ។ ប្រទេសចេនឡា ឬ កម្ពុជា ស្ថិតនៅត្រង់ផ្នែកខាងត្បូងនៃប្រទេសលាវ ជាប្រទេសចំណុះប្រទេសហ៊្វូណន ។ ព្រះរាជាដែលសោយរាជ្យក្នុងប្រទេសនេះ សុទ្ធសឹងជាក្សត្រដែលតព្រះរាជវង្សពីតាបសម្ហូយអង្គព្រះនាម កម្ពុ និងទេពអប្សរ មេរា ។*

**ប្រទេសចេនឡាធ្វើសញ្ជ័យយកហ៊្វូណនៈ –** *នៅពេលដែលហ៊្វូណនមានការបែកបាក់គ្នាក្នុងការគ្រប់គ្រងរាជ្យ ប្រទេសចេនឡា ឆ្លៀតក្នុងឱកាសនោះ ចាប់ផ្ដើមបះបោរប្រឆាំងនឹងហ៊្វូណន ។*

**ព្រះបាទភវវរ្ម័នទី ១ (៥៥០ - ៦០០)ៈ –** *ក្នុងភាគទី ២ នៃសតវត្សទី ៦ កាលព្រះអង្គទ្រង់ឡើងគ្រងរាជ្យ ព្រះអង្គបានចាប់ផ្ដើមធ្វើសញ្ជ័យ*

យកហ៊្វូណន ជាមួយនឹងព្រះអនុជព្រះអង្គព្រះនាម ចិត្រាសេនា ។ ក្នុងវេលាកាលនោះ ប្រទេសចេនឡា បានលាតសន្ធឹងមកខាងត្បូង គឺចូលដល់ទំនាបទន្លេមេគង្គ ។

**ព្រះបាទចិត្រាមហិន្ទ្រវរ្ម័នទី ១ (៦០០-៦១៥) :—** លុះព្រះបាទភវវរ្ម័នសុគតទៅ ហើយដោយព្រះអង្គគ្មានព្រះរាជទាយាទផង ព្រះអនុជព្រះអង្គក៏ឡើងគ្រងរាជ្យហើយទ្រង់ព្រះនាមជាព្រះបាទចិត្រាមហិន្ទ្រវរ្ម័ន។ ព្រះបាទចិត្រាមហិន្ទ្រវរ្ម័នព្រះអង្គទ្រង់បន្តស្នាព្រះហស្ដព្រះបាទភវវរ្ម័នមកទៀត ។ ព្រះអង្គយកបានភូមិភាគក្រចេះ និងមង្គលបូរី ហើយដើម្បីជាការធានាការពារនៃព្រំដែនខាងកើត ព្រះអង្គបានចងសម្ពន្ធមិត្តជាមួយនឹងចំប៉ា ។ លុះព្រះអង្គសុគតទៅ ប្រទេសចេនឡាមានជំហររឹងប៉ឹងមែនទែន ។

**ព្រះបាទឦសានវរ្ម័ន (៦១៥-៦៣៥) :—** ព្រះអង្គជាព្រះរាជបុត្រនៃព្រះបាទចិត្រាមហិន្ទ្រវរ្ម័ន ។ ព្រះអង្គបានបង្ហើយការធ្វើសញ្ជ័យយកប្រទេសហ៊្វូណន ដោយយកបានភូមិភាគនៃខេត្តកណ្ដាល ព្រៃវែង តាកែវ ចន្ទបុរ ។ ព្រះអង្គបានចងស្ពានមេត្រីជាមួយចិននិងចំប៉ា ។

**ព្រះបាទភវវរ្ម័នទី ២ (៦៣៩-៦៥៥) :—** កាលព្រះបាទឦសានវរ្ម័នសុគតទៅ ការកែងដណ្ដើមរាជ្យក៏កើតមានឡើង ដោយព្រះអង្គគ្មានព្រះរាជបុត្រ ។ តែនៅទីបំផុត មានស្ដេចមួយព្រះអង្គព្រះនាមភវវរ្ម័នទី២

ក៏បានឡើងគ្រងរាជ្យ ហើយព្រះអង្គបង្ក្រាបឲ្យមានការរៀបរយឡើងវិញ ។

**ព្រះបាទជ័យវរ្ម័នទី១ (៦៥៥-៦៨១):** — ព្រះអង្គជាព្រះរាជបុត្រ ព្រះបាទភវវរ្ម័នទី ២ ។ ព្រះអង្គបានតាំងរាជធានីនៅអង្គរបុរី (ក្នុងខេត្តតាកែវ) ។ ព្រះអង្គបានរក្សាការទូតដែលមានតាំងពីព្រះរាជាមុនៗមក ។ ព្រះអង្គទ្រង់កាន់ព្រហ្មញ្ញសាសនា គោរពព្រះហរិហរៈ ។ ក្នុងរជ្ជកាលព្រះអង្គ ប្រទេសចេនឡាមានសេចក្ដីរុងរឿង ក្សេមក្សាន្តរហូត ។ ព្រះអង្គសុគតនៅឆ្នាំ ៦៨១ ដោយឥតមានព្រះរជ្ជទាយាទ ។




ការធ្វើសញ្ជ័យយកហ្វូណន

—oOo—

**សេចក្ដីសង្ខេប** : — ប្រទេសចេនឡា ឬ កម្ពុជាស្ថិតនៅភាគខាងត្បូងនៃប្រទេសលាវសព្វថ្ងៃ ។ ប្រទេសនេះជាប្រទេសចំណុះប្រទេសហ្វូណន ។ ព្រះរាជាទាំងឡាយដែលសោយរាជ្យក្នុងប្រទេសនេះ ជាក្សត្រជាប់ព្រះញាតិវង្សនឹងតាបសមួយព្រះអង្គព្រះនាមកម្ពុ ។

នៅពេលដែលហ្វូណនមានការបែកបាក់គ្នា ប្រទេសចេនឡាបានចាប់ធ្វើសញ្ជ័យយកប្រទេសហ្វូណន ។ ព្រះរាជាដែលបានធ្វើការសញ្ជ័យនេះគឺព្រះបាទភវវរ្ម័នទី១ ព្រះបាទចិត្រាមហិន្ទ្រវរ្ម័ន និងព្រះបាទឦសានវរ្ម័នទី ១ គឺតាំងពីភាគទី ២ នៃសតវត្សទី៦ រហូតដល់ខាងដើមសតវត្សទី៧ ។ ព្រះបាទភវវរ្ម័នទី ២ ព្រះអង្គបានបង្ក្រាបការបះបោរ ធ្វើឲ្យមានការរៀបរយឡើងវិញ ។ តមកទៀត ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១ ប្រទេសចេនឡាមានសេចក្ដីក្សេមក្សាន្តរុងរឿងច្រើន ។

**សំណួរ**: — ពាក្យ „កម្ពុជា,, មានកំណើតមកពីណា? ចេនឡា ឬ កម្ពុជាស្ថិតនៅត្រង់ណា ? ចេនឡាកាលពីដើមចំណុះប្រទេសណា? ព្រះរាជាដែលសោយរាជ្យក្នុងប្រទេសនោះ ជាប់ព្រះញាតិវង្សពីណាមក? ហេតុម្ដេចបានជាចេនឡាហ៊ានវាយប្រទេសហ្វូណន? ស្ដេចអង្គណាខ្លះដែលបានធ្វើសញ្ជ័យយកហ្វូណន? ការធ្វើសញ្ជ័យនេះមានថេរវេលាពីកាលណាដល់កាលណា? ព្រះបាទភវវរ្ម័នទី ២ ព្រះអង្គបានធ្វើអ្វី ? ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័ន ប្រទេសចេនឡាយ៉ាងម្ដេច ?

* *

*

## ៥– ប្រទេសចេនឡាបែកជាពីរ

### « ការរាតត្បាតនៃប្រទេសជ្វា »

**មូលហេតុដែលនាំឱ្យប្រទេសចេនឡាបែកជាពីរ** : — *នៅឆ្នាំ ៦៨១ កាលព្រះបាទជ័យវរ្ម័នទី ១ សុគតទៅ ព្រះអង្គពុំមានព្រះរាជទាយាទទេ ។*

ព្រះមហេសីព្រះអង្គ ព្រះនាមជ័យទេវី ទ្រង់គ្រប់គ្រងរាជ្យជំនួសព្រះអង្គ ។ តែដោយប្រទេសចេនឡាធំពេក នៅឆ្នាំ ៧១០-៧១៥ ក៏មានកើតការវឹកវរទៀងក្នុងព្រះនគរ ។ បន្ទាប់មក ចេនឡាបានបែកជាពីរ ដែលហៅជា ចេនឡាដីគោក និងចេនឡាទឹកលិច ។

**ចេនឡាដីគោក** :— ប្រទេសចេនឡាដីគោកនៅខាងជើង ស្ថិតត្រង់ភូមិភាគចេនឡាពីដើម គឺត្រង់ភាគកណ្ដាលនិងភាគខាងត្បូងនៃប្រទេសលាវ ។ ចេនឡាដីគោកនេះ ជារដ្ឋមួយឯករាជ្យដាច់ដោយឡែកពីចេនឡាទឹកលិច មានភវៈបុរៈ ( តំបន់បាសាក់ ) ជារាជធានី ។ ព្រះរាជាប្រទេសនេះធ្លាប់មានការទាក់ទងខាងផ្លូវទូតជាមួយប្រទេសចិន ។

**ចេនឡាទឹកលិច** :— ប្រទេសចេនឡាទឹកលិចនៅខាងត្បូង ស្ថិតត្រង់ភូមិភាគប្រទេសហ្វូណនពីដើម គឺត្រង់ទំនាបទន្លេមេគង្គ ចាប់ពីខោនចុះទៅទល់នឹងសមុទ្រ ។ តមកមិនយូរប៉ុន្មាន ប្រទេសនេះក៏បានបែងចែកជារដ្ឋតូច ៗ តាមរបៀបសក្តិភូមិ ។ នៅចុងសតវត្សទី ៨ ប្រទេសចេនឡាទឹកលិច បែកជាប្រាំនគរយ៉ាងតិច ហើយថែមទាំងមានការប្រកួតប្រជែងគ្នាផង ។ ក្នុងចំណោមរដ្ឋតូចៗ ទាំងឡាយ គួរកត់សំគាល់រដ្ឋមួយដែលមាន.បម្ភៈបុរៈ ( សំបូរ - ក្រចេះ ) ជារាជធានី ហើយនិងស្ដេចមួយព្រះអង្គព្រះនាម ពុស្ករាក្ស ( PUSHKARAKSHA ) ដែលបានគាំងព្រះអង្គជាព្រះរាជាប្រទេសកម្ពុជានៅសម្ភៈបុរៈ ។

**ាររាតត្បាតពីប្រទេសជ្វា:–** ការបែកខ្ញែកគ្នា បានធ្វើឲ្យប្រទេសចេនឡា ធ្លាក់ចុះខ្សោយ ៗ ជាគ្រោះអាក្រក់មួយបន្ថែមទៀត ប្រទេសនេះបាន ពើបប្រទះនឹងការរាតត្បាតពីប្រទេសជ្វា នៅចុងសតវត្សទី ៨ ។ ក្នុង សម័យនោះ ពួកជ្វាទាំងនោះ បានប្លន់ប្រទេសចំប៉ា ចូលមកប្រទេស ចេនឡាទឹកលិច ឡើងតាមទន្លេមេគង្គរហូតដល់សម្ភុបុរៈ ។ ពួកទ័ព ជ្វាបានចូលលុកលុយទីក្រុង បានទាំងធ្វើគតព្រះរាជាផង ។ តាំងពីពេល នោះមក ប្រទេសចេនឡាទឹកលិច បានធ្លាក់ជាស្រុកចំណុះប្រទេសជ្វា រហូតមកទល់នឹងសតវត្សទី ៩ ។



**អារ្យធម៌នៃប្រទេសចេនឡា ក្នុងសម័យបាក់បែកៈ–** ថ្វីដ្បិតតែមានការបាក់បែក តែការចំរើនខាង វប្បធម៌នានាមែនមានជាដរាប ។

ខាងសាសនាក្នុងសម័យនោះ មានការ លូតលាស់ច្រើនខាងការប្រតិបត្តិព្រះហរិហរៈ ។ ព្រះហរិហរៈជាតួទេវៈ ដែលបូករួមទាំងព្រះហរិ គឺព្រះវិស្ណុ និងព្រះហរៈ គឺព្រះសិវៈ ។ ព្រះ គារវៈវត្ថុ សាងឡើងជារូបតែមួយ តែភាគខាង

ះហរិហរៈ នៅប្រាសាទអណ្ដែត ក្នុងសតវត្សទី ៨

ត្បូង តំណាងព្រះវិស្ណុ និងភាគខាងស្តាំតំណាងព្រះសិវៈ ។

គួរកត់សំគាល់ថាក្នុងសម័យនោះ មានទេវរូបនៅប្រាសាទអណ្តែត និងកោះក្រៀង ដែលសាងឡើងប្រកបដោយវិចិត្រសិល្បៈគួរឲ្យស្ងើច ព្រោះទេវរូបនោះមានភាពដូចមនុស្សសុទ្ធសាធ ។

—oOo—

**សេចក្តីសង្ខេបៈ—** ក្រោយពីឆ្នាំ ៦៨១ លុះព្រះបាទជ័យវរ្ម័នទី១ សុគតទៅ ព្រះមហេសីព្រះអង្គព្រះនាម ជ័យទេវី ព្រះអង្គគ្រប់គ្រងរាជ្យផ្ទាល់ព្រះអង្គ ។ តែដោយប្រទេសចេនឡាធំពេកចំពោះព្រះអង្គ ប្រទេសក៏បែកជាពីរ ដែលហៅថា ចេនឡាដីគោក និងចេនឡាទឹកលិច។ ប្រទេសចេនឡាដីគោកស្ថិតនៅត្រង់ចេនឡាពីដើម ។ ឯចេនឡាទឹកលិចស្ថិតនៅត្រង់ហ្វូណនពីដើម ។

មកដល់ចុងសតវត្សទី ៨ ប្រទេសចេនឡាទឹកលិច បានបែកជាប្រទេសតូចៗប្រាំទៅទៀត ។ ការបែកបាក់នេះបានធ្វើឲ្យប្រទេសនេះចុះខ្សោយខ្លាំង ។ ទទួលក្នុងឱកាសនោះមានពួកជ្វាចូលមកពតត្បូកជ្រោយឥណ្ឌូចិន បានប្លន់ប្រទេសចេនឡាទឹកលិច ដុតទីក្រុងសម្ភៈបុរៈនិងធ្វើឃាដព្រះរាជាផង ។ គឺតាំងពីពេលនោះមកទល់នឹងសតវត្សទី ៩ ប្រទេសនេះក៏បានធ្លាក់ជាប្រទេសចំណុះប្រទេសជ្វា ។

ក្នុងសម័យចេនឡា មានការរីកចំរើននូវការគោរពព្រះហរិហរៈ ។

**សំណួរ :—** បន្ទាប់ពីព្រះបាទជ័យវរ្ម័នទី១ ព្រះរាជាណាគ្រប់គ្រងចេនឡា ? ហេតុអ្វីបានជាចេនឡាបែកជាពីរ ? ចេនឡាដីគោកនៅឯណា ? ចេនឡាទឹកលិចនៅឯណា ? ហេតុអ្វីបានជាចេនឡាទឹកលិចធ្លាក់ខ្សោយ ? ជ្វាមកលុកលុយចេនឡាក្នុងសតវត្សទីប៉ុន្មាន? ក្នុងសម័យចេនឡា គេគោរពអ្វី ខាងសាសនា ?

# ជំពូកទី៣-សម័យអង្គរ

## ៦-ព្រះបាទជ័យវរ្ម័នទី២ និង ព្រះបាទឥន្ទ្រាវរ្ម័នទី១

**ះបាទជ័យវរ្ម័នទី២ (៨០២-៨៥០) :–** ព្រះអង្គដែលជាក្សត្រជាប់ព្រះញាតិវង្សនឹងព្រះរាជានៃប្រទេសចេនឡាទឹកលិច ព្រះនាមពុស្ករក្សបានត្រូវពួកជ្វាចាប់ជាឈ្លើយ នាំយកទៅឯស្រុកជ្វា នៅឱកាសដែលពួកជ្វាចូលមកពតត្បាតប្រទេស ។ នៅឆ្នាំ ៨០០ ព្រះអង្គបានយាងត្រឡប់មកពីស្រុកជ្វាវិញ ។

**កម្ពុជាបានឯករាជ្យ :–** ដំបូងព្រះអង្គគង់នៅឥន្ទ្របុរី រួចយាងទៅគង់នៅហរិហរាល័យ (រលួស) និងអមរេន្ទ្របុរី (បាពយខាងលិច) ទៀត ។ បន្ទាប់ពីបានពង្រឹងឥទ្ធិពលព្រះអង្គក្នុងប្រទេស និងកំចាត់ទ័ពចាមដែលបានមកឈ្លានពានកម្ពុជា នៅឆ្នាំ ៨០២ ព្រះអង្គក៏ទទួលព្រះរាជាភិសេក និងប្រកាសឯករាជ្យ លែងចំណុះប្រទេសជ្វា ។ ដើម្បីប្រសិទ្ធព្រះអង្គឲ្យទៅជាទេវរាជ កុំឲ្យចំណុះអ្នកណាបាន ព្រះអង្គបានឲ្យរៀបពិធីអភិសេកព្រះអង្គ នៅលើកំពូលភ្នំ មហេន្ទ្រា (ភ្នំគូលេន) តាមរបៀបព្រហ្មញ្ញសាសនា ហើយឲ្យធ្វើនមស្ការចំពោះព្រះអង្គឲ្យដូចជាព្រះទេវៈ ។ ពិធីនេះមានទីដៅម្យ៉ាងទៀត គឺពង្រឹងព្រះរាជបល្ល័ង្កឲ្យមានស្ថេរភាព ។

នៅទីអវសាន ព្រះអង្គបានយាងមកគង់នៅ"ហរិហរាល័យ"វិញ ។




ព្រះរាជធានី ក្នុងរជ្ជកាល ព្រះបាទជ័យវរ្ម័នទី២

**ព្រះរាជាសោយរាជ្យក្រោយព្រះអង្គ** :— លុះព្រះបាទជ័យវរ្ម័នទី២ សុគតទៅ ព្រះរាជបុត្រព្រះអង្គឡើងគ្រងរាជ្យ ហើយទ្រង់ព្រះនាមថា ព្រះបាទជ័យវរ្ម័នទី ៣ ( ៨៥០-៨៧៧ ) ។ ព្រះអង្គទ្រង់គង់នៅហរិហរាល័យ ។ ព្រះអង្គបានខំគ្រប់គ្រងព្រះរាជាណាចក្រ ឲ្យបានគង់វង់គឺព្រះរាជាណាចក្រកម្ពុជាទឹកលិច ( កម្ពុជាដីគោកនៅក្រៅអំណាចព្រះអង្គនៅឡើយ ) ។

**ព្រះបាទឥន្ទ្រាវរ្ម័នទី ១ (៨៧៧-៨៨៩)** :- ព្រះបាទជ័យវរ្ម័នទី៣ សុគតទៅ ហើយដោយព្រះអង្គគ្មានព្រះរាជបុត្រផង ព្រះបាទឥន្ទ្រាវរ្ម័នទី ១ ដែលជាប់ព្រះញាតិវង្សខាងព្រះវរមាតា ព្រះអង្គក៏បានឡើងគ្រងរាជ្យ ។

ព្រះបាទឥន្ទ្រាវរ្ម័នទី ១ ព្រះអង្គជាមហាក្សត្រប្រកបដោយសេចក្ដីក្លាហាន វិរយភាព កិត្តិយស និងនិស្ស័យជាសិល្បករ ។ ព្រះអង្គមានចំណេះវិជ្ជាជ្រៅជ្រះ ដោយព្រះអង្គ មានព្រាហ្មណ៍អ្នកប្រាជ្ញម្នាក់ជាព្រះគ្រូ ។

**កម្ពុជាបានឯកភាព** :- ដោយព្រះអង្គបានទទួលជាព្រះរាជមតិកនូវព្រះរាជាណាចក្រសម្ភុៈបុរៈ និងទំនាបនៃទន្លេមេគង្គ (បេនឡាទឹកលិច) យកមកបូករួមនឹងកម្ពុជា ដែលជាដំណែលព្រះបាទជ័យវរ្ម័នទី ២ទៀត ឯកភាពខ្មែរ កាលនោះសឹងតែបានសំរេចហើយ ព្រោះនៅសល់តែកវៈបុរៈ (បេនឡាដីគោក) ដែលមិនទាន់ចុះចូល ។

**ស្នាព្រះហស្ត**:- កាលព្រះអង្គគង់នៅហរិហរាល័យ ព្រះអង្គមានការទាក់ទងខាងផ្លូវទូតយ៉ាងប្រសើរ ជាមួយនឹងប្រទេសជិតខាងដូចជា ចិន ជ្វា ចំប៉ា ។

ខាងកិច្ចការក្នុងប្រទេស ព្រះអង្គបានខំពង្រីកសេដ្ឋកិច្ច និងលំអព្រះរាជធានី ។ នៅឆ្នាំ ៨៧៧ ព្រះអង្គបានឲ្យជីកស្រះមួយយ៉ាងធំនៅខាងជើងទីក្រុង ។ នៅឆ្នាំ ៨៧៩ ព្រះអង្គឲ្យសាងប្រាសាទព្រះគោ ដើម្បីឧទ្ទិស

*ថ្វាយដល់ព្រះអតីតមហាក្សត្រ ។ នៅឆ្នាំ ៨៨១ ព្រះអង្គបានឲ្យសាង ប្រាសាទបាគង សម្រាប់ធ្វើសក្ការៈបូជាចំពោះព្រះទេវរាជ ។*

— oOo —

**សេចក្ដីសង្ខេប**:– ព្រះបាទជ័យវរ្ម័នទី២(៨០២-៨៥០) ដែលជ្វាចាប់ជាឈ្លើយ បានយាងត្រឡប់មកវិញនៅឆ្នាំ៨០០ ។ បន្ទាប់ពីបានពង្រឹងឥទ្ធិពលព្រះអង្គនៅក្នុងប្រទេស និងបានកំចាត់ទ័ពចាមដែលមកឈ្លានពានកម្ពុជា នៅឆ្នាំ៨០២ ព្រះអង្គក៏ទទួលព្រះរាជាភិសេក និងប្រកាសឯករាជ្យ ។ ដើម្បីប្រសិទ្ធិព្រះអង្គឲ្យទៅជាព្រះទេវរាជ និងឈប់នៅចំណុះប្រទេសឯទៀតបាន ព្រះអង្គបានឲ្យរៀបពិធីអភិសេកព្រះអង្គ នៅលើភ្នំ មហិន្ទ្រា ហើយឲ្យធ្វើនមស្ការចំពោះព្រះអង្គ ឲ្យដូចជាទេវៈ ។ ព្រះបាទជ័យវរ្ម័នទី២ ព្រះអង្គទ្រង់គង់នៅហរិហរាល័យ ។

ព្រះបាទជ័យវរ្ម័នទី២ ព្រះអង្គបានបង្រួបបង្រួមកម្ពុជាទឹកលិច ។ ព្រះរាជបុត្រព្រះអង្គព្រះបាទជ័យវរ្ម័នទី ៣ គ្រាន់តែបានឃុំគ្រងព្រះរាជដំណែលឲ្យគង់វង់តែប៉ុណ្ណោះ។ នៅក្នុងរជ្ជកាលព្រះបាទឥន្ទ្រាវរ្ម័នទី១ (៨៧៧-៨៨៩) ខ្មែរមានឯកភាពឡើងវិញ នៅសល់តែភវបុរៈមួយទេ ។

ព្រះបាទឥន្ទ្រាវរ្ម័នទី១ ព្រះអង្គបានចងស្ពានមេត្រីជាមួយចិន ចាម ជ្វា ។ ព្រះអង្គបានសាងប្រាសាទបាគោ និងបាគង ។

**សំណួរ**:— ព្រះបាទជ័យវរ្ម័នទី២ ត្រូវជ្វាចាប់ទៅពីឆ្នាំណា ? យាងមកវិញព្រះអង្គបានធ្វើអ្វីខ្លះមុននឹងទទួលព្រះរាជាភិសេក ? ពិធីព្រះរាជាភិសេកធ្វើនៅទីណា ? ក្នុងគោលបំណងដូចម្ដេច ? ព្រះអង្គបានសាងឯករាជ្យដោយមធ្យោបាយអ្វីខ្លះ ? ព្រះរាជាណាសោយរាជ្យបន្ទាប់ព្រះអង្គ ? យ៉ាងម្ដេចបានជាព្រះបាទឥន្ទ្រាវរ្ម័នសាងឯកភាពបាន ? ព្រះបាទឥន្ទ្រា-វរ្ម័នទី ១ បានចងស្ពានមេត្រីនឹងប្រទេសណាខ្លះ ? បានសាងប្រាសាទណាខ្លះ ?

* *

*

# ៧– ព្រះបាទយសោវរ្ម័នទី១ និងព្រះរាជាសោយរាជ្យ ក្រោយព្រះអង្គ

**ព្រះបាទយសោវរ្ម័នទី១ (៨៨៩-៩០០)** — *នៅឆ្នាំ ៨៨៩ លុះព្រះបាទឥន្ទ្រាវរ្ម័នសុគតទៅ ព្រះរាជបុត្រព្រះអង្គព្រះនាម យសោវរ្ម័នទី១ ឡើងគ្រងរាជ្យ ។ ព្រះអង្គជាមហាក្សត្រប្រកបដោយឋាមពល ចំណេះវិជ្ជា គុណធម៌ ពិធីសាស្ត្រ ។*

**ស្នាព្រះហស្ត :--** *ស្នាព្រះហស្តសំខាន់ជាងគេ គឺមូលស្ថាបនាអង្គរ ។ ដោយហរិហរាល័យ ជារាជធានីពុំមានបែបផែនប្រកបដោយសារព័ន្ធភាព ព្រះអង្គក៏ទ្រង់សាងយសោធរបុរៈដែលជារាជធានីថ្មីនៅភ្នំបាខែង ។*

*ក្រៅពីនោះ ព្រះអង្គបានសាងប្រាសាទ លលៃ ដើម្បីឧទ្ទិសថ្វាយ ចំពោះព្រះវិញ្ញាណក្ខន្ធនៃព្រះអតីតមហាក្សត្រ ប្រាសាទនៅលើភ្នំក្រោម និងនៅភ្នំបូក ដើម្បីឧទ្ទិសថ្វាយចំពោះព្រហ្មញ្ញសាសនា ។ ព្រះអង្គបានឲ្យជីកបារាយណ៍ខាងកើត បណ្តោយប្រវែង៧ គ.ម និងទទឹង១,៨០០គ.ម។ ព្រះអង្គបានឲ្យលើកផ្លូវ ពីយសោធរបុរៈទៅដល់បារាយណ៍ ខាងហរិហរាល័យ ។*

*ក្នុងរជ្ជកាលព្រះអង្គ មានចំបាំងនឹងចាម- ឬ ថ្វា ហើយមានជោគជ័យ ។ លុះព្រះអង្គសុគតទៅ ព្រំដែននៃកម្ពុជា ដែលព្រះអង្គបានពង្រីកដោយសន្តិភាព បានលាតពីលាវខាងត្បូង ទៅទល់ឈូងសមុទ្រ*

សៀម ទ័ពពីខ្មែរកូសាំងស៊ីន ទៅដល់ប្រទេសភូមា ។ ព្រះអង្គទ្រង់សុគតនៅឆ្នាំ ៩០០ បន្ទាប់ពីបានសោយរាជ្យ ១១ ឆ្នាំ ។



ភ្នំបាខែង ទីធ្វើនមស្ការៈ

## ព្រះរាជាសោយរាជ្យក្រោយព្រះបាទយសោវរ្ម័នទី១.–

**ព្រះបាទហស៌វរ្ម័នទី១ (៩០០-៩២២) ព្រះបាទជ័យវរ្ម័នទី៤ (៩២២-៩៤២) និង ព្រះបាទឦសាណវរ្ម័នទី ២ (៩២២-៩២៨) :–** លុះព្រះបាទយសោវរ្ម័នសុគតទៅ ព្រះរាជបុត្រព្រះអង្គគឺព្រះបាទ ហស៌វរ្ម័នទី ១ ព្រះអង្គទ្រង់ឡើងគ្រងរាជ្យ ។ មកដល់ឆ្នាំ ៩២១ ព្រះបិតុលាព្រះអង្គ ទ្រង់បានប្រឆាំងនឹងព្រះអង្គ ហើយប្រកាសជាមហាក្សត្រព្រះនាមព្រះបាទជ័យវរ្ម័នទី ៤ តាំងព្រះរាជធានីនៅកោះកែរ ។ នៅឆ្នាំ ៩២២ ព្រះបាទហស៌វរ្ម័នសុគតទៅ ព្រះអនុជព្រះអង្គព្រះបាទឦសាណវរ្ម័នទី២ទ្រង់ឡើងគ្រងរាជ្យនៅអង្គរ ។ កាលនោះ កម្ពុជាបែកជាពីររហូតដល់ព្រះបាទឦសាណវរ្ម័នសុគតទើបកម្ពុជាបានរួមតែមួយវិញដោយមានព្រះរាជាតែមួយព្រះអង្គ គឺព្រះបាទជ័យវរ្ម័នទី៤នោះឯង ដែលគ្រងរាជ្យនៅកោះកែរ ។

**ព្រះបាទហស៌វរ្ម័នទី២ (៩៤២-៩៤៤)** – នៅកោះកែរ ព្រះបាទជ័យវរ្ម័នទី៤ ព្រះអង្គបានសាងប្រាសាទដ៏ធំសំបើម ។ លុះព្រះអង្គសុគតទៅ ព្រះរាជបុត្រព្រះអង្គ គឺព្រះបាទហស៌វរ្ម័នទី ២ សោយរាជ្យបន្តមកទៀតបាន ៣ ឆ្នាំ ។

**ព្រះបាទរាជិន្ទ្រវរ្ម័នទី ២ (៩៤៤-៩៦៨):–** លុះព្រះបាទហស៌វរ្ម័នទី២ សុគតទៅ ព្រះបាទរាជិន្ទ្រវរ្ម័ន ដែលត្រូវជាព្រះភាគិនេយ្យ នៃ

ព្រះបាទជ័យវរ្ម័នទី ៤ ឡើងគ្រងរាជ្យ ។ ដោយព្រះអង្គបានព្រះរាជមតិក នូវកវៈបុរៈ (បេទឡាដីគោក) ផង ព្រះអង្គក៏បានសម្រេចឯកភាពខ្មែរ យ៉ាងពេញលេញ ហើយព្រះអង្គក៏យាងមកគង់នៅយសោធបុរៈវិញ ។ នៅឆ្នាំ ៩៤៥ ព្រះអង្គបានធ្វើចំបាំងនឹងចាមដែលមកឈ្លានពានលើទឹកដីខ្មែរ ។ ព្រះអង្គបានសាងប្រាសាទមេបុណ្យខាងកើត ប្រាសាទប្រែរូប ប្រាសាទភិមានអាកាស ប្រាសាទបាទដុំ ។



ប្រាសាទ ប្រែរូប

ក្នុងរជ្ជកាលព្រះអង្គ ព្រាហ្មណ៍យជ្ញវរាហ៍ ( Yajnâvarâha ) បានសាង ប្រាសាទបន្ទាយស្រីក្នុងឆ្នាំ ៩៦៧ ។



ប្រាសាទ បន្ទាយស្រី

**ព្រះបាទជ័យវរ្ម័នទី៥ (៩៦៨-១០០១):–** ព្រះអង្គជាព្រះរាជបុត្រព្រះបាទរាជិន្ទ្រវរ្ម័នទី២ ។ ព្រះអង្គបានសាងប្រាសាទតាកែវ ។



ប្រាសាទ តាកែវ

—oOo—

**សេចក្ដីសង្ខេប** :– ព្រះបាទយសោវរ្ម័នទី១ ត្រូវជាព្រះរាជបុត្រព្រះបាទឥន្ទ្រវរ្ម័ន។ព្រះអង្គបានតាំងព្រះរាជធានីថ្មីឈ្មោះយសោធបុរៈនៅភ្នំបាខែង ប្រកបដោយន័យនិងបែបផែន។ព្រះអង្គបានសាងប្រាសាទ លលៃនៅហរិហរាល័យ ប្រាសាទនៅភ្នំក្រោម ប្រាសាទនៅភ្នំបូក បានឲ្យជីកបារាយណ៍ខាងកើត ។

បន្ទាប់ពីព្រះរជ្ជកាលព្រះបាទយសោវរ្ម័ន និងព្រះបាទហស៌វរ្ម័នទី១តមកក្នុងរជ្ជកាលព្រះបាទឦសាណវរ្ម័នទី២កម្ពុជាគ្រប់គ្រងដោយព្រះរាជាពីរអង្គ គឺព្រះបាទឦសាណវរ្ម័នទី២ដែលគង់នៅយសោធបុរៈ (អង្គរ) និងព្រះបាទជ័យវរ្ម័នទី៤ដែលគង់នៅកោះកែរ។លុះព្រះបាទឦសាណវរ្ម័នទី២សុគតទៅ ប្រទេសកម្ពុជាបានរួមតែមួយវិញក្រោមព្រះបាទជ័យវរ្ម័នទី៤ ដែលគង់នៅកោះកែរ។ តែបន្ទាប់ពីព្រះអង្គមក ព្រះរជ្ជទាយាទព្រះអង្គទ្រង់ឡើងគ្រង

រាជ្យ ក្នុងព្រះនាមព្រះបាទហស៌វរ្ម័នទី ២ ដែលគង់នៅកោះកែរដដែល ។ លុះដល់ព្រះបាទរាជិន្ទ្រវរ្ម័នទី ២ ឡើងគ្រងរាជ្យ ទើបព្រះអង្គយាងមកគង់នៅយសោធបុរៈវិញ ។ ព្រះបាទរាជិន្ទ្រវរ្ម័នទី ២ ព្រះអង្គសាងប្រាសាទមេបុណ្យ (ខាងកើត) ប្រាសាទបាទជុំ ចាប់ផ្ដើមភិមានអាកាស ។ ក្នុងរជ្ជកាលព្រះអង្គ ព្រាហ្មណ៍ម្នាក់ឈ្មោះយជ្ញវរាហ៍បានសាងប្រាសាទបន្ទាយស្រី ។ ព្រះបាទជ័យវរ្ម័នទី ៥ ដែលសោយរាជ្យបន្ទាប់ពីព្រះបាទរាជិន្ទ្រវរ្ម័នទី ២ បានសាងប្រាសាទតាកែវ ។

សំណួរ:— ព្រះបាទយសោវរ្ម័នទី ១ តាំងព្រះរាជធានីនៅឯណា? ឈ្មោះអ្វី? ព្រះអង្គបានសាងប្រាសាទណាខ្លះ? ព្រះរាជាអង្គណាដែលសោយរាជ្យបន្ទាប់ពីព្រះបាទយសោវរ្ម័ន? បន្ទាប់ពីរជ្ជកាលព្រះបាទហស៌វរ្ម័នទៅ ប្រទេសកម្ពុជាមានព្រឹត្តិការណ៍យ៉ាងម្ដេច? កាលនោះព្រះរាជាព្រះនាមអ្វី ដែលគង់នៅយសោធបុរៈ? ហើយព្រះរាជាអង្គណាដែលគង់នៅកោះកែរ? ព្រះបាទរាជិន្ទ្រវរ្ម័នទី២ ព្រះបាទជ័យវរ្ម័នទី ៥ បានសាងអ្វីខ្លះ?

## ៨– ចំបាំងគ្នាឯងនៅឯដើមសតវត្សទី១១

### «ព្រះបាទសុរិយាវរ្ម័នទី១»

រជ្ជកាលព្រះបាទឧទយាទិត្យវរ្ម័ន (១០០១):— *លុះព្រះបាទជ័យវរ្ម័នទី ៥ សុគតទៅ នៅឆ្នាំ ១០០១ ព្រះគាត់នេយ្យព្រះអង្គមួយព្រះអង្គ ទ្រង់ឡើងគ្រងរាជ្យ ហើយទ្រង់ព្រះនាមថា ព្រះបាទឧទយាទិត្យវរ្ម័ន ។ ព្រះអង្គសោយរាជ្យបានតែប៉ុន្មានខែ ស្រាប់តែបាត់ព្រះអង្គទៅ មិនដឹងជាព្រះ*

អង្គជាក់រាជ្យ ឬទ្រង់សុគត ហើយនៅក្នុងពេលនោះ កម្ពុជាក៏មានកើតចលាចលឡើង ដោយមានក្សត្រច្រើនអង្គ បានបែងចែកប្រទេសជាច្រើនបំណែក ហើយប្រកាន់ថា ជាបុព្វសិទ្ធិពល់ៗអង្គ ។

**ព្រះបាទជ័យវិរវរ្ម័ន (១០០២ ១០១០) និង ព្រះបាទសុរិយាវរ្ម័នទី ១ (១០០២ -១០៥០):–** នៅឆ្នាំ ១០០២ ព្រះបាទជ័យវិរវរ្ម័ន ព្រះអង្គទ្រង់ឡើងគ្រងរាជ្យបន្តពីព្រះបាទ ឧទយាទិត្យវរ្ម័ន នៅយសោធបុរៈ ។ ក្នុងពេលនោះដដែល គឺនៅឆ្នាំ ១០០២ មានក្សត្រមួយអង្គទៀត ដែលទ្រង់អះអាងថា ព្រះមាតាព្រះអង្គ ជាប់ព្រះញាតិវង្សនឹងព្រះបាទឥន្ទ្រវរ្ម័ន ទ្រង់បានប្រកាសព្រះអង្គជាព្រះរាជានៃកម្ពុជាដែរ ហើយទ្រង់ព្រះនាមថា ព្រះសុរិយាវរ្ម័នទី ១ នៅកំពត ។ ព្រះបាទសុរិយាវរ្ម័នទី ១ ទ្រង់លើកទ័ពមកច្បាំងនឹងព្រះបាទជ័យវិរវរ្ម័ន ។ ព្រះបាទសុរិយាវរ្ម័នទី ១ ព្រះអង្គយកយសោធបុរៈបាននៅឆ្នាំ១០០៦ ។ តែចំបាំងគ្នាឯងណេះនៅតែនៅមានបន្តមកទៀតអស់កាល ៤ ឆ្នាំ ។ បានជោគជ័យហើយ ព្រះអង្គនៅខំព្យាយាមបង្ក្រាបក្សត្រទាំងឡាយណាដែលអាចមានព្រះសិទ្ធិគ្រប់គ្រងរាជ្យ ឬក្សត្រអង្គណាដែលមិនបញ្ចូលព្រះទ័យនឹងគង់នៅក្រោមអំណាចព្រះអង្គ ។ លុះដល់ឆ្នាំ ១០១០ ទើបព្រះបាទសុរិយាវរ្ម័នទី ១ បានជោគជ័យជាស្ថាពរ ។ ព្រះអង្គសោយរាជ្យតែមួយអង្គឯង ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ព្រះហស្តព្រះបាទសុរិយោវង្សទី១·—

**សន្តិភាពនយោបាយគម្ពុ:**— កម្ពុជានៅក្នុងព្រះហស្តព្រះអង្គហើយ ក៏នៅតែមានការបះបោររំដើបរំដួល ។ ព្រះអង្គទ្រង់ខិតខំយ៉ាងខ្លាំងដើម្បីសាងឲ្យមានការរៀបរយឡើងវិញ ។

**ការរដ្ឋបាល :**— ព្រះអង្គទ្រង់រៀបចំការរដ្ឋបាល ឲ្យកាន់តែមានរបៀបឡើង ។ មន្ត្រីទាំងឡាយត្រូវគោរពលំដាប់ ជាន់ ថ្នាក់ ហើយត្រូវធ្វើសម្បថស្វាមីភក្តិ ចំពោះព្រះមហាក្សត្រផង ។ ព្រះអង្គទ្រង់មានព្រះជំនឿក្នុងព្រះពុទ្ធសាសនា តែព្រះអង្គក៏រក្សាឲ្យទៅជិតព្រះអង្គជាដរាបនូវមន្ត្រីទាំងឡាយដែលមានភារៈកិច្ចធ្វើការបូជាចំពោះព្រះទេវរាជ ។

**ការពង្រីកដែនដី :**— ដោយព្រះអង្គទ្រង់បានទទួលព្រះរាជមតិកពីព្រះវរបិតាព្រះអង្គនូវភូមិភាគលពបុរី ព្រះអង្គទ្រង់ពង្រីកដែនដីកម្ពុជាទៅខាងលិចថែមទៀត ។ ព្រះអង្គទ្រង់បានយកភូមិភាគចន្លោះទន្លេមេណាមនិងកម្ពុជាសព្វថ្ងៃ ។

**មូលស្ថាបនា:**— ព្រះអង្គទ្រង់ឲ្យបង្កើយប្រាសាទកិមានអាកាស ឲ្យសាងប្រាសាទព្រះវិហារ (នៅភ្នំដងរែក) ប្រាសាទភ្នំជីសូរ (ក្នុងខេត្តតាកែវ)។ ព្រះអង្គទ្រង់បានរៀបចំគំរោងដើម្បីសាងព្រះរាជធានីថ្មី ។ ព្រះអង្គទ្រង់បានចាប់ផ្តើមសាងប្រាសាទបាពួន ដែលជាប្រាសាទភ្នំ នៃក្រុងថ្មីនេះ ។ ការបង្ហើយនៃការស្ថាបនា ជាស្នាព្រះហស្តព្រះរាជបុត្រព្រះអង្គព្រះនាម

ព្រះបាទឧទយាទិត្យវរ្ម័នទី ២ ។



ប្រាសាទ ភិមានអាកាស

**ចំណុចសំគាល់**:- ព្រះបាទសុរិយាវរ្ម័នទី១ដែលទ្រង់បានធ្វើសញ្ជ័យយករាជបល្ល័ង្កបាន ព្រះអង្គទ្រង់បានបង្កើតសន្តតិវង្សមួយថ្មី ដែលហៅថាសន្តតិវង្សព្រះបាទសុរិយាវរ្ម័នទី១ ។

-oOo-

**សេចក្ដីសង្ខេប**:– នៅឆ្នាំ ១០០១ បន្ទាប់ពីព្រះបាទឧទយាទិត្យវរ្ម័នឡើងគ្រងរាជ្យបានប៉ុន្មានខែ កម្ពុជាក៏បានត្រូវបែងចែកជាច្រើនចំណែក ។ នៅឆ្នាំ ១០០២ ព្រះបាទជ័យវីរវរ្ម័ន(១០០២-១០១០) ទ្រង់ឡើងគ្រងរាជ្យនៅអង្គរ ។ នៅពេលនោះព្រះបាទសុរិយាវរ្ម័នទី១ ក៏ប្រកាសព្រះអង្គជាមហាក្សត្រដែរ ហើយលើកទ័ពពីកំពតមកច្បាំងនឹងព្រះបាទជ័យវីរវរ្ម័នហេតុបានជ័យជំនះ ។ លុះព្រះអង្គបានសម្រេចជាព្រះមហាក្សត្រតែមួយព្រះអង្គនៅកម្ពុជាហើយ ព្រះអង្គទ្រង់បង្ក្រាបការបះបោរក្នុងស្រុក ។ ព្រះអង្គទ្រង់រៀបចំការរដ្ឋកាលឲ្យកាន់តែមានរបៀបឡើង ។ ព្រះអង្គទ្រង់កាន់ព្រះពុទ្ធសាសនា តែមួលស្ថាបនាទាំងឡាយ សាងឡើងសុទ្ធតែដើម្បីព្រហ្មញ្ញសាសនា ។ ព្រះអង្គទ្រង់បានបង្ហើយប្រាសាទភិមានអាកាស សាងប្រាសាទព្រះវិហារ ប្រាសាទភ្នំជីសូរ ។ ព្រះអង្គទ្រង់បានរៀបចំកំពែងព្រះរាជធានីថ្មី និងចាប់ផ្ដើមសាងប្រាសាទបាពួន ដែលជាប្រាសាទភ្នំនៃក្រុងថ្មីនេះ ។

**សំណួរ**:– ក្នុងរជ្ជកាលព្រះបាទឧទយាទិត្យវរ្ម័ន មានព្រឹត្តិការណ៍អ្វី ? ព្រះរាជាអង្គណាដែលបានសោយរាជ្យបន្ទាប់ពីព្រះបាទឧទយាទិត្យវរ្ម័ន? ព្រះអង្គបានធ្វើចម្បាំងនឹងក្សត្រអង្គណា ? ព្រះបាទសុរិយាវរ្ម័នទី ១ ព្រះអង្គលើកទ័ពពីណាមក មកច្បាំងនឹងព្រះបាទជ័យវីរវរ្ម័ន ? ចម្បាំងនោះមានលទ្ធផលយ៉ាងម្ដេច ? អស់កាលប៉ុន្មានឆ្នាំ ? ព្រះបាទសុរិយាវរ្ម័នទី ១ ព្រះអង្គបានសាងអ្វីខ្លះ ?

* * *

## ៩– ព្រះបាទឧទយាទិត្យវរ្ម័នទី២–ព្រះបាទហស៌វរ្ម័នទី៣

**ព្រះបាទឧទយាទិត្យវរ្ម័នទី ២ (១០៥០-១០៦៦)**:– *ព្រះអង្គត្រូវជាព្រះរាជបុត្រព្រះបាទសុរិយាវរ្ម័នទី ១ ។ – កាលព្រះអង្គទ្រង់ឡើងគ្រងរាជ្យ*

ព្រះអង្គនៅក្នុងយុវភាពនៅឡើយ ។ ព្រះអង្គបានទទួលនូវការអប់រំជ្រៅជ្រះណាស់ ។

**ការបះបោរ** :- ក្នុងរជ្ជកាលព្រះអង្គ មានការបះបោរបីលើកនៅឆ្នាំ១០៥១ មួយលើក និងនៅឆ្នាំ ១០៥៥ ពីរលើកទៀតជាប់ៗគ្នា ។ តែការបះបោរទាំងបីលើកត្រូវបរាជ័យទៅវិញ ដោយសារស្នាដៃមេទ័ពព្រះអង្គដែលឈ្មោះសង្គ្រាម ។

**ការពង្រីកដែនដី** :— ថ្វីត្បិតតែនៅក្នុងប្រទេស មានការជ្រួលច្របល់ខ្លះ តែការពង្រីកទឹកដីក៏មានការចំរើនដែរ ។ ក្នុងរជ្ជកាលព្រះអង្គ ព្រំដែនខាងលិច បានខិតទៅឆ្ងាយជាងក្នុងរជ្ជកាលមុនៗ ។

**មូលស្ថាបនា** :— ព្រះអង្គបានសាងបង្ហើយប្រាសាទបាពួន ដែលព្រះវរបិតាព្រះអង្គទ្រង់បានចាប់ផ្តើម បានសាងប្រាសាទមេបុណ្យ នៅកណ្ដាលបារាយខាងលិច ព្រមទាំងបានជីកបារាយខាងលិចដែលមានបណ្ដោយ ៨ គម និងទទឹង ២,២ គម ។

**ព្រះបាទហស៌វរ្ម័នទី៣ ( ១០៦៦-១០៨០ )** :- លុះព្រះបាទឧទយាទិត្យវរ្ម័នទី ២ ទ្រង់សុគតទៅ ហើយដោយព្រះអង្គទ្រង់ពុំមានរាជបុត្រផង ព្រះរាជបល្ល័ង្កក៏បានមកព្រះអនុជព្រះអង្គ ព្រះនាមព្រះបាទហស៌វរ្ម័នទី ៣ ។

**ស្តារព្រះមហាស្តក្នុងប្រទេស** :— ព្រះអង្គបានសាងឲ្យមានវិបុលភាពនៅក្នុងប្រទេស ។ ព្រះអង្គបានធ្វើឲ្យមានការរៀបរយឡើងវិញ ដោយតម្រូវ

ឲ្យគោរពយ៉ាងតឹងតែងនូវវណ្ណៈទាំងបួន (ព្រាហ្មណ៍ ខត្តិយៈ វេស្សៈ និងសុទ្រៈ) និងជួសជុលឡើងវិញនូវប្រាសាទទាំងឡាយដែលខូចខាតដោយចម្បាំងគ្នាឯងក្នុងរជ្ជកាលមុន ។

**ចម្បាំង:** — ព្រះបាទហសិវរ្ម័នទី ៣ ព្រះអង្គសព្វព្រះហឫទ័យនឹងសាងសន្តិភាព ។ តែក្នុងរជ្ជកាលព្រះអង្គ ព្រះអង្គទ្រង់ស្ថិតនៅក្នុងកាតព្វកិច្ចត្រូវធ្វើសង្គ្រាមពីរ មួយជាមួយនឹងចាម មួយទៀតជាមួយនឹងគុងកឹង ។

**ចម្បាំងជាមួយចាម** :— នៅឆ្នាំ ១០៧៤ ចាមបានឈ្លានពានរំលោភព្រំដែន ចូលដល់សម្បុរៈ បានកំទេចទីនមស្ការនៅទីនោះ និងចាប់បណ្ដាជនធ្វើជាឈ្លើយ ។ ទ័ពខ្មែរតទល់ពុំសូវបានជោគជ័យទេ ។ តែដល់ឆ្នាំ ១០៨០ សុខសន្តិភាព ក៏បានកើតឡើងវិញរវាងប្រទេសទាំងពីរ ។

**ចម្បាំងនឹងគុងកឹង** :— នៅឆ្នាំ ១០៧៦ កម្ពុជាត្រូវធ្វើសង្គ្រាមនឹងគុងកឹង ដោយចិនប្រទាញ ។ លុះដល់ទ័ពចិនបរាជ័យទៅ ទ័ពខ្មែរក៏បានត្រឡប់មកវិញ ។

**នៅចុងរជ្ជកាល** :— មកដល់ឆ្នាំ ១០៨០ គឺនៅពេលដែលព្រះអង្គគង់នៅឡើយ នៅភាគខាងជើងនៃកម្ពុជា ក្នុងក្រុងមហិធរបុរៈ (ក្នុងជទ្ទង ទន្លេសមូន ) មានអភិជនមួយរូប បានប្រកាសខ្លួនជាព្រះរាជា ហើយតាំងព្រះនាមថា ព្រះបាទជ័យវរ្ម័នទី ៦ ។

—oOo—

**សេចក្តីសង្ខេប** :— ព្រះបាទឧទយាទិត្យវរ្ម័នទី ២ (១០៥០-១០៦៦) ព្រះអង្គត្រូវជាព្រះរាជបុត្រព្រះបាទសុរិយាវរ្ម័នទី ១ ។ ក្នុងរជ្ជកាលព្រះអង្គ មានការបះបោរបីលើក ។ តែទាំងបីលើកនៃការបះបោរនោះ បានបរាជ័យ ទៅវិញ ។ ថ្វីត្បិតតែនៅក្នុងប្រទេស មានការជ្រួលច្របល់ តែការពង្រីកទឹកដីក៏បានចំរើនដែរ ។ ខាងមូលស្ថាបនា ព្រះអង្គបានបង្ហើយប្រាសាទបាពួន សាងប្រាសាទមេបុណ្យខាងលិច និងបារាយខាងលិច ។

ព្រះបាទហស៌វរ្ម័នទី ៣ (១០៦៦-១០៨០) ព្រះអង្គត្រូវជាអនុជព្រះបាទឧទយាទិត្យវរ្ម័នទី ២ ។ ក្នុងប្រទេសព្រះអង្គបានធ្វើឲ្យមានរបៀបរៀបរយ និងឲ្យជួសជុលប្រាសាទដែលបាក់បែកដោយសារចម្បាំងក្នុងរជ្ជកាលមុន ។ ក្នុងរជ្ជកាលព្រះអង្គមានចំបាំងពីរលើក គឺចំបាំងនឹងចាម ហើយនឹងគុងកឹង ។ តែចំបាំងនេះពុំបានលទ្ធផលល្អទេ ។ នៅចុងរជ្ជកាលព្រះអង្គនៅក្រុងមហិធរបុរៈមានអភិជនមួយរូប បានប្រកាសខ្លួនជាស្តេច ហើយទ្រង់ព្រះនាមថាព្រះបាទជ័យវរ្ម័នទី ៦ ។

**សំណួរ** :— ព្រះរាជាអង្គណា សោយរាជ្យបន្ទាប់ពីព្រះបាទសុរិយាវរ្ម័នទី ១? ក្នុងរជ្ជកាលព្រះអង្គមានព្រឹត្តិការណ៍អ្វី ? ព្រះអង្គបានសាងអ្វីខ្លះជាមូលស្ថាបនា ? ព្រះបាទហស៌វរ្ម័នទី ៣ ត្រូវជាអ្វីនឹងព្រះបាទឧទយាទិត្យវរ្ម័នទី ២ ? ចូរនិយាយពីស្ថានភាពក្នុងប្រទេសព្រះអង្គ? ព្រះអង្គបានធ្វើចំបាំងនឹងប្រទេសណាខ្លះ ? នៅក្នុងរជ្ជកាល មានព្រឹត្តិការណ៍អ្វី?

* * *

## ១០– ចម្បាំងគ្នាឯងនៅចុងសតវត្សទី១១

### «ព្រះបាទសូរ្យវរ្ម័នទី ២»

**ព្រះបាទនិបទិន្ទ្រវរ្ម័ន (១០៨០-១១១៣) និងព្រះបាទជ័យវរ្ម័នទី ៦ (១០៨០-១១០៧)** :— *នៅឆ្នាំ ១០៨០ គឺនៅពេលដែលអភិជនមួយ*

រូបនៅមហិធរបុរៈ បានប្រកាសខ្លួនជាព្រះមហាក្សត្រនៃកម្ពុជាដែរ ក្នុងព្រះនាមព្រះបាទជ័យវរ្ម័នទី ៦ នោះព្រះបាទហសិវរ្ម័នទី ៣ ស្រាប់តែបាត់ព្រះអង្គទៅ ហើយព្រះរាជបល្ល័ង្កក៏បានមកព្រះបាទន្រិបទិន្ទ្រវរ្ម័នដែលសោយរាជ្យគង់នៅអង្គរ ។

ព្រះបាទជ័យវរ្ម័នទី ៦ ព្រះអង្គទ្រង់លើកទ័ពមកច្បាំងនឹងព្រះបាទន្រិបទិន្ទ្រវរ្ម័ន ។ រហូតដល់ព្រះអង្គទ្រង់ទិវង្គតទៅ នៅឆ្នាំ ១១០៧ ព្រះបាទជ័យវរ្ម័នទី ៦ ព្រះអង្គទ្រង់យកបានតែភូមិភាគខាងជើងនិងខាងកើតៗ ក្នុងដំបន់ដទៃទៀតមានដំបន់អង្គរជាដើម ប្រជារាស្ត្រនៅរក្សាសា្មមីភក្តិចំពោះព្រះបាទន្រិបទិន្ទ្រវរ្ម័ន ។

**ស្នាព្រះហស្តព្រះបាទជ័យវរ្ម័នទី ៦** :—ព្រះអង្គបានសាងប្រាសាទ បឹងមាលា ប្រាសាទនៅព្រះវិហារ នៅភីម៉ាយ និងនៅវត្តភូ ។

**ព្រះបាទន្រិបទិន្ទ្រវរ្ម័ន និងព្រះបាទធរណិន្ទ្រវរ្ម័នទី ១ (១១០៧-១១១២)និងព្រះបាទសុរ្យវរ្ម័នទី ២ (១១១៣-១១៥០)** :— លុះព្រះបាទជ័យវរ្ម័នទី ៦ទ្រង់ទិវង្គតទៅ នៅឆ្នាំ ១១០៧ ព្រះជេដ្ឋាព្រះអង្គទ្រង់ឡើងគ្រងរាជ្យបន្តមកទៀត ហើយទ្រង់ព្រះនាមថា ព្រះបាទធរណិន្ទ្រទី ១ ។ ព្រះបាទធរណិន្ទ្រទី ១ ព្រះអង្គត្រូវជាគូប្រជែងរាជ្យនឹងព្រះបាទន្រិបទិន្ទ្រវរ្ម័នផង និងព្រះរាជនត្តាព្រះអង្គដែលជាអនាគតព្រះបាទសុរ្យវរ្ម័នទី ២ ផង ។

ចម្បាំងរវាងព្រះបាទសុរ្យវរ្ម័នទី ២ និងព្រះបាទធរណិន្ទ្រវរ្ម័នខ្ទាំងគ្នា

ណាស់ ។ នៅទីបំផុត គឺនៅឆ្នាំ ១១១៣ ព្រះបាទសុរ្យវរ្ម័នទី ២ ទ្រង់បានធ្វើគតព្រះបាទធរណិន្ទ្រវរ្ម័នបាន ហើយទ្រង់ឡើងគ្រងរាជ្យបន្តមក ។ បន្ទាប់មកព្រះអង្គមកច្បាំងនឹងព្រះបាទន្ឫបតិន្ទ្រវរ្ម័ន ហើយទ្រង់បានធ្វើគតព្រះអង្គទៀត ។ នៅក្រោមការគ្រប់គ្រងរបស់ព្រះអង្គ តាំងពីពេលនោះមក កម្ពុជាបានឯកភាពឡើងវិញ ។

**ស្នាព្រះហស្តព្រះបាទសុរ្យវរ្ម័នទី ២ :—**

— ចម្បាំងនឹងប្រទេសជិតខាង ។ ព្រះអង្គជាស្ដេចសឹកមួយអង្គយ៉ាងឆ្នើម ។ ព្រះអង្គទ្រង់ធ្វើសង្គ្រាមជាមួយនឹងចាម ជាមួយនឹងយួន ជាមួយនឹងសៀម ហើយនឹងជាមួយមន ។ ដល់ព្រះអង្គសោយទីវង្គតទៅ ព្រះរាជាណាចក្រខាងជើងទល់នឹងចិន ខាងត្បូងទល់នឹងសមុទ្រ ខាងលិចទល់នឹងភូមា ខាងកើតទល់នឹងចំប៉ា ។



ប្រាសាទ អង្គរវត្ត

*— ការស្ថាបនា ។ ព្រះអង្គទ្រង់កាន់លទ្ធិវិស្ណុ ។ ព្រះអង្គបានសាង អង្គរវត្ត សម្រាប់ជាទីគោរពបូជាដល់ព្រះវិស្ណុ និងសម្រាប់បញ្ចុះព្រះអដ្ឋិធាតុព្រះអង្គផង ។ ក្រៅពីនេះ ព្រះអង្គបានសាងប្រាសាទនៅភ្នំជីសូរ ភ្នំសណ្ដាក ព្រះវិហារវត្តភូ បឹងមាលា ប្រាសាទព្រះខ័ន (ខាងកំពង់ស្វាយ) ។*

**ចំណុចសំគាល់ :—** *ព្រះបាទទ្រិបទិន្ទ្រវរ្ម័ន ជាព្រះរាជាសោយរាជ្យក្រោយបង្អស់ក្នុងសន្តតិវង្សព្រះបាទសុរ្យវរ្ម័នទី ១ ។ ព្រះបាទជ័យវរ្ម័នទី៦ ព្រះបាទធរណិន្ទ្រវរ្ម័នទី ១ ព្រះបាទសុរ្យវរ្ម័នទី ២ និងព្រះរាជាតៗទៅ ទៀត ជាក្សត្រក្នុងសន្តតិវង្សថ្មី ។ ទៀត គឺសន្តតិវង្សនៃមហិធរបុរៈ ។*

—oOo—

**សេចក្ដីសង្ខេប :—** នៅឆ្នាំ ១០៨០ ប្រទេសកម្ពុជាចែកជាពីរ ។ នៅអង្គរមានព្រះមហាក្សត្រមួយព្រះអង្គព្រះនាមហស៍វរ្ម័នទី ៣ ។ នៅឯមហិធរបុរៈ (ភូមិភាគ**ខាងជើងនៃ**កម្ពុជា) មានព្រះមហាក្សត្រមួយអង្គទៀតព្រះនាមព្រះបាទជ័យវរ្ម័នទី ៦ ។ ព្រះរាជា**ទាំង**ពីរព្រះអង្គចេះតែច្បាំងនឹងគ្នា ។ លុះព្រះបាទហស៍វរ្ម័នទី ៣ បាត់ព្រះអង្គទៅ ព្រះបាទទ្រិបទិន្ទ្រវរ្ម័នក៏សោយរាជ្យបន្តនៅអង្គរ ។ នៅឆ្នាំ ១១០៧ ព្រះបាទជ័យវរ្ម័នទី ៦ ទ្រង់ចូលទីវង្គតទៅ ។ ព្រះបាទធរណិន្ទ្រវរ្ម័នទី ១ បានសោយរាជ្យបន្តមកទៀតនៅមហិធរបុរៈ ។ ព្រះបាទធរណិន្ទ្រវរ្ម័នទី ១ ព្រះអង្គត្រូវទប់ទល់នឹងព្រះបាទទ្រិបទិន្ទ្រវរ្ម័នហើយនឹងព្រះរាជនត្តាព្រះអង្គ ។ នៅទីបំផុតព្រះរាជនត្តាព្រះបាទធរណិន្ទ្រវរ្ម័នទី ១ នេះ បានធ្វើគតព្រះអង្គ ព្រមទាំងព្រះបាទទ្រិបទិន្ទ្រវរ្ម័ន ហើយទ្រង់ឡើងគ្រងរាជ្យ ក្នុងព្រះនាមព្រះបាទសុរ្យវរ្ម័នទី ២ ។ ព្រះបាទសុរ្យវរ្ម័នទី ២ ព្រះអង្គបានធ្វើប្រទេសកម្ពុជាឲ្យរួបរួមតែមួយវិញ ។ ព្រះអង្គជាស្ដេចសឹកមួយព្រះអង្គយ៉ាងឆ្នើម ។

ព្រះអង្គបានធ្វើសង្គ្រាមនឹងចាម យួន សៀមនិងមន ។ នៅចុងរជ្ជកាលព្រះអង្គ កម្ពុជាមានព្រំប្រទល់ទល់នឹងចំប៉ា ចិន ភូមា និងសមុទ្រចិន ។ ព្រះអង្គបានសាងប្រាសាទអង្គរវត្តនិងប្រាសាទឯទៀតជាច្រើន ។

**សំណួរ:–** កាលដែលព្រះបាទជ័យវរ្ម័នទី ៦ប្រកាសជាមហាក្សត្រ ព្រះរាជាអង្គណាគង់នៅឯអង្គរ ? ព្រះបាទជ័យវរ្ម័នទី ៦ ច្បាំងយកភូមិភាគណាខ្លះ ? ព្រះរាជាអង្គណាដែលសោយរាជ្យបន្តពីព្រះអង្គ ? ព្រះបាទធរណិន្ទ្រវរ្ម័នទី ១ ព្រះអង្គជាគូប្រជែងនឹងព្រះរាជាអង្គណា? ព្រះបាទសុរ្យវរ្ម័នទី ២ ត្រូវជាអ្វីនឹងព្រះអង្គ? ទីបំផុតនៃការប្រជែងនោះយ៉ាងម្ដេច? ព្រះបាទសុរ្យវរ្ម័នបានធ្វើចម្បាំងនឹងជាតិណាខ្លះ ? ព្រះអង្គបានពង្រីកព្រំដែនដល់ណា? ព្រះអង្គបានសាងប្រាសាទណាខ្លះ?

* * *

## ១១– ចម្បាំងនឹងចាម

**ប្រទេសចំប៉ា :–** *ជនជាតិចាមបានមកតាំងនៅឆ្នេរខាងកើតនៃជ្រោយឥណ្ឌូចិន ( វៀតណាមកណ្ដាល ) រវាងខាងដើមនៃគ្រិស្តសករាជ ។ ប្រទេសចាមឈ្មោះចំប៉ា ។ ប្រទេសចំប៉ាក៏ដូចជាប្រទេសហ៊្វូណនដែរ សុទ្ធតែបានទទួលឥទ្ធិពលឥណ្ឌា ។*

**បុព្វហេតុនៃចម្បាំង :–** *មានប្រជាជនកាន់តែកុះករឡើង ជនជាតិចាមស្ថិតនៅក្នុងការចាំបាច់មួយត្រូវឲ្យពង្រីកទឹកដី ។ ឡើងទៅខាងជើងមិនរួចទើសនឹងយួនដែលចង់តែរុលចុះមកខាងត្បូងដែរ ចាមងាកមកខាង*

ត្បូងវកដីខ្មែរវិញ ៗ



ប្រាសាទចាមនៅគីញង

**(ដកស្រង់ពីភូមិសាស្ត្រនៃប្រទេសឥណ្ឌូចិន របស់លោកប៊ូអូលនិងលោករ៉ុហ្សូរិយោ)**

ពួកចាមដែលចេញមកពាតត្បូងខ្មែរ ជួនកាលមានរបៀបជាចោរ ជួនកាលក៏មានរបៀបជាក្បួនទ័ពត្រឹមត្រូវ ៗ ដូច្នេះទើបចំបាំងរវាងខ្មែរនឹងចាមបានកើតឡើងជាញឹកញយណាស់ ៗ ដូចជានៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ២ (៨០២-៨៥០) ព្រះបាទយសោវរ្ម័ន (៨៨៩-៩០០) ព្រះបាទរាជេន្ទ្រវរ្ម័នទី២ (៩៤៤-៩៦៨) ព្រះបាទពោសិវរ្ម័ន




ផែនទីប្រទេសចំប៉ា

ទី៣(១០៦៦-១០៨០) ព្រះមហាក្សត្រខ្មែរ បានកំចាត់ទ័ពចាម ដែលបានចង់មកយាយីខ្មែរ ឲ្យខ្ចាត់ខ្ចាយរត់ទៅវិញ ។

**មហាចម្បាំង :—** តែចម្បាំងដែលមានសភាពខ្លាំងក្លាទាំង មានពេលវេលាយូរគឺសង្គ្រាមក្នុងរជ្ជកាលព្រះបាទ សុរ្យវរ្ម័នទី២ (១១១៣-១១៥០) ដែលរាលដាល រហូតដល់ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (១១៨១-១២១៨) ។

**ចម្បាំងក្នុងរជ្ជកាលព្រះបាទសុរ្យវរ្ម័នទី ២ :—** ក្នុងរជ្ជកាលព្រះអង្គ មានចម្បាំងពីរលើក ។

**លើកទី១ :—** នៅគ្រាដែលកម្ពុជា កំពុងមានកើតវឹកវរបែកបាក់គ្នា ចាមបានឆ្លៀតល្បង មកតាំងនៅនាតំបន់ដីសណ្តនៃទន្លេមេគង្គ រួចប៉ុន

យកវត្ថុមានដំឡៃពីប្រាសាទនានា ។ កាលព្រះបាទសុរ្យវរ្ម័នទី ២ ; បានឡើងគ្រងរាជ្យនៅឆ្នាំ ១១២៣ ព្រះអង្គបានដេញកំចាត់ចាម រហូតដល់ពួកទាំងនេះរត់ទៅជ្រកនៅប្រទេសយួន ។ លុះព្រះអង្គទ្រង់ឃើញថា យួនហ៊ានជួយយកអាសារចាម ព្រះអង្គក៏វាយយួនថែមទៀត ។ នៅឆ្នាំ ១១៣១ ព្រះអង្គបង្ខំចាមឲ្យចូលនឹងខ្មែរ ដើម្បីវាយយួន ។

**ភគទី ២ :–** លុះដល់ឆ្នាំ ១១៣៦ ស្ដេចចាម ដោយឃើញព្រះបាទសុរ្យ-វរ្ម័នទី ២ ព្រះអង្គមិនអាចយកជ័យលើយួនបាន ចាមក៏ដកដៃសហពល-កម្មពីខ្មែរ ហើយត្រឡប់ជាព្រមធ្វើសមគ្គពជយួនវិញ ។

ដោយទ្រង់ក្រោធនឹងអាកប្បកិរិយាប្រែប្រួលរបស់ចាម នៅឆ្នាំ១១៤៥ ជាកិច្ចសងសឹក ព្រះអង្គទ្រង់វាយលុកប្រទេសចំប៉ា យកបានក្រុងវិជ័យ និងប្រទេសចាមទាំងមូល ។ នៅឆ្នាំ ១១៤៧ ព្រះអង្គបានតាំងព្រះរាជាខ្មែរមួយព្រះអង្គព្រះនាម ហារិទេវៈ ឲ្យគ្រងរាជ្យនៅចំប៉ា ។ ធ្វើទេសានុពន្ធន៍នេះបានតែ៤ឆ្នាំ ពួកចាមនៅភាគខាងត្បូង បាននាំគ្នាបះបោរប្រឆាំងឡើង ព្រមទាំងបានធ្វើគតព្រះបាទ ហារិទេវៈផង ។ ហើយព្រះបាទសុរ្យវរ្ម័នទី២ព្រះអង្គក៏ទ្រង់សោយទីវង្គតក្នុងចន្លោះពេលនោះដែរ(មិនប្រាកដឆ្នាំ)។

—oOo—

**សេចក្ដីសង្ខេប:–** ជនជាតិចាមមានប្រទេសឈ្មោះ ចំប៉ាស្ថិតនៅភាគខាងកើតនៃជ្រោយឥណ្ឌូចិនជាប់នឹងឆ្នេរសមុទ្រ ។ លុះជនជាតិនេះមានបណ្ដាជនកាន់តែកុះករឡើង កិច្ចចាំបាច់ដើម្បីរស់បានបង្ខំចាមឲ្យល្បងចំប្លាងយកកម្ពុជាភាគខាងត្បូង ។ ចំបាំងនឹងចាមមានតាំងពីរជ្ជកាលព្រះបាទជ័យវរ្ម័នទី ២ ។ តែចំបាំងធំគឺចំបាំងក្នុងរជ្ជកាលព្រះបាទសុរ្យវរ្ម័នទី២ដែលអាលផាលរហូតដល់រជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ។

នៅក្នុងឆ្នាំ ១១២៣ ព្រះបាទសុរ្យវរ្ម័នទី ២ បានដេញវាយចាមដែលបានមកឈ្លានពាន ឲ្យខ្ចាត់រហូតទៅជ្រកនៅប្រទេសយួន ។ ហើយដោយទ្រង់ជ្រាបថា យួនបានជួយយកអាសារចាម ព្រះអង្គបានវាយនឹងយួនថែមទៀត ដោយបង្ខំទាំងចាមឲ្យចូលធ្វើសហាពលកម្មជាមួយខ្មែរផង ។

នៅឆ្នាំ ១១៤៥ គឺនៅពេលដែលចាម ទៅចូលដៃនឹងយួន ព្រះអង្គក៏វាយចាមមួយលើកទៀត វាយរហូតយកប្រទេសចាមបាន ហើយបានទាំងដាក់ព្រះរាជាខ្មែរមួយអង្គឲ្យគ្រងរាជ្យនៅចំប៉ាផង ។ បានតែ៥ឆ្នាំ ចាមបះក៏ធ្វើគតព្រះរាជាខ្មែរទៅ ។ ហើយនៅចន្លោះកាលនោះឯង ព្រះបាទសុរ្យវរ្ម័នទី២ ក៏ទ្រង់សុគតដែរ ។

**សំណួរ:–** ប្រទេសចាមឈ្មោះអ្វី ? ស្ថិតនៅឯណា ? ហេតុអ្វីបានជាចាមនិងខ្មែរចំប្លាងគ្នាយ៉ាងម៉េះ ? ចម្បាំងរវាងខ្មែរនិងចាមកើតមានឡើងក្នុងរជ្ជកាលព្រះរាជាណាខ្លះ ? ព្រះបាទសុរ្យវរ្ម័នទី ២ ចំប្លាងនឹងចាមពីរលើក ហេតុអ្វី? ក្នុងមួយលើកបានលទ្ធផលយ៉ាងម្ដេច? ហេតុអ្វីបានជាព្រះអង្គចំប្លាងនឹងយួនដែរ ?

* * *

## ១២– ចម្បាំងនឹងចាម « ក »

ចម្បាំងក្នុងរជ្ជកាលព្រះបាទធរណិន្ទ្រវរ្ម័នទី ២ (១១៥០ - ១១៦០) និង

**…រជ្ជកាលព្រះបាទយសោវរ្ម័នទី ២ (១១៦០-១១៦៥):–** ព្រះបាទធរណីន្ទ្រវរ្ម័នទី២ ព្រះអង្គត្រូវជាព្រះអនុជរួមព្រះអយ្យិកានឹងព្រះបាទសូរ្យវរ្ម័នទី២ ។ ក្នុងរជ្ជកាលព្រះអង្គ ចម្បាំងនឹងចាមចេះតែមានបន្តមកទៀត ។ ព្រះរាជបុត្រព្រះអង្គ ( អនាគតព្រះបាទជ័យវរ្ម័នទី ៧ ) បានយាងទៅធ្វើចម្បាំងនេះរហូតដល់ក្រុងវិជ័យ ។ មកដល់ឆ្នាំ ១១៦០ ព្រះវរបិតាព្រះអង្គសុគតទៅ ហើយនៅពេលដែលព្រះបាទយសោវរ្ម័នទី២ ( ក្សត្រមួយអង្គក្នុងព្រះរាជវង្ស ) ឡើងគ្រងរាជ្យទៀត ក៏ព្រះអង្គ នៅតែជាប់ធ្វើចម្បាំងនៅឯចំប៉ា ។ លុះដល់ឆ្នាំ ១១៦៥ គឺឆ្នាំដែលព្រះបាទយសោវរ្ម័នទី ២ ត្រូវមន្ត្រីម្នាក់ធ្វើឃាត ដើម្បីយករាជ្យ ទើបព្រះអង្គយាងត្រឡប់មកវិញ ។

**…ប្រាំងក្នុងរជ្ជកាលព្រះបាទត្រីភូវនាទិត្យវរ្ម័ន (១១៦៥-១១៧៧) : –** មន្ត្រីដែលបានធ្វើឃាតព្រះបាទយសោវរ្ម័នទី ២ បានឡើងគ្រងរាជ្យហើយទ្រង់ព្រះនាម ព្រះបាទត្រីភូវនាទិត្យវរ្ម័ន ។ ឯចម្បាំងនឹងចាមក៏ចេះតែមានមកទៀត ។ តែមកដល់ឆ្នាំ ១១៧៧ ចាមបានលើកទ័ពមកតាមទន្លេមេគង្គ ចូលដល់បឹងទន្លេសាប ។ ក្នុងពេលនោះ ចាមយកបានអង្គរ ហើយបានទាំងធ្វើឃាត ព្រះបាទត្រីភូវនាទិត្យវរ្ម័នផង ។ ចាមបានត្រួតត្រានៅអង្គរអស់ថេរវេលាប្រមាណ ៤ ឆ្នាំ ។ បរាជ័យនេះនាំឲ្យសាបសូន្យអស់នូវអានុភាពខ្មែរ ។

**ចម្បាំងក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ (១១៨១-១២១៨) មុនព្រះអង្គឡើងគ្រងរាជ្យ ) :–** *ក្នុងរជ្ជកាលព្រះបាទ ត្រីភូវនាទិត្យវរ្ម័ន ព្រះអង្គ (គឺអនាគតព្រះបាទជ័យវរ្ម័នទី ៧ ) មិនធ្វើសកម្មភាពអ្វីទាំងអស់ ។ លុះព្រះបាទត្រីភូវនាទិត្យវរ្ម័នសុគតទៅ ទើបព្រះអង្គប្រមូលទ័ពចំប្បាំងតស៊ូនឹងចាមរហូតដល់មានជ័យជំនះ ដោយកំចាត់ចាមចេញពីកម្ពុជា នៅឆ្នាំ ១១៨១ៗ គឺនៅឆ្នាំនោះដែលព្រះអង្គឡើងគ្រងរាជ្យ ហើយទ្រង់ព្រះនាមថា*



ចម្លាក់នៅបាយ័ន : ចម្បាំងនឹងចាម

នាមថា ព្រះបាទជ័យវរ្ម័នទី ៧ ។

ក្នុងរជ្ជកាលព្រះអង្គ ដប់ឆ្នាំក្រោយមក គឺនៅឆ្នាំ ១១៩០ ចាមបានលើកទ័ពមកវាយខ្មែរម្តងទៀត ។ តែព្រះបាទជ័យវរ្ម័នទី ៧ ព្រះអង្គបានតបតវិញយ៉ាងខ្លាំងអស្ចារ្យ ចូលដល់រាជធានី ព្រះអង្គយកចំប៉ាបានទាំងមូល ។ ព្រះអង្គបានដាក់ព្រះរាជវាខ្មែរមួយព្រះអង្គ ឲ្យគ្រប់គ្រងរាជ្យនៅក្រុងវិជ័យ និងខេត្តជិតខាងទាំងប៉ុន្មាន ។ ចំណែកខេត្តដទៃ ព្រះអង្គប្រគល់ឲ្យក្សត្រចាមមួយអង្គ ដែលធ្លាប់រស់នៅរាជធានីអង្គរ និងធ្លាប់យកអាសារព្រះអង្គ ឲ្យគ្រប់គ្រង ។ លុះដល់ឆ្នាំ ១២០៣ ក្សត្រចាមអង្គនោះមាននិន្នាការចង់បង្រួបបង្រួមចាមឡើងវិញ ហើយលែងស្តាប់បង្គាប់ខ្មែរ ព្រះអង្គក៏ដេញក្សត្រចាមនោះចេញ។ ពីឆ្នាំ ១២០៣ ដល់ឆ្នាំ ១២២៦ (១) ប្រទេសចំប៉ាបានធ្លាក់ជាខេត្តមួយនៃកម្ពុជា ។ តាំងពីនោះមកចាមឈប់ឈ្លានពានទឹកដីខ្មែរទៀត ។

-- oOo --

**សេចក្តីសង្ខេប : — ក្នុងរជ្ជកាលព្រះបាទធរណិន្ទ្រវរ្ម័នទី២ (១១៥០-១១៦០)និងក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី២ (១១៦០-១១៦៥) ចំបាំងនឹងចាមបានប្រព្រឹត្តទៅនៅក្នុងប្រទេសចាម ។ កងទ័ពខ្មែរត្រូវបានដឹកនាំដោយព្រះរាជបុត្រព្រះបាទធរណិន្ទ្រវរ្ម័នទី២ ដែលជាអនាគតព្រះបាទជ័យវរ្ម័នទី៧។លុះដល់ព្រះបាទត្រីភុវនាទិត្យវរ្ម័ន (១១៦៥-១១៧៧) ឡើងគ្រងរាជ្យដោយធ្វើឃាតព្រះបាទយសោវរ្ម័នទី២ ទើបព្រះអង្គទ្រង់យាងត្រឡប់មកកម្ពុជាវិញ ។**

(១)– តាមអ្នកស្រី ហ្សីតូ ថានៅឆ្នាំ ១២២០ ។

មកដល់ឆ្នាំ ១១៧៧ ចាមមកតាមទន្លេ វាយយកអង្គរ និងធ្វើឃាតព្រះបាទត្រីភុវនាទិត្យវរ្ម័នផង ។ ប្រាំឆ្នាំក្រោយមក ព្រះអង្គម្ចាស់រនោគតព្រះបាទជ័យវរ្ម័នទី ៧ ព្រះអង្គក៏បានកំចាត់ចាមឲ្យអស់ពីប្រទេសទៅវិញ ។ នៅឆ្នាំ ១១៨១ ទើបព្រះអង្គឡើងសោយរាជ្យជា ព្រះបាទជ័យវរ្ម័នទី ៧ ។

នៅឆ្នាំ ១១៩០ ចាមលើកទ័ពមកសងសឹកវិញ តែព្រះបាទជ័យវរ្ម័នទី ៧ បានតបវិញយ៉ាងខ្លាំងអស្ចារ្យ ។ ព្រះអង្គបានលើកទ័ពចូលដល់ក្រុងវិជ័យ ហើយយកចំប៉ាបាន ។

**សំណួរ** : – ក្នុងរជ្ជកាលព្រះបាទធរណិន្ទ្រវរ្ម័នទី ២ និងព្រះបាទយសោវរ្ម័នទី ២ ចម្បាំងនឹងចាមប្រព្រឹត្តទៅនៅឯណា ? អ្នកណាជាអ្នកដឹកនាំសង្គ្រាមនោះ ? ត្រូវជាអ្វីនឹងព្រះបាទធរណិន្ទ្រវរ្ម័នទី ២ ? ចាមវាយយកអង្គរបាននៅឆ្នាំណា? ក្នុងរាជ្យស្ដេចណា ដែលបានកំចាត់ចាមទៅវិញ ?នៅឆ្នាំ ១១៩០ ការសងសឹករបស់ចាមបានលទ្ធផលយ៉ាងណា ចូរបង្ហាញនូវគុណសម្បត្តិនៃព្រះបាទជ័យវរ្ម័នទី ៧ ?

* * *

## ១៣– ព្រះបាទជ័យវរ្ម័នទី ៧ (១១៨១-១២០១)

*ព្រះបាទជ័យវរ្ម័នទី ៧ មិនត្រឹមតែជាព្រះមហាក្សត្រខ្លាំងពូកែខាងសឹកសង្គ្រាមប៉ុណ្ណោះទេ ទ្រង់ប្រសប់គ្រប់គ្រងផែនដីណាស់ទៀតផង ទ្រង់បានប្រាថ្នាឲ្យរៀបច្បាប់គ្រប់តំណែង សំរាប់ព្រះនគរឲ្យបានចំរើនឡើង ហើយទ្រង់ឲ្យសាងគិលានដ្ឋាន នូវមន្ទីរព្យាបាលរោគជាច្រើនផងក្នុងព្រះរាជនគរ ។ នៅក្នុងរាជ្យព្រះអង្គ ប្រទេសកម្ពុជាយើងមានទំហំដីធំទូលាយណាស់ គឺរាប់តាំងប្រទេសកម្ពុជាសព្វថ្ងៃ ជាមួយនឹងប្រទេស*



ព្រះបាទជ័យវរ្ម័ន ទី ៧

ចំប៉ា ប្រទេសលាវ ប្រទេសសៀម ភាគមួយចំណែកនៃជ្រោយម៉ាឡាយូ និងភាគមួយចំណែកទៀតនៃប្រទេសភូមា ។

**ព្រះរាជប្រវត្តិសង្ខេបនៃព្រះអង្គ:—**

ព្រះបាទជ័យវរ្ម័ន ទី៧ ជាព្រះរាជបុត្រព្រះបាទ ធរណិន្ទ្រវរ្ម័ន ទី ២ ។ ព្រះវររាជមាតាទ្រង់ព្រះនាម ចូឌាមណី ។

បន្ទាប់ពីព្រះអគ្គទេពីប្រសូត្របានរាជបុត្រមួយព្រះអង្គមក ទ្រង់ក៏បានយាងចាកចេញទៅកាន់ប្រទេសចំប៉ាអស់រយៈពេលជាច្រើនឆ្នាំ ទុកព្រះអគ្គទេពីឲ្យមានទុក្ខជាទម្ងន់ ។ គ្រាក្រោយមក ព្រះនាងបានរម្ងាប់សេចក្ដីសោកសង្រេងសង្រែ ក្នុងការប្រតិបត្តិព្រះធម៌នៃព្រះពុទ្ធសាសនា។ នៅពេលក្រោយមកទៀត ពេលព្រះបាទជ័យវរ្ម័នត្រឡប់ចូលមកកាន់ព្រះនគរវិញ ព្រះនាងបានចាកចេញពីសិក្ខាបទ ហើយរួមរស់ជាមួយព្រះស្វាមីឡើងវិញ ។ គ្រាក្រោយមកទៀត បន្ទាប់ពីព្រះបាទជ័យវរ្ម័ន ទី ៧ បានរំដោះប្រទេសឲ្យផុតចេញពីការត្រួតត្រាបះបោរ ព្រះអគ្គទ្រង់បាន

ឡើងសោយរាជ្យ ហើយបានពង្រីកទឹកដីមហានគរ ឲ្យរីកធំទូលាយជាទីគ្រាណាតាំងអស់ ។ នៅពេលជាមួយគ្នានោះ ព្រះអគ្គទេពីទ្រង់សោយទីវង្គត ទើបព្រះបាទជ័យវរ្ម័នលើកព្រះនាងឥន្ទ្រទេវី ដែលជាព្រះរៀមនៃព្រះអគ្គទេពីមុន ជាព្រះអគ្គមហេសីឡើង ។

**ព្រះនាងឥន្ទ្រទេវី** :— ព្រះនាងឥន្ទ្រទេវី មានតម្រេះវិជ្ជាខ្ពង់ខ្ពស់ខាងវិជ្ជាសាស្ត្រនិងខាងបរមត្ថ ។ ទ្រង់សព្វព្រះរាជហឫទ័យនឹងការគោរពប្រតិបត្តិខាងផ្លូវព្រះពុទ្ធសាសនាណាស់ ។ ព្រះនាងបានផ្សាយសេចក្ដីមេត្តាចំពោះស្រី ៗណា ដែលចូលចិត្តសិក្សាវិទ្យាសាស្ត្រ ។

—oOo

**សេចក្ដីសង្ខេប**:— ព្រះបាទជ័យវរ្ម័នទី ៧ ព្រះអង្គមិនគ្រាន់ជាតែព្រះមហាក្សត្រមួយអង្គខ្លាំងពូកែខាងសឹកសង្គ្រាម និងពង្រីកទឹកដីប៉ុណ្ណោះទេ ព្រះអង្គទ្រង់ប្រសប់គ្រប់គ្រងផែនដីណាស់ ។ ក្នុងរាជ្យព្រះអង្គ ប្រទេសជាតិមានការចំរើនរុងរឿងក្រៃលែង ។

ព្រះបាទជ័យវរ្ម័នទី ៧ ជាព្រះរាជបុត្រព្រះបាទធរណិន្ទ្រវរ្ម័នទី ២ ។ ព្រះវររាជមាតាព្រះនាម ចូឌាមណី ។ បន្ទាប់ពីព្រះអគ្គទេពីប្រសូត្របានរាជបុត្រមួយព្រះអង្គមក ទ្រង់ក៏យាងចាកចេញទៅធ្វើសង្គ្រាមនៅចំប៉ា ទុកព្រះអគ្គទេពីឲ្យមានទុក្ខជាទម្ងន់ដោយការនឹករលឹកព្រះអង្គ ។ ប៉ុន្តែព្រះនាងទ្រង់បានរម្ងាប់ទុក្ខនេះបាន ដោយការកាន់គោរពព្រះធម៌ព្រះពុទ្ធ ។

ព្រះបាទជ័យវរ្ម័នទី៧ ទ្រង់ឡើងគ្រងរាជ្យ ក្រោយពេលដែលព្រះអង្គទ្រង់បានកំចាត់ចាមដែលមកលុកលុយកម្ពុជាយើង។ តមក ព្រះអង្គទ្រង់បានពង្រីកទឹកដីយ៉ាងធំទូលាយ

ជាងគ្រាណាទាំងអស់ ។

ក្រោយមកទៀត ព្រះទេពីទ្រង់សោយទីវង្គត ។ ព្រះអង្គទ្រង់លើកព្រះនាងឥន្ទ្រទេវី ដែលត្រូវជាព្រះរៀមព្រះអគ្គទេពីមុន ជាព្រះអគ្គមហេសី ។ ព្រះនាងឥន្ទ្រទេវីមានតប្រេះ ខ្ពង់ខ្ពស់ណាស់ខាងវិទ្យាសាស្ត្រនិងខាងធម៌អាថ៌ព្រះពុទ្ធ ។

**សំណួរៈ**—ព្រះបាទជ័យវរ្ម័នទី ៧ ជាព្រះរាជបុត្រស្តេចអង្គណា? ព្រះមាតាព្រះអង្គព្រះនាមអ្វី? —ហេតុអ្វីបានជាព្រះអង្គយាងទៅប្រទេសចាម? —មុនព្រះអង្គទ្រង់ឡើងគ្រងរាជ្យ មានព្រឹត្តិការណ៍អ្វីសំខាន់? —ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័ន ទី ៧ ផែនដីកម្ពុជាយើងយ៉ាងម្តេច ? —ព្រះនាងឥន្ទ្រទេវី ជាអ្នកណា?

* * *

## ១៤- ព្រះបាទជ័យវរ្ម័នទី៧ ជាស្តេចសឹក

*ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី ៧ ចម្បាំងមានកើតឡើងជាញឹកញាប់ ជាមួយនឹងប្រទេសចំប៉ា ។ ដោយសារការវៀងវៃរបស់ព្រះអង្គ ក្នុងផ្លូវយុទ្ធសាស្ត្រ ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់បានទទួលជ័យជំនះជាស្ថាពរលើប្រទេសចំប៉ា ហើយបានបង្ក្រាបការបះបោរ ដែលកើតមានឡើងក្នុងព្រះនគរទៀតផង ។*

**អំពីព្រឹត្តិការណ៍មុនចម្បាំងនឹងចាមៈ—** *ក្នុងរយៈពេលដែលព្រះអង្គគង់នៅប្រទេសចំប៉ា ក្នុងប្រទេសកម្ពុជា ព្រះវររាជបិតាទ្រង់សោយទីវង្គត។ ពេលនោះមានស្តេចមួយព្រះអង្គព្រះនាម យសោវរ្ម័នទី ២ បានឡើង*

សោយរាជសម្បត្តិជាបន្តមក ។ ក្នុងរជ្ជកាលស្តេចថ្មីនេះ មានការបះបោរពីរបានកើតឡើង គឺបះបោរទីមួយ បណ្តាលមកអំពីអ្នកខ្លាំងពូកែម្នាក់តាំងខ្លួនជារាហ៊ូ មានគំនិតក្បត់ព្រះចៅយសោវរ្ម័នទី ២ ដើម្បីដណ្តើមយកព្រះបល្ល័ង្ករាជ្យ ។ ការប្រយុទ្ធរៀបតែនឹងចាញ់ដៃរាហ៊ូទៅហើយ ស្រាប់តែព្រះរាជកុមារជាព្រះរាជបុត្រព្រះបាទជ័យវរ្ម័នទី ៧ សម្លាប់រាហ៊ូបានហើយជួយការពារព្រះចៅឲ្យរួចផុតពីសេចក្តីអន្តរាយ ។

ការបះបោរទីពីរ បណ្តាលមកពីមានមន្ត្រីក្បត់ម្នាក់បានដណ្តើមរាជ-បល្ល័ង្ក ហើយតាំងខ្លួនជាស្តេច ព្រះនាមថា ព្រះបាទត្រីភូវនាទិត្យក្នុងឆ្នាំ ១១៦៥ ។

**ការវិលត្រឡប់នៃព្រះបាទជ័យវរ្ម័នទី៧** :– ដំណឹងក្បត់ព្រះបល្ល័ង្ករាជ្យនេះ បានឮស្លុះសាយទៅដល់ប្រទេសចំប៉ា ។ ព្រះជ័យវរ្ម័នទ្រង់យាងត្រឡប់មកជាប្រញាប់ ដើម្បីជួយរំដោះទុក្ខព្រះបាទយសោវរ្ម័ន ។ ប៉ុន្តែព្រះអង្គមិនបានសម្រេចព្រះបំណងឡើយ ព្រោះព្រះបាទត្រីភូវនាទិត្យបានធ្វើគតព្រះបាទយសោវរ្ម័នរួចទៅហើយ ។ ក្នុងពេលនោះព្រះជ័យវរ្ម័នទ្រង់នៅស្ងៀម មិនបញ្ចេញព្រះសកម្មភាពប្រឆាំងនឹងព្រះបាទត្រីភូវនាទិត្យទេ ។ ព្រះអង្គទ្រង់រង់ចាំឱកាសល្អ ដើម្បីនឹងកំចាត់ខ្មាំងសត្រូវឲ្យចាកចេញពីព្រះបល្ល័ង្ករាជ្យ ។

លុះដល់ឆ្នាំ ១១៧៧ នៅពេលដែលចាមចូលលុកលុយកម្ពុជា

ហើយបានធ្វើគតព្រះបាទត្រីភូវនាទិត្យវរ្ម័ន ទើបព្រះអង្គទ្រង់ចាប់ផ្ដើមធ្វើសកម្ម-ភាពនយោបាយដើម្បីស្រោចស្រង់ប្រទេសជាតិឡើងវិញ ។

* * *

**សេចក្ដីសង្ខេប** :— ចំបាំងរវាងខ្មែរនិងចាម បានរលត់ជាស្ថាពរ ដោយសារស្នាព្រះហស្ត ព្រះបាទជ័យវរ្ម័នទី ៧ ។

មុនព្រះអង្គឡើងគ្រងរាជ្យ គឺកាលព្រះអង្គគង់នៅឯចំប៉ានៅឡើយ នៅក្នុងកម្ពុជាយើងមានបះបោរពីរលើក ។ លើកទីមួយ គឺការបះបោររបស់ជនម្នាក់ ដែលតាំងខ្លួនជាពហ៊ុ ហើយចង់ដណ្ដើមបល្ល័ង្កពីព្រះបាទយសោវរ្ម័នទី២ ដែលសោយរាជ្យបន្តពីព្រះបាទធរណិន្ទ្រវរ្ម័នទី២ ។ តែពហ៊ុនោះ ត្រូវព្រះរាជបុត្រព្រះបាទជ័យវរ្ម័នទី ៧ **សម្លាប់បាន ។** ការបះបោរលើកទីពីរ បណ្ដាលមកពីមន្ត្រីម្នាក់ ដែលដណ្ដើមបល្ល័ង្ករាជ្យ ពីព្រះបាទយសោវរ្ម័នទី ២ បាន ហើយតាំងខ្លួនជាស្ដេចដោយមាននាមថា ត្រីភូវនាទិត្យវរ្ម័ន ។

លុះបានជ្រាបដំណឹងទីពីរនេះ ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់យាងត្រឡប់មកកម្ពុជាវិញ ។ ព្រះអង្គទ្រង់បានរង់ចាំឱកាស ដើម្បីកំចាត់ខ្មាំងសត្រូវឲ្យចាកចេញពីបល្ល័ង្ករាជ្យ រហូតដល់ពេលដែលចាមចូលមកលុកលុយកម្ពុជាយើង ។

**សំណួរ**: — ព្រះរាជាណា ដែលបានធ្វើឲ្យសង្គ្រាមរវាងចាមនិងខ្មែរ រលត់ជាស្ថាពរ? — កាលព្រះបាទជ័យវរ្ម័នទ្រង់គង់នៅឯចំប៉ា នៅកម្ពុជាមានព្រឹត្តិការណ៍អ្វីខ្លះ?— អ្នកណាជាអ្នកបង្កការបះបោរលើកទី១ ? ហើយអ្នកណាបានបង្ក្រាបការបះបោរនោះ ? — ការបះបោរលើកទី២ បណ្ដាលមកពីអ្នកណា? — លទ្ធផលយ៉ាងម្ដេច? — ហេតុអ្វីបានជាព្រះជ័យវរ្ម័នទ្រង់យាងមកកម្ពុជាវិញ ?

* * *

## ១៥- ព្រះបាទជ័យវរ្ម័នទី ៧ ខារស្ដេចសឹក (ក)

### « អំពីការចូលលុករបស់ចាមក្នុងប្រទេសកម្ពុជា »

មានស្ដេចចាមមួយព្រះអង្គព្រះនាមឥន្ទ្រវរ្ម័នបានបងស្ពានមេត្រីនឹងប្រទេសអណ្ណាម ហើយបានលើកទ័ពតាមជើងគោក ឆ្ពោះមកច្បាំងនឹងប្រទេសកម្ពុជា ។ ក្នុងខណៈនោះ កងទ័ពខ្មែរមានបុព្វានុភាពខ្លាំងក្លាណាស់ដែរ ទ័ពចាមក៏ដកថយវិលត្រឡប់ទៅវិញ ។

ក្នុងឆ្នាំ ១១៧៧ ស្ដេចចាមបានបាត់លើកកងទ័ពជើងទឹកមកតាមទូក សំពៅចូលមកតាមទន្លេមេគង្គ កាត់ឆ្ពោះតម្រង់រហូតដល់ទន្លេសាប។ ម្ដងនេះទ័ពចាមចូលលុកលុយមហានគរបាន ហើយក៏ធ្វើគតស្ដេចត្រីភូវនាទិត្យបោលទៅ ។ ប្រទេសកម្ពុជាក៏ឋិតនៅក្រោមការត្រួតត្រាជិះជាន់របស់ចាម ។

**ការរំដោះមាតុប្រទេសឱ្យផុតពីការជិះជាន់របស់ចាមៈ–** ព្រះបាទជ័យវរ្ម័នបានប្រមូលខេមរៈជនអ្នកស្នេហាជាតិជាច្រើននាក់ ដើម្បីបង្ករទ័ពប្រយុទ្ធតទល់នឹងសត្រូវចាម ។ ការប្រយុទ្ធនេះបានប្រព្រឹត្តទៅអស់រយៈពេល ៤ឆ្នាំ ទើបប្រទេសបានសេចក្ដីសុខក្សេមក្សាន្តឡើងវិញ ហើយព្រះបាទជ័យវរ្ម័នក៏តាំងរៀបពិធីរាជាភិសេក ដាក់ព្រះនាមជាព្រះបាទជ័យវរ្ម័ន ទី ៧ ក្នុងឆ្នាំ ១១៨១ ។

**ការបង្ក្រាបអំពើក្បត់នៅមល្យាង (ខាងត្បូងខេត្តបាត់ដំបង) :–** មាន *មនុស្សមួយក្រុម ច្រើនជាអ្នកខូចកាច នៅស្រុកមល្យាង បានធ្វើទុក្ខប្រជាពលរដ្ឋខ្មែរ ហើយចង់ប្រឆាំងនឹងព្រះចៅក្រុងកម្ពុជាផង ។ ព្រះបាទជ័យវរ្ម័នទី ៧ បានចាត់ព្រះអង្គម្ចាស់ចាមមួយព្រះអង្គ ព្រះនាមវិទ្យានន្ទន ដែលជាបុត្រចិញ្ចឹមព្រះអង្គ ឲ្យទៅបង្ក្រាបអំពើបះបោរនោះ ។ ព្រះអង្គម្ចាស់ចាម បានវាយឈ្នះពួកបះបោរ ហើយប្រទេសកម្ពុជាបានឋិតក្នុងសេចក្ដីសុខឡើងវិញ ។*

–oOo–

**សេចក្ដីសង្ខេប:–** ស្ដេចចាមព្រះនាម ជ័យឥន្ទ្រវរ្ម័ន បានលើកទ័ពមកច្បាំងនឹងកម្ពុជាយើង ។ កាលនោះទ័ពខ្មែរមានឫទ្ធានុភាពជាងទ័ពចាម ចាមក៏បានដកថយទៅវិញ ។

នៅឆ្នាំ ១១៧៧ ចាមបានលើកទ័ពមកតាមទន្លេមេគង្គ ចូលដល់ទន្លេសាប ហើយចូលលុកលុយមហានគរ ព្រមទាំងបានធ្វើគតស្ដេចត្រិភូវនាទិត្យវរ្ម័នផង ។ គឺគ្រានោះហើយ ដែលព្រះបាទជ័យវរ្ម័នបានបង្កើតទ័ពប្រយុទ្ធ តទល់កំចាត់ពួកចាមឲ្យខ្ចាត់ទៅវិញ អស់រយៈពេល៤ឆ្នាំ ទើបព្រះអង្គឡើងគ្រងរាជ្យនៅឆ្នាំ ១១៨១ ។

ក្នុងរាជ្យព្រះអង្គ មានការបះបោរមួយនៅមល្យាង (ខាងត្បូងបាត់ដំបង) ។ កាលនោះព្រះបាទជ័យវរ្ម័ន ទី ៧ ទ្រង់បានចាត់ព្រះអង្គម្ចាស់ចាមមួយព្រះអង្គ ដែលត្រូវជាបុត្រចិញ្ចឹមរបស់ព្រះអង្គ ព្រះនាមវិទ្យានន្ទនឲ្យទៅបង្ក្រាបពួកបះបោរ ។ ពួកនេះបានបាក់បបខ្លបខ្លាចស្ងប់ស្ងាត់ទៅវិញអស់ទៅ ។

**សំណួរ:–**នៅឆ្នាំ១១៧៧ ចាមលើកទ័ពមកតាមណា? ការលុកលុយរបស់ចាមនោះមានលទ្ធផលយ៉ាងម្ដេច?អ្នកណាជាអ្នកបានកំចាត់ចាមទាំងនោះទៅវិញ? ព្រះបាទជ័យវរ្ម័នទី ៧ –

សោយរាជ្យក្នុងឆ្នាំណា ? ក្នុងរាជ្យព្រះអង្គ មានការបះបោរទេ ? នៅឯណា ? អ្នកណាជាអ្នកបង្ក្រាបការបះបោរនោះ ?

* * *

## ១៦– ព្រះបាទជ័យវរ្ម័ន ទី ៧ ជាស្តេចសឹក ( ក )

### «ការសងសឹករបស់ខ្មែរទៅលើពួកចាម»

ក្នុងឆ្នាំ ១១៩០ ព្រះបាទជ័យវរ្ម័នទី ៧ បានលើករេហ៍ពលចូលទៅវាយលុកប្រទេសចំប៉ា ហើយវាយយកបានក្រុងវិជ័យ ហើយចាប់បានស្តេចចាមបញ្ជូនជាឈ្លើយមកប្រទេសកម្ពុជា ។ ព្រះអង្គបានលើកព្រះអនុជថ្លៃឲ្យគ្រងរាជ្យនៅក្រុងវិជ័យ ឯព្រះអង្គម្ចាស់ចាម ក៏យាងទៅតាំងទីក្រុងមួយថ្មីនៅទិសខាងត្បូង ។

ព្រះអង្គម្ចាស់ចាម វិទ្យានន្ទន ដែលជាបុត្រាចិញ្ចឹមព្រះបាទជ័យ-វរ្ម័ន ទី ៧ មានព្រះទ័យចង់ក្បត់ព្រះចៅប្រទេសកម្ពុជា ។ ព្រះអង្គម្ចាស់នោះបានញុះញង់ពលរដ្ឋចាមនៅក្រុងវិជ័យ ឲ្យបះបោរប្រឆាំងនឹងស្តេចខ្មែរ ដែលជាព្រះអនុជថ្លៃព្រះបាទជ័យវរ្ម័នទី ៧ ។ ស្តេចខ្មែរអង្គនេះក៏ត្រូវភៀសខ្លួនចេញពីក្រុងវិជ័យ ។ ព្រះអង្គម្ចាស់ចាម ចង់ដោះដៃពីស្តេចខ្មែរ ក៏តាំងបង្រួបបង្រួមនគរទាំងពីរឲ្យទៅតែមួយវិញ ដើម្បីកាន់កាប់តែមួយព្រះអង្គឯង ។ បន្ទាប់ពីសម្លាប់ស្តេចចាម ជ័យឥន្ទ្រវរ្ម័ន

ដែលបានរួបរួមខ្លួនពីប្រទេសកម្ពុជាទៅវិញនៅឆ្នាំ ១២០៣ ស្តេចវៀងចន្ទន៍ បានត្រូវបណ្ដេញចេញពីនគរចំប៉ា ហើយរហូតមកដល់ឆ្នាំ ១២២០ ប្រទេសចំប៉ាទុកដូចជាអាណាខេត្តមួយរបស់ប្រទេសកម្ពុជា ។

**អំពីការពង្រីកអាណាខេត្តតទៅ :—** លុះបានជ័យជំនះមែនទែនលើចាមហើយ ព្រះបាទជ័យវរ្ម័នទី៧ បានពង្រីកទឹកដីមកខាងលិចវិញទៀត ទ្រង់បង្ក្រាបជ្រោយម៉ាឡេស៊ីមួយភាគ ហើយទន្ទ្រានផ្សាយបុទ្ធានុភាពរហូតទៅដល់ប្រទេសភូមា ។




—oOo—

**សេចក្តីសង្ខេបៈ–** ដើម្បីសងសឹកនឹងចាម នៅឆ្នាំ១១៩០ ព្រះបាទជ័យវរ្ម័នទី ៧ បានលើកទ័ពចូលលុកលុយប្រទេសចំប៉ា ហើយវាយយកបានក្រុងវិជ័យ ព្រមទាំងបានចាប់ស្តេចចាមបញ្ជូនជាឈ្លើយមកកម្ពុជាផង ។ ព្រះអង្គទ្រង់បានលើកព្រះអនុជថ្លៃមួយអង្គឲ្យគ្រងរាជ្យនៅក្រុងវិជ័យនោះ ។ ឯព្រះអង្គម្ចាស់ចាមព្រះនាមវិទ្យានន្ទន ព្រះអង្គទ្រង់ចាត់ឲ្យគ្រប់គ្រងភាគខាងត្បូង ។

ក្រោយមកព្រះអង្គម្ចាស់វិទ្យានន្ទន មានព្រះទ័យក្បត់នឹងខ្មែរ ហើយបានញុះញង់ចាមឲ្យប្រឆាំងនឹងស្តេចខ្មែរ ។ នៅឆ្នាំ ១២០៣ ព្រះអង្គម្ចាស់វិទ្យានន្ទនបានត្រូវបណ្តេញចេញពីចំប៉ា ហើយរហូតមកដល់ឆ្នាំ ១២២០ ប្រទេសចំប៉ាបានត្រូវចាត់ទុកជាអាណាខេត្តមួយរបស់ប្រទេសកម្ពុជា ។

លុះបានជោគជ័យលើពួកចាមហើយ ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់បានពង្រីកដែនដីទៅខាងលិចទៀត គឺបានយកជ្រោយម៉ាឡេស៊ីមួយភាគ និងប្រទេសភូមាមួយភាគ ។

**សំណួរៈ–** ហេតុអ្វីបានជាព្រះបាទជ័យវរ្ម័នទី ៧ លើកទ័ពទៅលុកចំប៉ា នៅឆ្នាំ ១១៩០? –ការលុកលុយនោះបានលទ្ធផលយ៉ាងម្តេច? – ក្នុងការក្បត់របស់ព្រះអង្គម្ចាស់វិទ្យានន្ទន ព្រះអង្គម្ចាស់នេះបានធ្វើអ្វី? – ចំប៉ាបានធ្លាក់ជាអាណាខេត្តខ្មែរ ដល់ឆ្នាំណា? – បន្ទាប់ពីបានជោគជ័យទៅលើចាម ព្រះបាទជ័យវរ្ម័នទី ៧ ព្រះអង្គទ្រង់ធ្វើអ្វីទៀត? –នៅខាងលិច ព្រំដែនខ្មែរលាតទៅដល់ណា?

* * *

## ១៧– ព្រះបាទជ័យវរ្ម័នទី៧ ជាស្តេចសាងប្រាសាទ

*ក្នុងរជ្ជកាលព្រះអង្គ ព្រះបាទជ័យវរ្ម័នទី ៧ បានសាងប្រាសាទជា*

ច្រើន ទុកជាដំណែលរហូតមកដល់សព្វថ្ងៃនេះ ។

## ប្រាងប្រាសាទដែលព្រះអង្គបានសាងៈ —

**នគរធំព្រមទាំងកំផែង :—** កាលចាមចូលលុកលុយប្រទេសយើង ចាមបានធ្វើឲ្យក្រុងយសោធបុរៈខូចខ្នាំច្រើន ។ មិនគ្រាន់តែជួសជុលប្រាសាទទាំងនោះឡើងវិញទេ ព្រះអង្គបានទាំងសាងក្រុងមួយថ្មីទៀតគឺអង្គរធំ ។



ប្រាសាទបាយ័ន

ដើម្បីជាគ្រឿងការពារ ព្រះអង្គបានសាងកំផែងថ្មព័ទ្ធជុំវិញក្រុងដែលមានប្រវែង ១២ គីឡូម៉ែត្រ ។ នៅក្នុងកំផែងនោះ ព្រះអង្គបានសាងប្រាសាទបាយ័នដែលជាទីតាំងនៃក្រុង និងជាទីគោរពបូជាដល់ព្រះពុទ្ធសាសនា ។

**ប្រាសាទព្រះខ័ន ប្រាសាទតាព្រហ្ម ប្រាសាទបន្ទាយឆ្មារ :—** ព្រះអង្គទ្រង់សាងប្រាសាទព្រះខ័ន សម្រាប់ជាទីរំលឹកដល់ព្រះវិញ្ញាណក្ខន្ធនៃព្រះវរបិតា ។ ប្រាសាទតាព្រហ្ម សម្រាប់ដំកល់ព្រះបរមរូបនៃព្រះវរមាតា និងព្រះរូបសម្តេចព្រះគ្រូ ។ ព្រះអង្គទ្រង់សាងប្រាសាទបន្ទាយឆ្មារ (ក្នុងខេត្តបាត់ដំបង) ដើម្បីថ្វាយដល់ព្រះរាជបុត្រព្រះអង្គព្រះនាមស្រិន្ទ្រកុមារ ដែលមានសគុណក្នុងចម្បាំងនឹងចាម ។

**ប្រាសាទដទៃ :—** ក្រៅពីប្រាសាទខាងលើនេះ នៅតំបន់អង្គរ ព្រះអង្គបានសាងប្រាសាទបន្ទាយក្តី ប្រាសាទនាគព័ន្ធ ប្រាសាទតាសោម ប្រាសាទក្រោលគោ ប្រាសាទតានៃ ។ នៅក្នុងខេត្តកំពង់ចាម ព្រះអង្គសាងប្រាសាទនគរ ។ នៅបាទីក្នុងខេត្តតាកែវ ព្រះអង្គបានសាងប្រាសាទតាព្រហ្ម ។

**ព្រះរាជទ្រព្យដំកល់សម្រាប់ប្រាសាទ :—** សម្រាប់ប្រាសាទនានា មានវត្ថុមានតម្លៃជាច្រើន ដូចជាចានមាស ចានប្រាក់ ពេជ្រ កែវមុក្តា ត្បូងយ៉ាងល្អ ផ្តិលមាស រនាំងពីស្រុកចិន ក្រស់ ។ល។

**បុគ្គលិកជាអ្នករាជការក្នុងប្រាសាទ :—** ប្រាសាទនោះមានភូមិបំណុះចំនួនជាច្រើន ។ មានអ្នកធ្វើការរក្សាប្រាសាទជាច្រើននាក់ ។ ក្នុងចំនួនមនុស្ស ១២៦៤០ នាក់ ដែលនៅក្នុងកំផែង មានអធិការ៨នាក់ មានមេគណៈ មានអ្នកគាល់បំរើ មានស្រីរបាំ ។

—oOo—

**សេចក្ដីសង្ខេបៈ**— ព្រះបាទជ័យវរ្ម័ន ទី ៧ ព្រះអង្គបានសាងប្រាសាទច្រើនណាស់ ។ ព្រះអង្គបានសាង អង្គរធំ ដែលមានប្រាសាទបាយ័នសម្រាប់ជាទីតាំងក្រុងនិងកំផែង ប្រវែង ១២ គីឡូម៉ែត្រ សម្រាប់ជាគ្រឿងការពារ ។ ព្រះអង្គបានសាងប្រាសាទព្រះខ័ន សម្រាប់ជាទីរំឭកដល់ព្រះវិញ្ញាណក្ខន្ធព្រះវរបិតាព្រះអង្គ ប្រាសាទតាព្រហ្ម សម្រាប់ដំកល់ព្រះបរមរូបនៃព្រះមាតាព្រះអង្គ និងសម្ដេចព្រះគ្រូ ប្រាសាទបន្ទាយឆ្មារ សម្រាប់ថ្វាយដល់ព្រះរាជបុត្រ ព្រះនាមឝ្រីន្ទកុមារ ។ ក្រៅពីនេះ ព្រះអង្គបានសាងប្រាសាទបន្ទាយក្ដី ប្រាសាទនាគព័ន្ធ ប្រាសាទតាសោម ប្រាសាទក្រោលគោ ប្រាសាទតានៃ ប្រាសាទនគរ (នៅកំពង់ចាម) ប្រាសាទតាព្រហ្ម (នៅតាកែវ) ។

សម្រាប់ប្រាសាទទាំងឡាយ មានវត្ថុមានតម្លៃជាច្រើន ដូចជា មាស ប្រាក់ ត្បូងជាដើម ហើយអ្នកថែរក្សាប្រាសាទទាំងនោះសោតទៀត ក៏មានចំនួនច្រើនក្រៃលែង ។

**សំណួរ**:— ព្រះបាទជ័យវរ្ម័ន ទី៧ សាងប្រាសាទបាយ័នសម្រាប់ធ្វើអ្វី ? កំផែងជុំវិញអង្គរធំប្រវែងប៉ុន្មាន ? ព្រះអង្គបានសាងប្រាសាទព្រះខ័ន ប្រាសាទតាព្រហ្ម ប្រាសាទបន្ទាយឆ្មារ ដើម្បីអ្វី ? ចូររាប់ប្រាសាទដទៃទៀត ? ប្រាសាទនគរនៅឯណា ? ប្រាសាទនៅក្នុងខេត្តតាកែវឈ្មោះអ្វី ?

*　　*　　*

## ១៨– ព្រះបាទជ័យវរ្ម័នទី៧

### «ព្រះអង្គជាមហាក្សត្រប្រកបដោយធម៌»

*ព្រះអង្គទ្រង់យកព្រះហឫទ័យទុកដាក់នឹងសេចក្ដីឈឺចាប់វេទនារបស់ប្រជារាស្ត្រ លើសសេចក្ដីឈឺចាប់របស់ព្រះអង្គផ្ទាល់ ។*

**ព្រះរាជសង្គហកិច្ចៈ—** ក្នុងសម័យព្រះបាទជ័យវរ្ម័នទី ៧ អារាមទាំងឡាយ ទុកជាទីសម្រាប់ទទួលនិស្សិត និងសាសនិកជន ។ ព្រះអង្គបានឲ្យសាងផ្លូវថ្នល់ជាច្រើន ហើយនៅតាមផ្លូវថ្នល់ទាំងនោះ ព្រះអង្គឲ្យសង់សាលាសំណាក់សំរាប់អ្នកដំណើរ ។ ព្រះអង្គបានឲ្យសាងមន្ទីរពេទ្យពេញព្រះនគរ ដើម្បីជាសុខភាពដល់ប្រជារាស្ត្រ ។

**ក្នុងមន្ទីរពេទ្យទាំងឡាយៈ—** ចំពោះមន្ទីរពេទ្យទាំងឡាយ រាជការបានផ្តល់បុគ្គលិក គ្រឿងបរិភោគ និងឱសថយ៉ាងទៀងទាត់ និងយ៉ាងគ្រប់គ្រាន់ ។

ក្នុងមន្ទីរពេទ្យនីមួយៗ មានបុគ្គលិកប្រចាំការជាច្រើននាក់ ។ អ្នកដែលនៅខាងក្នុងមានមុខងារជាគ្រូពេទ្យ ជាមេឃ្លាំង ជាអ្នកចែកថ្នាំ ជាអ្នកធ្វើម្ហូបអាហារ ជាអ្នកដាំទឹក ជាអ្នកបុកថ្នាំ ជាអ្នកបុកស្រូវ ជាអ្នកសំអាត ។

ក្នុងមួយឆ្នាំៗ ឃ្លាំងហ្លួងបើកឲ្យបដងនូវវត្ថុសំរាប់ផ្សំឱសថ ដូចជាទឹកឃ្មុំ កប្បូរ ក្រវាញ សំបោរល្វែង ។ល។

ក្រៅពីមន្ទីរពេទ្យ ដែលជាមន្ទីរពេទ្យប្រចាំស្រុក នៅមានមន្ទីរពេទ្យធំសំខាន់ៗ ប្រចាំក្រុង ។ ចំពោះមន្ទីរពេទ្យធំៗនេះ ចំណាយបានកើនឡើងជាបី ។

ក្នុងមួយឆ្នាំៗ ក្រសួងសុខាភិបាលជាតិ បានចាយជាស្រូវអស់

១១១៩២ តោន ល្ង ២១២៤ គីឡូក្រាម ក្រវាញ ១០៩ គីឡូក្រាម ថ្នាំគ្រុន ៤០០០ គ្រាប់ ថ្នាំបុសជូនបាដ ១៨៦០ ប្រអប់ ។

-o0o-

**សេចក្តីសង្ខេប** — ព្រះបាទជ័យវរ្ម័នទី ៧ ជាព្រះមហាក្សត្រប្រកបដោយធម៌យ៉ាងប្រពៃ។ព្រះអង្គទ្រង់ប្រឈួនដោយជំងឺបណ្តាស្ត្ររបស់ព្រះអង្គ ជាជាងដែលព្រះអង្គប្រឈួនព្រះរោគព្រះអង្គផ្ទាល់។ក្នុងសម័យព្រះអង្គ ព្រះអង្គបានឲ្យសាងអាពម ទុកសម្រាប់ទទួលនិស្សិតនិងសាសនិកជន ។ ព្រះអង្គបានឲ្យសាងផ្លូវថ្នល់ជាច្រើន ហើយនៅតាមផ្លូវថ្នល់ទាំងនោះមានសង់សាលាសំណាក់សម្រាប់អ្នកដំណើរ។ ពេញទាំងនគរ ព្រះអង្គបានឲ្យសាងមន្ទីរពេទ្យដើម្បីជាសុខភាពនៃប្រជារាស្ត្រ ហើយសម្រាប់មន្ទីរពេទ្យទាំងនោះ រាជការបានផ្តល់បុគ្គលិកនិងគ្រឿងបរិក្ខារយ៉ាងគ្រប់គ្រាន់ ។

**សំណួរៈ**— ហេតុអ្វីបានជាគេថា ព្រះបាទជ័យវរ្ម័នទី៧ជាព្រះមហាក្សត្រប្រកបដោយធម៌យ៉ាងប្រពៃ ? ព្រះអង្គបានសាងអាពមសម្រាប់ធ្វើអ្វី? នៅតាមថ្នល់ ហេតុអ្វីបានជាព្រះអង្គទ្រង់ឲ្យសាងសាលាសំណាក់ ? មន្ទីរពេទ្យដែលព្រះអង្គបានសាង សាងឡើងសម្រាប់អ្នកណា? មន្ទីរពេទ្យទាំងឡាយ រាជការបានផ្គត់ផ្គង់យ៉ាងម្តេច?

# ១៥- ព្រះរាជាដែលសោយរាជ្យ

## «ក្រោយព្រះបាទជ័យវរ្ម័នទី ៧»

**ព្រះបាទឥន្ទ្រវរ្ម័នទី២ (១២០១-១២៤៣)** :— *ព្រះអង្គជាព្រះរាជបុត្រព្រះបាទជ័យវរ្ម័នទី ៧ ។ ព្រះអង្គទ្រង់កាន់ព្រះពុទ្ធសាសនា (មហាយាន) ។ នៅឆ្នាំ ១២២០ ព្រះអង្គបានបោះបង់ចំប៉ាឲ្យទៅចាមវិញ ។*

**ព្រះបាទជ័យវរ្ម័នទី ៨ (១២៤៣-១២៩៥)** :— *ក្នុងរជ្ជកាលព្រះអង្គ មានព្រឹត្តិការណ៍សំខាន់ៗ ដូចតទៅនេះ ៖*

**ជាមួយនឹងម៉ុងហ្គោល** ( Mongol ) :— *ជនជាតិម៉ុងហ្គោល បន្ទាប់ពីបានធ្វើសញ្ជ័យយកប្រទេសចិន មានបំណងនឹងចូលពតត្បាតប្រទេសចំប៉ា និងកម្ពុជា ។ ពួកម៉ុងហ្គោលយកចំប៉ាបាន ភាគខាងជើង និងភាគកណ្តាល ។ ព្រះបាទជ័យវរ្ម័នទី ៨ ដោយព្រះអង្គទ្រង់បារម្ភក្រែងមានការបុករុកពលដាលដល់កម្ពុជា ព្រះអង្គក៏ចាត់ឲ្យបញ្ជូនសួយសារអាករទៅឲ្យពួកទាំងនោះ ។*

**ជាមួយនឹងសៀម** :— *សៀម ឬថៃ ដំបូងនៅយូណាន (ក្នុងប្រទេសចិន) ។ កាលពីសតវត្សទី ៨ ពួកនេះបានបង្កើតជាព្រះរាជាណាចក្រមួយ មានឈ្មោះថា ណាន់-ចៅ ។ ក្រោយមកទៀត សៀមក៏បានមកជ្រកនៅក្នុងទឹកដីខ្មែរភាគខាងជើង ហើយមកដល់សតវត្សទី ១៣ សៀមក៏បានដោះខ្លួនរួចពីក្រោមអំណាចខ្មែរ ហើយតាំងព្រះរាជាណាចក្រមួយឯករាជ្យ*

ដោយយកក្រុងសុខោទ័យ ជាព្រះរាជធានី ។

**ប្រតិកម្មនៃពួកព្រាហ្មណ៍** :– ដោយព្រះបាទជ័យវរ្ម័នទី ៨ ព្រះអង្គទ្រង់កាន់លទ្ធិព្រះសិវៈ ពួកព្រាហ្មណ៍ ដែលច្រណែននឹងសេចក្ដីចំរើននៃព្រះពុទ្ធសាសនាក្នុងរជ្ជកាលមុនៗ ក៏បង្ករប្រតិកម្ម បំផ្លាញព្រះពុទ្ធរូប ឬវត្ថុដែលរចនាឡើងតាមលទ្ធិពុទ្ធនិយម ។

**ព្រះបាទឥន្ទ្រវរ្ម័នទី ៣ ឬព្រះបាទស្រិន្ទ្រវរ្ម័ន (១២៩៥-១៣០៨)** :– ព្រះអង្គទ្រង់កាន់ព្រះពុទ្ធសាសនា (តាមលទ្ធិថេរវាទ) ។ តែព្រះអង្គទ្រង់ទំនុកបំរុងពួកព្រាហ្មណ៍ ដូចជាពួកកាន់ព្រះពុទ្ធសាសនាដែរ ។ ក្នុងរជ្ជកាលព្រះអង្គ ប្រទេសបានសេចក្ដីសុខសាន្ត ។

**ព្រះបាទឥន្ទ្រាជ័យវរ្ម័ន ឬព្រះបាទស្រិន្ទ្រវរ្ម័ន (១៣០៨-១៣២៧)** :– ព្រះអង្គជាព្រះមហាក្សត្រកាន់គោរពព្រះសិវៈ ។ ក្នុងរជ្ជកាលព្រះអង្គ ពួកព្រាហ្មណ៍បានប្រព្រឹត្តអំពើរលោភច្រើន ទៅលើពុទ្ធសាសនិកជន មានការធ្វើទុក្ខបុកម្នេញ និងការបំផ្លាញព្រះពុទ្ធរូប ។ ពួកសៀមដោយសំអាងថា ជាអ្នកការពារព្រះពុទ្ធសាសនា បានចូលមករុករានប្រទេសច្រើនលើក រហូតដល់ចំប៉ា ។

**ព្រះបាទជ័យវរ្ម័នទី ៩ (១៣២៧-១៣៣៦)** : - ព្រះអង្គក៏ជាព្រះមហាក្សត្រកាន់គោរពព្រះសិវៈដែរ ។ ក្នុងរជ្ជកាលព្រះអង្គ កម្ពុជាមានការទាក់ទងខាងផ្លូវទូតជាមួយចិនហើយនិងយួន ។

**សេចក្តីសង្ខេប :–** ព្រះបាទឥន្ទ្រវរ្ម័នទី ២ ព្រះអង្គជាព្រះរាជបុត្រព្រះបាទជ័យវរ្ម័នទី ៧ ។ ព្រះអង្គបានបោះបង់ចំប៉ាឲ្យទៅចាមវិញ នៅឆ្នាំ ១២២០ ។ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៨ សៀមដែលធ្លាប់នៅក្រោមអំណាចខ្មែរ បានរើបខ្លួនជាប្រទេសឯករាជ្យ ។ នៅក្នុងប្រទេស អ្នកកាន់សាសនាព្រាហ្មណ៍ បានបង្ករប្រតិកម្មប្រឆាំងនឹងព្រះពុទ្ធសាសនា ។ ក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី ៣ ការឈ្លោះប្រកែកខាងសាសនាបានស្ងប់ស្ងាត់ទៅវិញ ។ មកដល់រជ្ជកាលព្រះបាទឥន្ទ្រជ័យវរ្ម័ន អ្នកកាន់សាសនាព្រាហ្មណ៍ បានធ្វើទុក្ខបុកម្នេញទៅលើអ្នកកាន់ព្រះពុទ្ធសាសនាទៀត ។ នៅពេលនោះ ពួកសៀម ដោយសំអាងខ្លួនជាអ្នកការពារព្រះពុទ្ធសាសនា បានចូលមករុករានប្រទេសច្រើនលើកចូលរហូតដល់ចំប៉ា ។ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៩ ប្រទេសយើងមានការទាក់ទងខាងផ្លូវទូតជាមួយចិន ហើយនិងយួន ។

**សំណួរ :–** ព្រះរាជាអង្គណា សោយរាជ្យបន្ទាប់ពីព្រះបាទជ័យវរ្ម័នទី ៧ ? – ព្រះអង្គត្រូវជាអ្វីនឹងព្រះបាទជ័យវរ្ម័នទី ៧ ? – នៅឆ្នាំណា ព្រះបាទឥន្ទ្រវរ្ម័នទី ២ បោះបង់ចំប៉ាឲ្យទៅចាមវិញ ? – នៅក្នុងរជ្ជកាលព្រះរាជាណា ដែលសៀមបានរើខ្លួនរួចជាប្រទេសឯករាជ្យ ? – នៅក្នុងរាជ្យព្រះបាទឥន្ទ្រជ័យវរ្ម័ន សៀមចូលរុករានប្រទេសដោយសំអាងអ្វីជាលេស ? – ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៩ កម្ពុជាមានការទាក់ទងខាងផ្លូវទូតជាមួយប្រទេសណាខ្លះ ?

* * *

## ២០– សាសនា

*តាំងពីរវាងសតវត្សទី ១ ជនជាតិឥណ្ឌាដែលបានចូលមកប្រទេសខ្មែរ បាននាំមកនូវសាសនាធំ ៗ ពីរ ។ គឺព្រហ្មញ្ញសាសនា និងព្រះពុទ្ធ-សាសនា ។ សាសនាទាំងពីរនេះ នៅកម្ពុជាមានគេរាប់អាន កាន់រៀង*

ដរាបមក ខុសគ្នាតែតិច ឬច្រើន ។ ព្រហ្មញ្ញសាសនាបានទទួលសេចក្តីរុងរឿង តាំងពីសតវត្សទី១ រហូតដល់សតវត្សទី ១១ ។ ព្រះពុទ្ធសាសនាបានទទួលឋានៈខ្ពង់ខ្ពស់ តាំងពីសតវត្សទី ១២ មកទល់នឹងសព្វថ្ងៃ ។

**ព្រហ្មញ្ញសាសនា** :– ក្នុងព្រហ្មញ្ញសាសនា មានព្រះទេវច្រើន ។ ព្រះទេវៈដែលសំខាន់ជាងគេ គឺព្រះព្រហ្ម ព្រះសិវៈ និងព្រះវិស្ណុ ។ តាមព្រហ្មញ្ញសាសនា ព្រះទេវៈទាំងអស់សុទ្ធតែមានឫទ្ធានុភាព អាចធ្វើឲ្យមនុស្សយើងបានសុខ ឬ បានទុក្ខ ។



ព្រះព្រហ្ម ព្រះឥសូរ នៅក្លោងទ្វារប្រាសាទបាយ័ន

**ព្រះព្រហ្ម** :– ព្រះអង្គមានព្រះភក្ត្របួន មានព្រះហស្តបួន ។

**ព្រះសិវៈ ឬ ព្រះឥសូរ** :– រូបតំណាងព្រះអង្គមានច្រើនបែប ។

បើរូបជាមនុស្ស គេអាចសំគាល់បានដោយមានព្រះនេត្រទី ៣ នៅត្រង់ថ្ពាល់ ។

**ព្រះវិស្ណុ ឬព្រះនារាយណ៍** :– រូបតំណាងព្រះអង្គមានច្រើនបែប ៗ តាមធម្មតា គេសាងឡើងជាតួមនុស្ស មានព្រះហស្តបួន មួយកាន់កងចក្រ មួយកាន់ខ្យងស័ង្ខ មួយកាន់ដំបងមោង មួយកាន់ផែនដី ។

**ព្រះហរិហរ** :– ឯព្រះហរិហរៈ គឺជារូបតំណាងនៃព្រះហរិ ឬ ព្រះវិស្ណុ និងព្រះហរៈ ឬ ព្រះសិវៈរួមបញ្ចូលគ្នា ។ ភាគខាងឆ្វេង គឺព្រះវិស្ណុ ។ ភាគខាងស្តាំ គឺព្រះសិវៈ ។ ខ្មែរយើងច្រើនគោរពព្រះហរិហរៈនៅសម័យចេនឡា ។

**ព្រះពុទ្ធសាសនា** :– ព្រះពុទ្ធសាសនាមានបែកខ្ញែកជាច្រើនពួក ៗ ពួកធំ ៗ មានពីរគឺមហាយាន និងហិនយាន ។

**ព្រះពុទ្ធសាសនាមហាយាន** :– តាមព្រះពុទ្ធសាសនាមហាយានគេគោរពព្រះពោធិសត្វ ដែលជាព្រះអតីតជាតិនៃព្រះពុទ្ធ ។ ពោធិសត្វដែលគេគោរព គឺព្រះលោកេស្វរៈ និងព្រះអវលោកិតេស្វរៈ ។ អ្នកកាន់គោរពយល់ថា ព្រះពោធិសត្វមានអនុភាព អាចធ្វើឲ្យមនុស្សយើងបានសុខ ឬបានទុក្ខ ។ រូបតំណាងព្រះពោធិសត្វស្រដៀង ១ និងព្រះវិស្ណុ ។ គឺព្រះពុទ្ធសាសនាតាមបែបមហាយាននេះហើយ ដែលខ្មែរយើងកាន់ច្រើន



លោកិស្វរៈ

នៅសម័យអង្គរ ។ ព្រះរាជា ដែលជាច្បងក្នុងការកាន់សាសនានេះគឺ ព្រះបាទសុរិយវរ្ម័នទី១ (១០០២-១០៥០) ។

**ព្រះពុទ្ធសាសនាហិនយាន :—** តាមព្រះពុទ្ធសាសនា ហិនយានគេគោរពព្រះពុទ្ធ ហើយប្រកាន់ធ្វើតាមព្រះពុទ្ធោវាទ ។ ព្រះពុទ្ធជាបរមគ្រូ ចង្អុលប្រាប់ផ្លូវល្អអាក្រក់ ។ ព្រះអង្គមិនអាចធ្វើឲ្យមនុស្សលោកបានសុខឬ បានទុក្ខដូចសាសនាព្រាហ្មណ៍ ឬមហាយានទេ ។

គឺព្រះពុទ្ធសាសនាហិនយាននេះហើយ ដែលខ្មែរយើងកាន់សព្វថ្ងៃ។ ព្រះរាជាខ្មែរដែលកាន់លទ្ធិនេះមុនគេ គឺព្រះបាទឥន្ទ្រវរ្ម័នទី ៣ (១២៩៥-១៣០៨) ។ លទ្ធិហិនយាននេះ មានការចំរើនតាំងពីសតវត្សទី ១៤ រហូតមក ។



ព្រះពុទ្ធរូបគង់នៅលើនាគ

**សេចក្ដីសង្ខេប** :— តាំងពីសតវត្សទី ១ ជនជាតិឥណ្ឌាដែលបានចូលមកប្រទេសខ្មែរ បាននាំមកនូវសាសនាធំៗ ពីរ ។ គឺព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា។ ក្នុងព្រហ្មញ្ញសាសនាមានព្រះទេវៈច្រើន ។ តែព្រះទេវៈដែលសំខាន់ជាងគេ គឺព្រះព្រហ្ម ព្រះសិវៈ ឬព្រះឥសូរ ព្រះវិស្ណុ ឬ ព្រះនារាយណ៍ ។ នៅសម័យចេនឡា គេច្រើនគោរពព្រះហរិហរៈ ។ ព្រហ្មញ្ញសាសនានេះ បានទទួលសេចក្ដីរុងរឿងនៅកម្ពុជាតាំងពីសតវត្សទី ១ ដល់សតវត្សទី ១១ ។

ព្រះពុទ្ធសាសនាបែកជានិកាយធំៗ ពីរពួក ។ គឺមហាយាន និងហិនយានៗ តាមលទ្ធិមហាយាន គេគោរពព្រះពោធិសត្វ ។ សាសនានេះមិនសូវខុសពីព្រហ្មញ្ញសាសនាទេ ។ គេគោរពសាសនានេះនៅសម័យអង្គរ ។ តាមសាសនាហិនយាន

គេគោរពព្រះពុទ្ធដែលជាព្រះបរមគ្រូ និងប្រកាន់តាមព្រះពុទ្ធវាទ ។ គឺព្រះពុទ្ធសាសនានេះហើយដែលខ្មែរយើងកាន់សព្វថ្ងៃ ។

**សំណួរៈ**—ជនជាតិឥណ្ឌាដែលមកកាន់ប្រទេសខ្មែរយើង បាននាំសាសនាអ្វីខ្លះមកកម្ពុជា? ក្នុងព្រហ្មញ្ញសាសនា គេគោរពអ្វី? នៅសម័យចេនឡា គេច្រើនគោរពអ្វី? ព្រហ្មញ្ញសាសនា បានទទួលការរុងរឿងនៅពេលណា ? ព្រះពុទ្ធសាសនាបែកជាប៉ុន្មាននិកាយ ? តាមលទ្ធិមហាយាន គេគោរពអ្វី? ក្នុងសម័យណា គេកាន់លទ្ធិមហាយាន? តាមលទ្ធិមហាយាន គេគោរពអ្វី ? សព្វថ្ងៃនេះយើងកាន់ព្រះពុទ្ធសាសនាតាមលទ្ធិណា ?

* * *

## ២១– ប្រាង្គប្រាសាទ

**ប្រាង្គប្រាសាទទាំងឡាយជាបេតិកភណ្ឌខ្មែរ** :— *កម្ពុជាយើងជាប្រទេសសម្បូណ៌ដោយប្រាង្គប្រាសាទ ដែលជាបេតិកភណ្ឌមានដំលៃលើសលុប ។ ភាពសម្បើមនិងភាពល្អនៃប្រាសាទទាំងឡាយ បានទទួលនូវការសរសើរស្ញប់ស្ញែងពីមហាជនក្នុងពិភពលោក ។ ទំហំការនិងសិល្បៈការដ៏អស្ចារ្យនៃការស្ថាបនានោះ បាននាំឲ្យជនជាតិអឺរ៉ុបខ្លះមិនជឿថាជាសមត្ថភាពខ្មែរផង ។*

**កាលសម័យនៃ "អង្គរ"**:— *តាំងពីសម័យហ្វូណន រហូតមកដល់បច្ចុប្បន្នសម័យ ការស្ថាបនារមែងមានជាហូរហែមក ។ តែការស្ថាបនាដែលមានច្រើនជាងគេ ហើយដោយថ្មផង គឺស្ថាបនាក្នុងសម័យ "អង្គរ" ។ ព្រះរាជាខ្មែរគង់នៅ"អង្គរ"មុនគេបង្អស់ គឺព្រះបាទជ័យវរ្ម័នទី២ (៨០២-៨៥០) ហើយក្រោយគេបង្អស់ គឺព្រះបាទពញាយ៉ាត (១៤២១-*

១៤៦២) ។ ព្រះបាទចៅពញាយ៉ាតព្រះអង្គទ្រង់ចាកចេញពីអង្គរនៅឆ្នាំ ១៤៣៣ ។ តែបើកាលណាគេនិយាយពីសម័យ “អង្គរ” គេនឹកតែពីរជ្ជកាលព្រះបាទជ័យវរ្ម័នទី ២ ដល់រជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ (១១៨១-១២០១) គឺពីសតវត្សទី ៩ ដល់សតវត្សទី ១២ ព្រោះនៅចន្លោះពេលនោះ ប្រាសាទថ្មបានស្ថាបនាឡើងយ៉ាងច្រើនហាក់ដូចផុសពីដី ដែលគួរហៅឲ្យច្បាស់ថា : “សម័យសាងប្រាសាទ” ។

**ភូមិដ្ឋាននៃមូលស្ថាបនាៈ** – បើនិយាយពីភូមិដ្ឋាននៃមូលស្ថាបនាវិញក៏ដូច្នោះដែរ ។ គឺគេច្រើននឹកតែទៅដំបន់អង្គរ ក្នុងខេត្តសៀមរាប ព្រោះនៅទីនោះមានប្រាសាទអង្គរវត្តដែលល្អជាងគេ ហើយមានប្រាសាទដទៃច្រើនណាស់ផង ។ តែតាមពិត ប្រាសាទខ្មែរមានពាសពេញតែកម្ពុជាទាំងក្រៅកម្ពុជាសព្វថ្ងៃនេះទៀតផង ។ ប្រាសាទទាំងអស់មានចំនួនជាង ៨០០ កំពូល ។

**មូលហេតុនៃការស្ថាបនាៈ** – នៅសម័យបុរាណ ជំនឿក្នុងសាសនា មានការមុតមាំណាស់ គឺឥទ្ធិពលនៃសាសនានេះហើយ ដែលបាននាំព្រះរាជាខ្មែរឲ្យសាងប្រាង្គប្រាសាទសន្ធឹកសន្ធាប់ហើយល្អៗ យ៉ាងនេះ ។ តែបើនិយាយឲ្យជាក់លាក់ទៅទៀត ការស្ថាបនាទាំងឡាយ មានគោលដៅផ្សេងៗ ពីគ្នាដែរ ។ ប្រាសាទខ្លះសម្រាប់ជាគោលនៃនគរហៅថា“ភ្នំ” ដូចជាប្រាសាទនៅភ្នំបាខែង ប្រាសាទបាពួន ប្រាសាទបាយ័ន ។

ប្រាសាទខ្លះសម្រាប់ជាទីនមស្សការដល់សាសនា ដូចជាប្រាសាទភ្នំក្រោម ប្រាសាទភ្នំបូក ព្រមទាំងប្រាសាទ„ភ្នំ” ទាំងឡាយ ។ ប្រាសាទខ្លះទៀត សម្រាប់ជាទីរំលឹកដល់ព្រះវិញ្ញាណក្ខន្ធនៃព្រះអតីតមហាក្សត្រ ដូចជាប្រាសាទព្រះខ័ន ប្រាសាទតាព្រហ្ម ប្រាសាទមេបុណ្យ ។

**ព្រះរាជាដែលបានសាងប្រាសាទថ្ម :-** ក្នុងសម័យអង្គរ ព្រះរាជាខ្មែរទាំងឡាយច្រើនជាព្រះរាជាស្ថាបនិកប្រាសាទថ្ម ។ តែព្រះរាជាដែលមានព្រះនាមល្បីជាងគេក្នុងការស្ថាបនានោះ គឺព្រះបាទយសោវរ្ម័នទី ១ ព្រះបាទសុរ្យវរ្ម័នទី ២ ព្រះបាទជ័យវរ្ម័នទី ៧ ។ ព្រះបាទយសោវរ្ម័នទី ១ព្រះអង្គបានផ្តើមមូលស្ថាបនានៅ“អង្គរ”ដែលឲ្យឈ្មោះថា យសោធបុរៈ ។ ព្រះបាទសុរិយវរ្ម័នទី២ ព្រះអង្គបានសាងអង្គរវត្តដ៏ល្អក្រៃលែង។ព្រះបាទជ័យ-វរ្ម័នទី ៧ព្រះអង្គបានសាងប្រាសាទជាច្រើនមានប្រាសាទបាយ័នជាដើម។




ប្រាសាទនៅអង្គរ

—oOo—

**សេចក្ដីសង្ខេបៈ**— ប្រាង្គប្រាសាទទាំងឡាយជាស្នាដៃនៃបុព្វបុរសរបស់យើង ។ សម័យអង្គរ គឺសម័យចាប់ពីរជ្ជកាលព្រះបាទជ័យវរ្ម័ន ទី ២ មកទល់នឹងរជ្ជកាលព្រះបាទពញាយ៉ាត ។ ប្រាសាទទាំងឡាយមានសឹងតែគ្រប់កន្លែងក្នុងប្រទេសកម្ពុជា តែមានច្រើនជាងគេនៅខេត្តសៀមរាប ។ ប្រាសាទខ្លះសាងឡើងដើម្បីជាគោលនៃព្រះនគរ ខ្លះជាទីសម្រាប់ធ្វើនមស្ការចំពោះសាសនា និងជាទីរំឭកដល់ព្រះវិញ្ញាណក្ខន្ធនៃព្រះអតីតមហាក្សត្រ ។ ព្រះរាជាដែលមានព្រះនាមល្បី គឺព្រះបាទយសោវរ្ម័នទី ១ ព្រះបាទយសោវរ្ម័នទី ២ ព្រះបាទជ័យវរ្ម័ន ទី ៧ ។ ព្រះបាទយសោវរ្ម័ន ព្រះអង្គបានផ្ដើមមូលស្ថាបនានៅ ‘‘អង្គរ,, ។ ព្រះបាទសុរិយវរ្ម័នទី ២ ព្រះអង្គបានសាងប្រាសាទអង្គរវត្តដែលល្អក្រៃលែង ។ ព្រះបាទជ័យវរ្ម័នទី ៧ ព្រះអង្គបានសាងប្រាសាទជាច្រើន មានប្រាសាទបាយ័នជាដើម ។

**សំណួរៈ**— សម័យ ‘‘អង្គរ,, ចាប់ពីរជ្ជកាលណា ដល់រជ្ជកាលណា ? ហេតុម្ដេចបានជាសម័យនោះ ហៅសម័យអង្គរ? ប្រាសាទខ្មែរមាននៅឯណាខ្លះ? ហេតុអ្វីបានជាព្រះរាជាខ្មែរសាងប្រាសាទទាំងនោះ ? ព្រះរាជាអង្គណាខ្លះ ដែលមានព្រះនាមល្បីក្នុងការស្ថាបនាប្រាសាទថ្មី ?

* * *

## ២២–ព្រះបាទត្រសក់ផ្អែម និងព្រះរាជបុត្រ(១)
## «ចម្បាំងនឹងសៀម»

*មកដល់ពាក់កណ្ដាលសតវត្សទី ១៨ និងក្នុងសតវត្សបន្ទាប់ ៗ គ្នាមក ប្រវត្តិសាស្ត្រយើងខ្វះការជាក់លាក់ច្រើន ។ មានឯកសារខ្លះខ្វែងគ្នា ។ មានឯកសារខ្លះរំលង ។ មានខ្លះផ្ដល់ដំណឹងជាបែបរឿងទេពនិទាន ។*

(១) មើលនៅទំព័រខាងចុង ។




ផែនទី សៀមនិងខ្មែរ ក្នុងសម័យបុរាណ

**ព្រះបាទត្រសក់ផ្អែម និងព្រះរាជបុត្រ:—** ដើមឡើយ ព្រះបាទត្រសក់ផ្អែម ជានាយចំការត្រសក់ស្ដេច ដែលបេះដាំត្រសក់បានផ្លែផ្អែម ហើយ បានធ្វើគតព្រះមហាក្សត្រ ដោយការប្រទូស្តក្នុងវេលាយប់មួយ ៗ បន្ទាប់មក នាយត្រសក់ផ្អែមត្រូវបានជ្រើសរើសឲ្យឡើងសោយរាជ្យ(១៣៣៦-

១៣៤០) ។

អំណើះតពីព្រះបាទត្រសក់ផ្អែមមក ព្រះរាជបុត្រព្រះអង្គពីរអង្គ ដែលបានគ្រងរាជ្យជាបន្តបន្ទាប់គ្នា គឺព្រះបាទនិព្វានបាទ (១៣៤០-១៣៤៦) និងព្រះបាទសិទ្ធានរាជា (១៣៤៦-១៣៤៦) ។ លុះព្រះបាទសិទ្ធានរាជាសុគតទៅ ព្រះរាជបុត្រព្រះអង្គទ្រង់ឡើងគ្រងរាជ្យ ហើយទ្រង់ព្រះនាមថា ព្រះបាទលំពង្សរាជា (១៣៤៧-១៣៥៣) ។

**ក្នុងរជ្ជកាលព្រះបាទលំពង្សរាជា - សៀមលើកទ័ពមកវាយអង្គរ** :– សៀម ឬ ថៃ ដំបូងនៅខាងយូណាន់ (ក្នុងប្រទេសចិន) ។ កាលពីសតវត្សទី៨ ពួកនេះបានបង្កើតជាព្រះរាជាណាចក្រមួយមានឈ្មោះថា ណាន់-ចៅ ។ បន្តមក សៀមបានមកនៅលើដីខ្មែរភាគខាងជើង ហើយតាំងរាជធានីនៅសុខោទ័យ ។

នៅឆ្នាំ១៣៥០ ព្រះចៅសៀមព្រះនាមរាមាធិបតី បានផ្លាស់ព្រះរាជធានី ពីសុខោទ័យ មកអយុធ្យា ក្នុងបំណងវាយខ្មែរ ។ នៅឆ្នាំ១៣៥១ ព្រះចៅសៀមបានលើកទ័ពចូលមកវាយអង្គរ ។ តែព្រះបាទលំពង្ស ព្រះអង្គបានដេញកំចាត់ទ័ពសត្រូវឲ្យថយទៅវិញ ។ បន្ទាប់មកសៀមបានលើកទ័ពបន្ថែមមកទៀត ហើយព័ទ្ធអង្គរបាន ។ ក្នុងពេលនោះទទួលព្រះអង្គទ្រង់ប្រឈួន ហើយសុគតទៅ ។ ព្រះស្រីសុរិយោ-ទ័យ ដែលត្រូវជាព្រះអនុជ និងជាព្រះឧបរាជ ព្រះអង្គបានតស៊ូនឹងទ័ព

សៀមប្រមាណមួយឆ្នាំ ។ តែដល់ចុងបង្អស់ គឺនៅឆ្នាំ ១៣៥២ ព្រះអង្គក៏សុគតក្នុងការប្រយុទ្ធទៅទៀត ។ សៀមយកអង្គរបាន សៀមប្រមូលយករត្នមានដំលៃ និងចាប់ខ្មែរធ្វើជាឈ្លើយជាច្រើន ។

**ព្រះបាទស្រីសុរិយោវង្សទី ១** (១៣៥៧ - ១៣៦៣) **ទ្រង់កំចាត់សៀមចេញពីអង្គរៈ—** យកអង្គរបាន ទ័ពសៀមនៅកាន់កាប់អង្គរទៀត ។ នៅឆ្នាំ ១៣៥៧ ព្រះស្រីសុរិយោវង្ស ដែលត្រូវជាព្រះភគិនិយោនៃព្រះបាទលំពង្ស និងព្រះស្រីសុរិយោទ័យ ដែលបានភៀសព្រះអង្គទៅលាវ ព្រះអង្គទ្រង់បានបង្ករទ័ពកំចាត់សៀមចេញពីអង្គរបាន ។ ព្រះអង្គបានដេញសៀមរហូតហួសកូរ៉ាត និងប្រាជិន ។

**ព្រះបាទបរមរាមា**(១៣៦៦-១៣៧៣)៖— លុះព្រះបាទស្រីសុរិយោវង្សសុគតទៅ ព្រះរាជបុត្រព្រះបាទលំពង្សមួយអង្គឡើងគ្រងរាជ្យ ហើយទ្រង់ព្រះនាមថាព្រះបាទបរមរាមា ។ ក្នុងរជ្ជកាលព្រះអង្គ កម្ពុជាមានសុខសន្តិភាព ។ ជាមួយនឹងសៀម ព្រះអង្គគ្មានរឿងរ៉ាវអ្វីទេ ។ ជាមួយនឹងចិនព្រះអង្គមានការទាក់ទងយ៉ាងប្រសើរ ។

– oOo –

**សេចក្ដីសង្ខេបៈ—** មកដល់សតវត្សទី១៤ មានព្រះរាជាមួយព្រះអង្គ ព្រះនាមព្រះបាទត្រសក់ផ្អែម ។ ព្រះអង្គមានព្រះរាជបុត្រពីរអង្គ ដែលបានគ្រងរាជ្យតៗបន្ទាប់គ្នា គឺព្រះបាទនិព្វានបាទ និងព្រះបាទសិទ្ធានរាជា។ លុះព្រះបាទសិទ្ធានរាជាសុគតទៅ ព្រះរាជបុត្រព្រះ

អង្គព្រះនាមលំពង់រាជាឡើងគ្រងរាជ្យមកទៀត (១៣៤៧-១៣៥៣) ។

នៅឆ្នាំ ១៣៥២ សៀមបានលើកទ័ពមកវាយអង្គរ ។ សៀមព័ទ្ធអង្គរជាប់ជិតមួយឆ្នាំ ។ នៅពេលនោះព្រះបាទលំពង្សប្រឈួន ហើយសុគតទៅ ។ ព្រះស្រីសុរិយោទ័យ ព្រះអនុជព្រះអង្គ បានតស៊ូឈមមុខតទល់នឹងសៀម ហើយព្រះអង្គបានសុគតក្នុងការប្រយុទ្ធ នៅពេលដែលសៀមវាយអង្គរបាន ។ នៅពេលនោះ សៀមប្រមូលព្រះរាជទ្រព្យនិងចាប់ខ្មែរបញ្ជូនទៅប្រទេសសៀមជាច្រើន ។

លុះដល់ឆ្នាំ ១៣៥៧ ព្រះស្រីសុរិយោវង្សទី ១ (១៣៥៧-១៣៦៣) ព្រះអង្គដែលបានភៀសខ្លួនទៅស្រុកលាវ បានបង្ករទ័ពកំចាត់សៀមឲ្យចេញពីអង្គរទៅវិញ ដេញរហូតដល់ភ្ជ័ត និងប្រាជិន ។ ពីនោះមក កម្ពុជាបានសុខសាន្ត ។ លុះព្រះបាទស្រីសុរិយោវង្សសុគតទៅ ព្រះបាទបរមរាមា (១៣៦៦-១៣៧៣) បានឡើងគ្រងរាជ្យបន្តមកទៀត ។

**សំណួរ** :– ព្រះបាទត្រសក់ផ្អែមមានព្រះរាជបុត្រប៉ុន្មាន ? ព្រះនាមអ្វី ? សៀមមកវាយអង្គរក្នុងឆ្នាំណា ? ក្នុងរជ្ជកាលព្រះរាជាណា ? ចូរអធិប្បាយពីចម្បាំងនោះ ។ យកអង្គរបានសៀមធ្វើអ្វីខ្លះ ? ព្រះរាជាអង្គណា ដែលកំចាត់សៀមទៅវិញ ? ព្រះរាជាណា ដែលសោយរាជ្យបន្ទាប់ពីព្រះអង្គ ?

# ជំពូកទី៤-សម័យក្រោយអង្គរ

## ២៣- ព្រះបាទធម្មាសោក - ព្រះបាទសុរិយោវង្សទី២

### ព្រះបាទបរមសុខា - ព្រះបាទពញាយ៉ាត

### ចម្បាំងនឹងសៀម - ការចាកចោលអង្គរ

ក្នុងរជ្ជកាលព្រះបាទធម្មាសោក ឬ ធម្មោសុខរាជ (១៣៧៣ - ១៣៩៤):–

នៅឆ្នាំ ១៣៧៣ ព្រះបាទធម្មាសោក ដែលត្រូវជាព្រះអនុជព្រះបាទបរមពមា បានឡើងគ្រងរាជ្យ ។ នៅឆ្នាំ ១៣៨៤ ដើម្បីសងសឹក ព្រះអង្គបានលើកទ័ពទៅវាយសៀម យកបានចន្ទបូរ (ចាន់តប៊ុន) និងជលបុរី (ឆុនប៊ូរី) ហើយបានទាំងនាំប្រជាជននៅភូមិភាគនោះមកបានប្រមាណ ៨០០០នាក់ផង ។

នៅឆ្នាំ ១៣៩៣ ក្នុងចម្បាំងតទប់របស់សៀម ព្រះអង្គមានជោគជ័យម្តងទៀតនៅចន្ទបូរ ។

នៅឆ្នាំ ១៣៩៤ សៀមបានលើកទ័ពមកព័ទ្ធអង្គរ ជាប់ ៧ ខែ ។ ពេលនោះ ដោយមានមន្ត្រីខ្មែរក្បត់ចូលដៃសៀម និងដោយព្រះបាទធម្មាសោកសុគតទៀត សៀមក៏យកអង្គរបាន ។ បន្ទាប់មកសៀមបានដាក់ស្តេចសៀមមួយអង្គឲ្យសោយរាជ្យនៅអង្គរ ។

ក្នុងរជ្ជកាលព្រះចៅពញា ឬ ព្រះបាទសុរិយោវង្សទី២ (១៤០១-១៤៧):–

ពេលនោះ ព្រះរាជបុត្រព្រះស្រីសុរិយោទ័យ ព្រះនាមព្រះចៅពញា

ព្រះអង្គបានប្រមូលទ័ពពីខាងស្រីសន្ធរ ទៅវាយកំចាត់សៀមឲ្យចេញពីអង្គរទៅវិញ ព្រមទាំងបានសម្លាប់ស្ដេចសៀម ដែលសោយរាជ្យនៅអង្គរផង ។ បន្ទាប់មក ទើបព្រះអង្គឡើងគ្រងរាជ្យ ។

**ក្នុងរជ្ជកាលព្រះបាទបរមសុខា** (១៤១៧-១៤២០) — អំពេកិះពីព្រះបាទចៅពញាឬស្រីសុរិយោវង្សទី ២ មក ព្រះកត្តិនិយោ ព្រះអង្គទ្រង់ឡើងគ្រងរាជ្យ ។ គឺព្រះបាទបរមសុខា ។ នៅឆ្នាំ ១៤២០ សៀមលើកទ័ពមកឡោមអង្គរទៀត ។ ព្រះបាទបរមសុខាទ្រង់សុគតក្នុងការតយុទ្ធនឹងសៀមនោះ ហើយសៀមក៏យកអង្គរបានទៀត ។

**ព្រះបាទពញាយ៉ាត** (១៤២១-១៤៦២):— ព្រះអង្គត្រូវជាព្រះរាជបុត្រព្រះបាទចៅពញា ឬ ស្រីសុរិយោវង្សទី ២ ។ កាលនោះព្រះអង្គព្រះជន្មបាន ១៨ ព្រះវស្សា ។

**ព្រះអង្គកំចាត់សៀម:**— យកអង្គរបាន សៀមនៅកាន់កាប់ដោយមានស្ដេចសៀមមួយអង្គគង់នៅផង ។ មួយឆ្នាំក្រោយមក គឺនៅឆ្នាំ១៤២១ ព្រះអង្គបានចាត់ឲ្យធ្វើគតស្ដេចសៀម ហើយព្រះអង្គក៏ឡើងគ្រងរាជ្យ។

**ព្រះអង្គផ្លាស់ព្រះរាជធានីមកភ្នំពេញឆ្នាំ ១៤៤៦:**— ដោយព្រះអង្គទ្រង់ព្រះតម្រិះឃើញថា ព្រះរាជធានីអង្គរនៅជិតក្រុងអយុធ្យាពេក ព្រះអង្គក៏ទ្រង់រកផ្លាស់ព្រះរាជធានី ។ ដំបូងព្រះអង្គយាងមកគង់នៅប្រាសាទស្រីសន្ធរ ។ តែដោយស្រីសន្ធរទឹកលិច ព្រះអង្គក៏ទ្រង់ជ្រើសរើសយក

*ចតុមុខវិញ ដែលព្រះអង្គចាត់ឲ្យរៀបចំឡើង ដោយចាក់ដីពង្រាប ដីកព្រែក និងសាងវត្តជាដើម ។*

**ព្រះអង្គដាក់រាជ្យនៅឆ្នាំ ១៤៦២:** - *នៅឆ្នាំ១៤៦២ ព្រះអង្គទ្រង់ដាក់រាជ្យ ដើម្បីព្រះរាជបុត្រព្រះអង្គព្រះនាម នារាយណ៍រាមាធិបតី ។ ព្រះបាទពញាយ៉ាតទ្រង់សុគត ៤ ឆ្នាំក្រោយមក ។ ព្រះអង្គព្រះជន្មបាន ៧៨ ព្រះវស្សា ។*

-oOo-

**សេចក្ដីសង្ខេប:**— ដើម្បីសងសឹក ព្រះបាទធម្មាសោក(១៣៧៣-១៣៩៤) ព្រះអង្គបានលើកទ័ពទៅវាយសៀម យកបានចន្ទបូរ និងជលបុរី ។ តែនៅឆ្នាំ ១៣៩៤ សៀមបានលើកទ័ពមកវាយខ្មែរ ហើយយកបានអង្គរ ។ កាលនោះព្រះបាទធម្មសោក ព្រះអង្គទ្រង់សោយទីវង្គតក្នុងការតស៊ូ ។ សៀមក៏កាន់កាប់អង្គររហូតដល់ឆ្នាំ ១៤០១ ។

នៅឆ្នាំ ១៤០១ នេះ សៀមបានខាត់ពីអង្គរទៅវិញ ដោយសារការវាយប្រហារនៃព្រះបាទស្រីសុរិយោវង្សទី២ (១៤០១-១៤១៧) តែនៅឆ្នាំ ១៤២០ ក្នុងរជ្ជកាលព្រះបាទបរមសុខា (១៤១៧-១៤២០) សៀមចូលមកវាយខ្មែរវិញ។ ព្រះបាទបរមសុខាទ្រង់សោយទីវង្គតក្នុងការតស៊ូ ។ សៀមយកអង្គរ និងកាន់កាប់បានមួយឆ្នាំ ។ នៅឆ្នាំ ១៤២១ ព្រះបាទពញាយ៉ាត(១៤២១-១៤៦២) បានចាត់ឲ្យធ្វើឃាតស្ដេចសៀមនៅអង្គរបាន ។ បន្ទាប់មកនៅឆ្នាំ ១៤៤៦ ព្រះអង្គបានផ្លាស់រាជធានីមកចតុមុខវិញ ។

ព្រះរាជបុត្រព្រះអង្គ ព្រះនាមព្រះនារាយណ៍ធិបតី សោយរាជ្យបន្ទាប់ពីព្រះអង្គ ។

**សំណួរ:**— ហេតុអ្វីបានជាព្រះបាទធម្មាសោកលើកទ័ពទៅច្បាំងនឹងសៀម ? ចម្បាំងនោះបាន

លទ្ធផលយ៉ាងម្ដេច ? សៀមយកអង្គរលើកទី២ ពីឆ្នាំណា ? ព្រះរាជាណាដែលបាន កំចាត់សៀមទៅវិញនៅពេលនោះ ? សៀមយកអង្គរបានជាលើកទី ៣ ក្នុងឆ្នាំណា ? ក្នុងរជ្ជកាលព្រះរាជាណា ? យ៉ាងម្ដេចទើបសៀមខ្លាត់ទៅវិញ ? ព្រះបាទពញាយ៉ាត ផ្លាស់រាជធានីមកភ្នំពេញនៅឆ្នាំណា ? ហេតុអ្វី ?

* * *

## ២៨ – ព្រះរាជបុត្រព្រះបាទពញាយ៉ាត(១) ចម្បាំងនឹងសៀម

### « នាយកនជណ្តើមរាជ្យ »

**ព្រះរាជបុត្រព្រះបាទពញាយ៉ាត :—** *ព្រះរាជបុត្រព្រះបាទពញាយ៉ាតទាំងបី ព្រះអង្គដែលបានគ្រងរាជ្យ គឺព្រះបាទនារាយណ៍រាជា ព្រះបាទស្រីរាជា និងព្រះបាទធម្មោរាជា ។*

**ព្រះបាទនារាយណ៍រាជា (១៤៦២-១៤៦៧) :—** *ក្នុងរជ្ជកាលព្រះអង្គ ពុំមានព្រឹត្តិការណ៍សំខាន់ទេ ។ ព្រះអង្គទ្រង់សុគតក្នុងឆ្នាំជាមួយនឹងព្រះវរបិតាព្រះអង្គ ។*

**ព្រះបាទស្រីរាជា ឬ រាមាធិបតី (១៤៦៧-១៤៧៤) :—** *ព្រះអង្គឡើងគ្រងរាជ្យបន្ទាប់ពីព្រះបាទនារាយណ៍រាជាមក ។*

*ក្នុងរជ្ជកាលព្រះអង្គ គឺនៅក្នុងឆ្នាំ ១៤៧៣ សៀមបានវាយលុកយកក្រូរ៉ាត អង្គរ និងចន្ទបុរ ។ ព្រះបាទស្រីរាជា ព្រះអង្គបានចាត់ព្រះ*

(១) មើលបំណុបខ្សែគ្នានៅខាងចុង ។

អនុជព្រះអង្គ ព្រះនាមពញាធម្មោរាជាឲ្យទៅរៀបចំទ័ពទប់ទល់នឹងសៀម ។ តែទ័ពសៀមបានចូលលុកមកទៀត រហូតចាប់ព្រះបាទស្រីរាជាបាននៅឆ្នាំ ១៤៧៤ ។ ព្រះអង្គសុគតនៅឯស្រុកសៀម ។ ព្រះអង្គមានព្រះរាជបុត្រមួយអង្គព្រះនាម ចៅពញាអុង ដែលសៀមឃាំងទុកឯស្រុកសៀម ។

**ព្រះបាទចៅពញាធម្មោរាជា (១៤៧៤-១៤៩៤) :—** ពេលនោះព្រះធម្មោរាជា ព្រះអង្គទ្រង់កេណ្ឌទ័ពទៅខាងបាភ្នំ (ព្រៃវែង) ។ ក្នុងរយៈពេល ៤ ឆ្នាំ ព្រះអង្គបានតស៊ូរហូតកំចាត់សៀមបាននៅឆ្នាំ១៤៧៧ ។

**នាយកនដណ្ដើមរាជ្យ :—** ព្រះបាទធម្មោរាជាសុគតទៅ ព្រះរាជបុត្រព្រះអង្គព្រះនាមសុគន្ធបទ ឬ ដាំខាត់សុគន្ធរ បានឡើងគ្រងរាជ្យ (១៤៩៤-១៤៩៨) ។ ព្រះអង្គទ្រង់គង់នៅបាសាន (ស្រីសន្ធរ) ព្រះអនុជព្រះអង្គព្រះនាមចន្ទរាជាទ្រង់គង់នៅឯចតុមុខ ។ ក្នុងរជ្ជកាលនោះមានការជ្រួលច្របល់មួយបង្ករឡើងដោយនាយកន ។

នាយកន ជាពលព្រះ ឆ័រជា "ស្ដេចហ្លួង" ។ ដោយប្រើអំណាចហួសពេក ដឹងខ្លួនថាខុស ខ្លាចស្ដេចយកទោស ហ្លួងកនគេចខ្លួនទៅបង្ករទ័ព ហើយឃោសនាថា ព្រះបាទសុគន្ធបទឲ្យខ្លួនរកចាប់ព្រះអង្គចន្ទរាជា ។ ព្រះអង្គចន្ទរាជាទ្រង់និកភ័យ ក៏កៀសព្រះអង្គទៅស្រុកសៀមទៅ ។

*នៅឆ្នាំ ១៥០៥ នាយកនធ្វើបម្បាងនឹងព្រះមហាក្សត្រ ហើយបាន ទាំងធ្វើគតព្រះអង្គនៅកំពុងស្វាយ (កំពង់ធំ) ។ ពីឆ្នាំ ១៤៩៨ ដល់ឆ្នាំ ១៥០៥ ស្ដេចកនសោយរាជ្យ ហើយតាំងទីក្រុងនៅស្រឡប់ឃ្មុំ ។*

–oOo–

**សេចក្ដីសង្ខេប** :– ព្រះរាជបុត្រព្រះបាទចៅពញាយ៉ាត ព្រះនរាយណ៍រាមា ព្រះស្រីរាជា និង ព្រះធម្មោរាជាបានគ្រងរាជ្យជាបន្តបន្ទាប់គ្នា ។

ក្នុងរជ្ជកាលព្រះបាទស្រីរាជា សៀមចូលលុក ហើយយកបានក្រពំត អង្គរ និង ចន្ទបូរហើយបានទាំងចាប់ព្រះអង្គបានផង ។ ព្រះអង្គសុគតនៅស្រុកសៀម ។ ឯព្រះ រាជបុត្រព្រះអង្គព្រះនាមចៅពញាអុងត្រូវសៀមឃាំងទុក ។

ព្រះបាទធម្មោរាជា ព្រះអង្គតយុទ្ធកំចាត់សៀមទៅវិញបាននៅឆ្នាំ ១៤៧៧ ។ ព្រះ អង្គឡើងគ្រងរាជ្យរហូតដល់ឆ្នាំ ១៤៩៤ ។

អំណើះពីព្រះអង្គមក ព្រះរាជបុត្រព្រះអង្គព្រះនាម សុគន្ធបទ ឡើងគ្រងរាជ្យ (១៤៩៤-១៥០៥) ។ ព្រះអនុជព្រះអង្គព្រះនាមចន្ទរាជា ចាញ់ឧបាយកលនាយកន ក៏ ភៀសព្រះអង្គទៅប្រទេសសៀម ។ បន្ទាប់មក នាយកនបង្ករទ័ពច្បាំងនឹងព្រះរាជា ។ លុះធ្វើគតព្រះអង្គបាននៅឆ្នាំ ១៥០៥ នាយកនឡើងសោយរាជ្យរហូតដល់ឆ្នាំ ១៥១៥ ។

**សំណួរ** :– ព្រះរាជបុត្រព្រះបាទពញាយ៉ាតព្រះនាមអ្វី ? ក្នុងរជ្ជកាលព្រះរាជាណា ដែល មានសៀមចូលលុក ? ព្រះរាជាអង្គណា ដែលបានកំចាត់សៀមទៅវិញ ? ហេតុម្ដេច បានជាព្រះអង្គចន្ទរាជាយាងទៅស្រុកសៀម ? នាយកនដណ្ដើមរាជ្យក្នុងរជ្ជកាលព្រះ រាជាណា ? ស្ដេចកនសោយរាជ្យបានប៉ុន្មានឆ្នាំ ?

* * *

# ២៥- ព្រះបាទអង្គចន្ទទី ១ - ព្រះបាទបរមិន្ទរាជា

## « ចម្បាំងនឹងសៀម - ចម្បាំងនឹងលាវ »

ព្រះចៅពញាច័ន្ទរាជា ឬព្រះបាទអង្គចន្ទទី ១ (១៥០៥-១៥៥៦)

**ព្រះអង្គចន្ទរាជាយាងមកកាន់កម្ពុជាវិញ :—** តាំងពីបាញ់កលស្ដេចកន ព្រះអង្គទ្រង់គង់នៅឯស្រុកសៀម ។ លុះព្រះអង្គទ្រង់បានជ្រាបថា ស្ដេចកនបានធ្វើគតព្រះបាទស្រីសុគន្ធបទ ព្រះអង្គទ្រង់សុំព្រះរាជានុញ្ញាតពីស្ដេចសៀម ដើម្បីត្រឡប់មកកាន់មាតុប្រទេសវិញ តែព្រះចៅសៀមពុំព្រមៗ ព្រះអង្គចន្ទរាជាទ្រង់ប្រើឧបាយ ដោយឲ្យផ្សាយថា នៅកម្ពុជាមានដំរីសៗ បើបានដំរីនោះ ព្រះចៅសៀមក៏បាត់ព្រះអង្គរាជាឲ្យមករកចាប់ ។

លុះយាងមកដល់កម្ពុជា ព្រះអង្គទ្រង់បានចាប់ផ្ដើមច្បាំងនឹងស្ដេចកន រហូតដល់សម្លាប់ស្ដេចកនបាននៅសំរោង (ព្រៃនគរ) ទើបព្រះអង្គឡើងគ្រងរាជ្យ ហើយតាំងព្រះរាជធានីនៅលង្វែក ។

**ចម្បាំងនឹងសៀម:—** មូលហេតុនៃចម្បាំងគឺ ស្ដេចសៀមទាមទារឲ្យព្រះបាទអង្គចន្ទថ្វាយដំរីស ។ សៀមចាប់ផ្ដើមវាតត្បាតដំបន់អង្គរ ។ តែទ័ពសៀម ត្រូវទ័ពព្រះបាទអង្គចន្ទវាយបរាជ័យទៅវិញនៅសៀមរាប ។

បន្ទាប់មកទៀត ព្រះចៅសៀម ឲ្យព្រះចៅពញាអុងដែលសៀម

យាំងទុកមកច្បាំងដណ្ដើមរាជ្យដោយមានទ័ពសៀមជាកំលាំង ។

ជំបូងភ្លាម នៅឆ្នាំ ១៥៣២ សៀមយកបានលង្វែក ។ តែដោយសៀមចង់យកប្រទេសទាំងមូល សៀមក៏បញ្ចូលទ័ពមកទៀតតាមជើងគោកផង ជើងទឹកផង ។ តែទាំងជើងគោក ទាំងជើងទឹក ទ័ពសៀមត្រូវបរាជ័យទៅវិញ ហើយព្រះអង្គអុងក៏សុគតក្នុងចម្បាំងនោះដែរ ។

**ស្នាព្រះហស្ត** :– ក្រៅពីចម្បាំងនឹងសៀម ព្រះអង្គបានពង្រីកសេដ្ឋកិច្ចដោយឲ្យធ្វើអាជីវកម្មយករ៉ែដែក ពង្រីកដីសម្រាប់ដំណាំ ។ ព្រះអង្គបានសាងវត្តអារាមជាច្រើន ។ ព្រះអង្គបានសាងសន្តិភាពក្នុងប្រទេស និងក្រៅប្រទេស ។

**ព្រះបាទបរមិន្ទរាជា ឬ បរមរាជា (១៥៥៥-១៥៦៧)** :– លុះព្រះបាទអង្គចន្ទសុគតទៅ ព្រះរាជបុត្រព្រះអង្គឡើងគ្រងរាជ្យ ហើយទ្រង់ព្រះនាមថា ព្រះបាទបរមិន្ទរាជា ។ ក្នុងរជ្ជកាលព្រះអង្គមានចម្បាំងពីរ គឺចម្បាំងនឹងសៀម ហើយនិងលាវ ។

**ចម្បាំងនឹងសៀម** :– នៅឆ្នាំ ១៥៥៧ សៀមជាប់ដៃច្បាំងនឹងភូមា ។ ឆ្លៀតឱកាសនោះ ព្រះបាទបរមិន្ទរាជា ព្រះអង្គទ្រង់លើកទ័ពទៅវាយសៀម យកបានខេត្តចន្ទបូរ ( ចន្ទបុ៊ន ) និងនគររាជ (គូរ៉ាត) ។

នៅឆ្នាំ ១៥៦២ សៀមលើកទ័ពមកវាយប្រាថ្នាកំចាត់ខ្មែរនៅខេត្តខាងលិច មានខេត្តចន្ទបុរីជាដើម ។ តែការសងសឹករបស់ព្រះបាទបរមិន្ទរាជា បានធ្វើឲ្យសៀមសុំធ្វើសន្ធិសញ្ញា រាជមេត្រីនៅឆ្នាំ១៥៦៧ ។

**ចម្បាំងនឹងលាវ :–** មូលហេតុនៃចម្បាំង គឺស្តេចលាវបានយកដំរីមកប្រជល់គ្នាល់ បើដំរីស្តេចអង្គណាចាញ់ ស្តេចនោះត្រូវនៅជាស្តេចបំណុះ ។ លុះដំរីលាវចាញ់ ស្តេចលាវមិនព្រមចុះចាញ់ ក៏លើកទ័ពមកវាយខ្មែរ ។ តែព្រះបាទបរមិន្ទរាជា ព្រះអង្គបានកំចាត់ទ័ពលាវដែលចូលមកដល់ភ្នំសន្ទុក ឲ្យខ្ចាត់ខ្ចាយទៅវិញនៅឆ្នាំ ១៥៦១ ។ នៅឆ្នាំ ១៥៦៦ លាវបាននាំទ័ពមកតាមទន្លេ មកដល់រកាកោង ។ ម្តងនេះ ទ័ពលាវក៏ត្រូវបរាជ័យដូចមុនទៀត ។

—oOo—

**សេចក្តីសង្ខេប :–** លុះស្តេចកនធ្វើគតព្រះបាទសុគន្ធបទហើយ ក៏ព្រះចៅសៀមមិនព្រមអនុញ្ញាតិឲ្យព្រះអង្គចន្ទយាងត្រឡប់មកស្រុកខ្មែរវិញទេ ។ ដូច្នោះទើបព្រះអង្គទ្រង់ប្រើឧបាយកលដោយឲ្យផ្សាយថា នៅកម្ពុជាមានដំរីស ។ ចង់បានដំរី ស្តេចសៀមក៏ចាត់ព្រះអង្គឲ្យរកទាក់ ។

មកដល់មាតុប្រទេស ដំបូងបង្អស់ ព្រះអង្គទ្រង់ច្បាំងនឹងស្តេចកន ដែលព្រះអង្គសម្លាប់បាននៅឆ្នាំ ១៥០៥ ។ បន្ទាប់មកព្រះអង្គត្រូវច្បាំងនឹងសៀម ដែលចូលលុកលុយដោយសំអាងលេសថា ព្រះអង្គមិនព្រមថ្វាយដំរីស តែទ័ពសៀមត្រូវបរាជ័យទៅវិញ ។ ព្រះអង្គម្ចាស់អុងដែលជាមេទ័ពខាងសៀមក៏សុគតក្នុងចម្បាំងនោះដែរ ។

លុះព្រះអង្គសុគតទៅ នៅឆ្នាំ ១៥៥៥ ព្រះរាជបុត្រព្រះអង្គព្រះនាមបរមិន្ទរាជាឡើង

គ្រងរាជ្យ ។ នៅឆ្នាំនោះ ឆ្លៀតឱកាសដែលសៀមកំពុងជាប់ចម្បាំងនឹងភូមា ព្រះបាទបរមិន្ទរាជា ព្រះអង្គលើកទ័ពទៅវាយសៀមចូលដល់ក្រុងអយុធ្យា ហើយយកបានចន្ទបុរ និងក្រាត ។

ក្រោយទៀត លាវបានលើកទ័ពចូលមកកម្ពុជាយើងពីរលើក តែត្រូវបរាជ័យទៅវិញ។

**សំណួរ**:– លុះស្ដេចកនធ្វើគតព្រះបាទសុគន្ធបទហើយ ហេតុម្ដេចបានជាព្រះអង្គចន្ទរាជាយាងមកកម្ពុជាភ្លាម ? ទ្រង់ធ្វើយ៉ាងម្ដេចទើបយាងមកបាន ? មកដល់កម្ពុជា ព្រះអង្គទ្រង់ធ្វើអ្វីជាបឋម ? ហេតុអ្វីបានជាព្រះអង្គមានរឿងចំប្បាំងនឹងសៀម ? ចម្បាំងនោះមានលទ្ធផលយ៉ាងណា ? នៅឆ្នាំ ២៥៥៥ ហេតុម្ដេចបានជាព្រះបាទបរមិន្ទរាជាធ្វើចម្បាំងនឹងសៀម ? ចម្បាំងនោះបានលទ្ធផលយ៉ាងម្ដេច ? ចម្បាំងនឹងលាវបានលទ្ធផលយ៉ាងម្ដេចដែរ ?

* * *

## ២៦– ព្រះបាទសត្ថាទី១

### « សៀមវាយបន្ទាយលង្វែកបាន »

**រជ្ជកាលព្រះបាទសត្ថាទី១ (១៥៦៧-១៥៧៤)** – *ព្រះបាទសត្ថាទី ១ ព្រះអង្គត្រូវជាព្រះរាជបុត្រព្រះបាទបរមិន្ទរាជា ឬព្រះបរមរាជា ហើយបានឡើងគ្រងរាជ្យនៅកាលដែលព្រះវរបិតាព្រះអង្គសុគតទៅ ។ ក្នុងរជ្ជកាលព្រះអង្គ ខាងនយោបាយ មានការគ្រាំគ្រងធំ ១ពីរ : មួយ គឺការជួយសៀមក្នុងការវាយភូមា ពីរ គឺការដែលព្រះអង្គដាក់រាជ្យដើម្បីព្រះរាជបុត្រដែលមានព្រះជន្មតិចពេក ។*

**ព្រះបាទសត្ថាទី ១ ជួយសៀមដើម្បីវាយភូមា:—** កាលនោះប្រទេសសៀម ត្រូវពួកភូមា ចូលវាតត្បាត ។ សៀមមកសុំខ្មែរឲ្យជួយ ។ ព្រះបាទសត្ថា ទី ១ ព្រះអង្គបានចាត់ព្រះស្រីសុរិយោពណ៌ដែលមានព្រះរាជនាទីជាព្រះឧបរាជ និងជាព្រះអនុជព្រះអង្គ ឲ្យលើកទ័ពទៅជួយសៀម ។ ច្បាំងបានជោគជ័យលើភូមាហើយ មិនអរគុណនឹងជំនួយខ្មែរ ស្តេចសៀមបែរជាហ៊ានប្រមាថមើលងាយព្រះឧបរាជ ព្រះស្រីសុរិយោពណ៌ ទុកដូចជាស្តេចចំណុះ ។

ដូច្នេះទើបដល់ក្រោយមក មិនយូរប៉ុន្មាន សៀមត្រូវភូមាវាយម្តងទៀត ខ្មែរក៏បានឆ្លៀតក្នុងឱកាសនោះ លើកទ័ពទៅវាយសៀមក្នុងខេត្តខ្លះ ។

**ព្រះបាទសត្ថាទី ១ ទ្រង់ដាក់រាជ្យដើម្បីព្រះរាជបុត្រព្រះអង្គ:—** នៅឆ្នាំ ១៥៧៨ (១) ព្រះបាទសត្ថាទី ១ ព្រះអង្គដាក់រាជ្យដើម្បីព្រះរាជបុត្រព្រះអង្គ ដែលឡើងគ្រងរាជ្យ ទ្រង់ព្រះនាមថា ព្រះបាទជ័យជេដ្ឋាទី១ ឬព្រះជ័យចេស្តា ( ១៥៧៨-១៥៩៣ ) ហើយដែលមានព្រះជន្មតែ ១០វស្សា ។ ការដាក់រាជ្យរបស់ព្រះអង្គនេះបានបង្កើតឲ្យមានការមិនពេញចិត្តច្រើនក្នុងចំណោមនាម៉ឺនមុខមន្ត្រី ។

**សៀមវាយយកបន្ទាយលង្វែកបាននៅឆ្នាំ១៥៩៣ :—** នៅឆ្នាំ ១៥៧៦

---

(១) អ្នកស្រីហ្សឺតូជា ១៥៨៤ ។

វង្គាតិបាលសៀមចូលមកយកខេត្តកូរ៉ាត និងបន្តប្តូរទៅកាន់កាប់ ។

នៅឆ្នាំ ១៥៨១ ស្តេចសៀម ព្រះចៅនរេសួន បានបញ្ជូនទ័ពយ៉ាង សម្បើមមកវាយខ្មែរ មាន ១៥០ ០០០នាក់ ដំរី៨០០ សេះ ១៨៥០ ។ ទ័ពសៀមចូលដល់ខេត្តបាត់ដំបង ពោធិសាត់ អង្គរ រលៀផ្អៀ និង បរិបូណ៌ (កំពង់ឆ្នាំង) ។ តែកាលនោះ ព្រះមហាក្សត្រខ្មែរ ព្រះបាទ ព្រះជ័យជេដ្ឋាធិរាជ ព្រះអង្គបានវាយកំចាត់សៀមឲ្យថយទៅវិញបាន ។

នៅឆ្នាំ ១៥៩៣(១) សៀមលើកទ័ពមកម្តងទៀត វាយខាងកំពង់ស្វាយ ខាងទន្លេសាប ហើយទីបំផុតយកលង្វែកបាន ។

នៅពេលនោះ ព្រះសត្ថា និងព្រះបាទជ័យជេដ្ឋាទី ១ ស្តេចទ្រង់ភៀសព្រះអង្គយាងទៅខេត្តស្ទឹងត្រែង ហើយសុគតនៅទីនោះទៅ ។ ព្រះស្រីសុរិយោពណ៌ ដែលជាព្រះឧបរាជ និងព្រះញាតិវង្សឯទៀត ត្រូវសៀមនាំទៅប្រទេសសៀម ។ មនុស្សប្រមាណ៩០ ០០០នាក់ ក៏ត្រូវសៀមចាប់ជាឈ្លើយ ។ ឯក្បួនខ្នាត ឯកសារផ្សេងៗច្រើនទៀត ក៏ត្រូវបានសៀមប្រមូលទៅអស់ ។

## ព្រះបាទរាមាជើងព្រៃ ( ១៥៩៤-១៥៩៦ ) ទ្រង់កំចាត់សៀមពីលង្វែកៈ-

នៅពេលនោះ មានក្សត្រមួយអង្គព្រះនាមរាមាជើងព្រៃ បានកេណ្ឌទ័ពទៅវាយសៀមនៅលង្វែកយ៉ាងអង់អាចក្រៃលែង ។ ព្រះអង្គបានសម្លាប់

(១) ឯកសារខ្ទះបារាំង នៅឆ្នាំ ១៥៩៣ ។

មេទ័ពសៀម និងបំផ្លាញឲ្យវិនាសអស់ពួកពលប្រមាណ ២០០០០នាក់ ។ បន្ទាប់ពីបានជោគជ័យ ព្រះអង្គឡើងគ្រងរាជ្យ ហើយទៅគង់នៅស្រីសន្ធរ ។

—oOo—

**សេចក្ដីសង្ខេបៈ** – ព្រះបាទសត្ថា (១៥៦៨-១៥០៥) ត្រូវជាព្រះរាជបុត្រព្រះបាទបរមិន្ទរាជាឬបរមរាជា ។ ក្នុងរជ្ជកាលព្រះអង្គ ខាងនយោបាយមានការភ្លាំភ្លងធំ ៗ ពីរ ។ មួយ គឺព្រះអង្គបានទៅជួយសៀមដើម្បីវាយភូមា ពីរ គឺព្រះអង្គបានដាក់រាជ្យ ដើម្បីព្រះរាជបុត្រដែលមានព្រះជន្មតែ ១០ ព្រះវស្សា ។

នៅឆ្នាំ ១៥៨១ និងឆ្នាំ ១៥៩៣ សៀមបានលើកទ័ពយ៉ាងសម្បើមដើម្បីវាយខ្មែរ ។ លើកទី ១ ទ័ពសៀមបរាជ័យទៅវិញ ដោយត្រូវព្រះបាទជ័យជេដ្ឋាវាយតប ។ លើកទី ២ សៀមចូលយកលង្វែកបាន ។ គ្រានោះ ព្រះសត្ថា និងព្រះបាទជ័យជេដ្ឋា ស្ដេចទ្រង់ភៀសព្រះអង្គទៅខាងស្ទឹងត្រែង ហើយសុគតនៅទីនោះទៅ ។ ព្រះស្រីសុរិយោពណ៌ ដែលជាព្រះឧបរាជព្រមទាំងព្រះញាតិវង្ស ត្រូវសៀមនាំទៅប្រទេសសៀម ។ មនុស្សប្រមាណ ៩០០០០នាក់ ត្រូវសៀមចាប់ជាឈ្លើយ ។ ក្បួនខ្នាត និងឯកសារផ្សេង ៗ ត្រូវសៀមប្រមូលយកអស់ ។

ពេលនោះ មានក្សត្រមួយអង្គព្រះនាមរាមាជើងព្រៃ បានកេណ្ឌទ័ពយ៉ាងសម្ងាត់ទៅវាយសៀមឲ្យខ្ចាត់ខ្ចាយពីលង្វែកចេញ ។ បន្ទាប់មកនៅឆ្នាំ ១៥៩៤ ព្រះអង្គឡើងគ្រងរាជ្យហើយគង់នៅស្រីសន្ធរ ។

**សំណួរ** :— ក្នុងរជ្ជកាលព្រះបាទសត្ថា មានការភ្លាំភ្លងអ្វីខ្លះ ខាងនយោបាយ? ការទៅជួយសៀមនាំឲ្យខុសយ៉ាងម្ដេច? ការដាក់រាជ្យរបស់ព្រះបាទសត្ថានាំឲ្យខុសយ៉ាងម្ដេច? ក្នុងរជ្ជកាល ព្រះបាទជ័យជេដ្ឋា មានចម្បាំងនឹងសៀមប៉ុន្មានលើក? ចម្បាំងមួយលើក ៗ មានលទ្ធផលយ៉ាងម្ដេច? ស្ដេចណាដែលបានកំចាត់សៀមចេញពីលង្វែកទៅវិញ?

## ២៧– ជនជាតិពរទុយហ្គ និងអេស្ប៉ាញ៉ុលមកកម្ពុជា

**ក្នុងរឿង "លង្វែក":–** ជនពរទុយហ្គ និងអេស្ប៉ាញ៉ុល ធ្លាប់មានការទាក់ទងនឹងកម្ពុជា តាំងពីរជ្ជកាលព្រះបាទអង្គចន្ទទី ១ ក្នុងបំណងផ្សាយគ្រិស្តសាសនា និងធ្វើជំនួញ ។ ព្រះសត្ថា ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យណាស់នឹងជនជាតិពរទុយហ្គម្នាក់ឈ្មោះ វេលោសូ (Véloso) និងជនជាតិអេស្ប៉ាញ៉ុលឈ្មោះ រូអ៊ីស (Ruiz) ។ ព្រះអង្គបានលើកព្រះអង្គក្សត្រីមួយអង្គឲ្យធ្វើជាភរិយាដល់វេលោសូ និងលើករូអ៊ីសឲ្យធ្វើជាព្រះរាជអង្គរក្ស ។ ក្នុងសម័យដែលសៀមវាយលង្វែក ជនទាំងនោះបានជួយយកអាសារព្រះរាជាខ្មែរ ក្នុងការទប់ទល់នឹងសៀម រហូតដល់សៀមចាប់ខ្លួនបានជាឈ្លើយនាំយកទៅក្រុងអយុធ្យា ។

**ក្នុងរឿងធ្វើគតព្រះបាទរាមាជើងព្រៃ(១) :–** ក្នុងរជ្ជកាលព្រះបាទរាមាជើងព្រៃ វេលោសូ និងរូអ៊ីស បានរួចពីកណ្ដាប់ដៃសៀម ហើយបានចូលមកកម្ពុជាទៀត ។ មានថ្ងៃមួយ ដោយមានការវិវាទរវាងពួកខ្លួន និងពួកចិន វេលោសូបានសូមចូលគាល់ព្រះរាជាដើម្បីធ្វើយុត្តិកម្ម ។ ទោមនស្សនឹងព្រះអង្គដែលមិនបើកឲ្យចូលគាល់តាមចិត្តខ្លួន វេលោសូ និងរូអ៊ីសនាំគ្នាហានទៅវាយប្រហារព្រះរាជវាំងនៅស្រីសន្ធរ ។ ក្នុងពេល

(១) តាមពង្សាវតារនៃប្រទេសកម្ពុជា ថា វេលោសូ និង រូអ៊ីស បានធ្វើគតព្រះបាទរាមាជើងព្រៃដើម្បីយករាជ្យថ្វាយព្រះពញាតន់ ។

នោះ ព្រះបាទរាមាជើងព្រៃក៏បានសោយទិវង្គតទៅ ។ ឯចំណែកពួកបរទេសទាំងឡាយក៏បាននាំគ្នាចាកចេញពីកម្ពុជា ឆ្ពោះទៅកាន់ចំប៉ា តុងកឹង រួចខ្លះក៏ត្រឡប់ទៅម៉ានីលវិញ ខ្លះត្រឡប់មកខាងលាវ ។

**ក្នុងរជ្ជកាលព្រះបាទពញាតន់ (១៥៩៦-១៥៩៧) :—** ចំណែកវេលោសូ និងរីយូស ទៅដល់តុងកឹង ក៏បានត្រឡប់មកខាងលាវ ។ នៅទីនោះ វេលោសូ និងរីយូស បានជួបនឹងព្រះពញាតន់ជាព្រះរាជបុត្រទី ២ នៃព្រះបាទសត្ថា ហើយបានដឹងពីការសោយទិវង្គតនៃព្រះសត្ថា និងព្រះបាទជ័យជេដ្ឋា ។ វេលោសូ និងរីយូស ក៏ទូលព្រះពញាតន់ ពីព្រឹត្តិការណ៍ដែលទើបនឹងកន្លងទៅនៅកម្ពុជា ហើយក៏ដង្ហែព្រះពញាតន់មកស្រីសន្ធរ ដើម្បីគ្រងរាជ្យ ។

លុះព្រះអង្គបានគ្រងរាជ្យហើយ ព្រះបាទពញាតន់បានតាំងវេលោសូ ជាចៅហ្វាយខេត្តនៅបាភ្នំ ហើយរីយូស ជាចៅហ្វាយខេត្តនៅត្រាំង ។ ដោយអ្នកទាំងពីរនោះធ្លាប់មានថ្វីដៃ ក្នុងការបង្ក្រាបចាមនៅត្បូងឃ្មុំ ព្រះអង្គក៏បានចាត់ឲ្យទៅបង្ក្រាបពួកចាមដែលប្រឆាំងនឹងពួកអេស្ប៉ាញ៉ុល ។ តែវេលោសូ និងរីយូស ត្រូវពួកបះបោរសម្លាប់បានទាំងពីរនាក់ ។ ដើម្បីសងសឹកជួសវេលោសូ និងរីយូស ព្រះរាជាទ្រង់ចេញបង្ក្រាបផ្ទាល់ព្រះអង្គ តែពួកបះបោរបានធ្វើគតព្រះអង្គទៅទៀត ។

**ព្រះបាទពញាអាន (១៥៩៧-១៥៩៩) :—** បន្ទាប់ពីព្រះបាទពញាតន់មក

ព្រះពញាកាន ដែលត្រូវជាព្រះបិតុលាព្រះអង្គ ឡើងគ្រងរាជ្យ ។ កាលនោះមានការបះបោរបន្តរឡើង ដោយមានមេម្នាក់ឈ្មោះកែវ ។ ដើម្បីបង្ក្រាបពួកទាំងនោះ ព្រះអង្គបានសុំជំនួយពីពួកអេស្ប៉ាញ៉ុលនៅម៉ានីល ។ តែនៅឆ្នាំ ១៦០០ ព្រះអង្គត្រូវសុគតក្នុងការឡោមស្ទាក់នៃពួកបះបោរ ។

តាំងពីនោះមក ការទាក់ទងជាផ្លូវការរវាងកម្ពុជា និងជនបស្ចិមប្រទេសក៏ឈប់លែងមាន ។ តែក្នុងសតវត្សទី ១៧ ជនអស់នេះក៏ចេះតែមកថែមទៀតដែរ ។ ព្រះវិហារកាតូលិកនៅពញាឮ បានកើតឡើងតាំងពីសម័យនោះ ។

—oOo—

**សេចក្តីសង្ខេប** :— ជនជាតិពរទុយហ្គេ និងអេស្ប៉ាញ៉ុល បានចូលមកស្រុកខ្មែរ តាំងពីរជ្ជកាលព្រះបាទអង្គចន្ទទី ១ ។ ពួកនេះបានជួយយកអាសារព្រះរាជាខ្មែររៀងៗមក ។ តែក្នុងរជ្ជកាលព្រះបាទរាមាជើងព្រៃ ពួកបរទេសទាំងនេះបានប្រព្រឹត្តអំពើឆ្គាំឆ្គងយ៉ាងខ្លាំងទៅលើព្រះមហាក្សត្រ ។ មូលហេតុគឺពួកនេះ បានរំលោភទៅលើចិននៅចតុមុខ ហើយសុំចូលគាល់ព្រះរាជា ។ ខឹងនឹងព្រះរាជាមិនអនុញ្ញាតិឲ្យចូលគាល់ ពួកទាំងនោះបាននាំគ្នាទៅវាយប្រហារព្រះរាជវាំង ហើយធ្វើឲ្យព្រះបាទរាមាជើងព្រៃសោយទីវង្គតក្នុងពេលនោះទៅ ។

ក្រោយមក វេលោសូ និងរ៉ូអ៊ីសបានទៅស្រុកលាវ ហើយបានជួបនឹងព្រះពញាតន់ដែលត្រូវជាព្រះរាជបុត្រព្រះសត្ថា ។ វេលោសូ និងរ៉ូអ៊ីសក៏បានដង្ហែព្រះអង្គមក

គ្រងរាជ្យ ។ ព្រះបាទពញាគន់ ព្រះអង្គបានតាំងវរលោអេ្យា និងរីអ្យ ទាំងពីរនាក់ជាចៅហ្វាយខេត្ត ។ តែតមកទៀត វរលោអេ្យា រីអ្យ និងព្រះបាទពញាគន់ បានក្ស័យ និងសោយទីវង្គតក្នុងការបង្ក្រាបការបះបោរ ។ ព្រះបាទពញាអាន ដែលសោយរាជ្យក្រោយព្រះអង្គ ក៏បានសុគតក្នុងការបង្ក្រាបពួកបះបោរដែរ ។

សំណួរៈ— ជនជាតិពរទុយហ្គេ និងអេស្ប៉ាញ៉ុល បានចូលមកស្រុកខ្មែរតាំងពីរជ្ជកាលស្តេចអង្គណា? ពួកអស់នេះមានការទាក់ទងនឹងព្រឹត្តិការណ៍ណាខ្លះ ក្នុងប្រវត្តិសាស្ត្រយើង? ព្រះបាទរាមាជើងព្រៃសុគតដោយហេតុអ្វី? ហេតុម្តេចបានជាវរលោអេ្យា និងរីអ្យទៅជួបនឹងព្រះពញាគន់នៅឯស្រុកឈាវ ? ហេតុអ្វីបានជាវរលោអេ្យា និងរីអ្យបានតាំងជាចៅហ្វាយខេត្ត? ហេតុយ៉ាងម្តេចបានជាវរលោអេ្យា និងរីអ្យស្លាប់? ចុះព្រះបាទពញាគន់? ព្រះរាជាអង្គណាដែលសោយរាជ្យបន្ទាប់ពីព្រះបាទពញាគន់?

* *

*

# ២៨–ព្រះបាទស្រីសុរិយោពណ៌–ព្រះបាទជ័យជេដ្ឋាទី២

## «ព្រៃនគរបានទៅយួន»




**ព្រះបាទស្រីសុរិយោពណ៌** *(១៦០០ - ១៦១៨) :– កាលព្រះបាទពញាអាន*

*ទ្រង់សុគតទៅ ព្រះរាជបុត្រព្រះសត្ថាទី ១ មួយអង្គ ព្រះនាមពញាយុម*

ទ្រង់ឡើងសោយរាជ្យ (១៥៩៩-១៦០០) ។ ព្រះអង្គមានព្រះវរមាតាជាតិលាវ ។ នាម៉ឺនមន្ត្រីទាំងឡាយពុំសូវពេញចិត្តនឹងព្រះអង្គទេ ។ អ្នកទាំងនោះបានសុំព្រះស្រីសុរិយោពណ៌ ដែលសៀមចាប់ទៅ កាលសៀមវាយលង្វែកបាន ឲ្យមកគ្រប់គ្រងរាជ្យវិញ ។ នៅឆ្នាំ ១៦០០ ព្រះចៅសៀមក៏បានយល់ព្រមឲ្យព្រះអង្គយាងមកកាន់កម្ពុជា ដោយឲ្យពលរេហ៍ហែហមព្រះអង្គមកផង ។ តែព្រះបាទពញាយ៉ុមមិនព្រមដាក់រាជ្យ ហើយបានបំបះបំបោរអ្នកស្រុកនៅដីក្រែង និងកំពង់ស្វាយ ឲ្យប្រឆាំងនឹងព្រះស្រីសុរិយោពណ៌ នៅទីបំផុត ព្រះស្រីសុរិយោពណ៌បានវាយពួកបះបោរខ្ចាត់ខ្ចាយអស់ ហើយចាប់បានទាំងព្រះបាទពញាយ៉ុមមកធ្វើគតទៀត ។ ព្រះបាទស្រីសុរិយោពណ៌ឡើងគ្រងរាជ្យ គង់នៅឯល្វាឯមជាព្រះរាជធានី ។

**ព្រះបាទជ័យជេដ្ឋាទី ២** (១៦១៨-១៦២៨) **យួនបានព្រៃនគរ បារៀនិងបៀងហ្វា** :– នៅឆ្នាំ ១៦១៨ ព្រះបាទស្រីសុរិយោពណ៌ ព្រះអង្គទ្រង់ដាក់រាជ្យ ដើម្បីព្រះរាជបុត្រច្បងរបស់ព្រះអង្គ ព្រះនាមជ័យជេដ្ឋាទី២ ។

នៅឆ្នាំ ១៦២០ ព្រះបាទជ័យជេដ្ឋាទី ២ ព្រះអង្គទ្រង់ផ្លាស់ព្រះរាជធានីពីល្វាឯមទៅឧដុង្គ ។ នៅក្នុងឆ្នាំជាមួយនោះ ព្រះរាជាប្រទេសយួនដង្ហែព្រះរាជបុត្រីមួយព្រះអង្គ ប្រកបដោយរូបឆោមលោមពណ៌ មកថ្វាយព្រះបាទជ័យជេដ្ឋាទី ២ ធ្វើជាមហេសី ។

កាលនោះ សៀម ដើម្បីប្រដែងឥទ្ធិពលខ្លួនមកលើកម្ពុជា ក៏លើកទ័ពមកវាយខ្មែរពីរលើក ក្នុងឆ្នាំ ១៦២៣ ។ តែទ័ពសៀមបានទទួលបរាជ័យ នៅបរិបូណ៌ ដោយស្នាព្រះហស្តព្រះបាទជ័យជេដ្ឋាទី ២ និងនៅបន្ទាយមាស ដោយស្នាព្រះហស្តព្រះឧទ័យដែលជាព្រះអនុជ ។

នៅឆ្នាំដដែលនោះ ព្រះរាជាយួនបានចាត់គណៈប្រតិភូមួយ មកឧដុង្គដើម្បីសុំព្រះរាជានុញ្ញាតិឲ្យជនជាតិយួនតាំងទីលំនៅ នៅភាគខាងត្បូងនៃកម្ពុជា គឺដំបន់ព្រៃនគរ បារៀ និងបៀងហ្វា ។ បន្ទាប់ពីការយល់ព្រមនៃព្រះមហាក្សត្រខ្មែរ យួន ដោយសំអាងថា ជាជំនួយដល់ចៅហ្វាយខេត្តខ្មែរ ក៏តាំងឧត្តមសេនីយយួនម្នាក់នៅព្រៃនគរ ។ លុះព្រះបាទជ័យជេដ្ឋាសុគតទៅ ព្រៃនគរ បារៀ និងបៀងហ្វាក៏បានទៅយួន ។

—oOo—

**សេចក្ដីសង្ខេបៈ** — បន្ទាប់ពីព្រះបាទពញាអាន ព្រះរាជទាយាទ គឺព្រះស្រីសុរិយោពណ៌ ។ តែដោយព្រះអង្គគង់នៅឯសៀម ព្រះពញាយុមក៏ឡើងគ្រងរាជ្យ ។ លុះព្រះស្រីសុរិយោ-ពណ៌បានយាងមកវិញ ព្រះបាទពញាយុមមិនព្រមចុះចូលព្រះអង្គ ។ ក្នុងការបង្ក្រាប ព្រះអង្គក៏ចាប់បានព្រះអង្គយុមយកទៅធ្វើគត ។ ព្រះអង្គតាំងព្រះរាជធានីនៅឯល្វាឯម (ខេត្តកណ្ដាល) ។

នៅឆ្នាំ ១៦១៨ ព្រះបាទស្រីសុរិយោពណ៌ ព្រះអង្គដាក់រាជ្យ ដើម្បីព្រះរាជបុត្រព្រះអង្គព្រះនាមជ័យជេដ្ឋាទី ២ ។ ព្រះបាទជ័យជេដ្ឋាទី ២ ព្រះអង្គបានតាំងព្រះរាជធានីនៅឧដុង្គ ។ ព្រះអង្គមានព្រះមហេសី ដែលត្រូវជាព្រះរាជបុត្រីនៃព្រះរាជាយួន ។

នៅឆ្នាំ ១៦២៣ ព្រះអង្គទ្រង់គង់នៅក្នុងភាគពូកិច្ចមួយ ដែលបង្ខំឲ្យព្រះអង្គព្រមអនុញ្ញាតិឲ្យយួនតាំងនៅភាគខាងត្បូងនៃកម្ពុជា ព្រៃនគរ បារៀ និងបៀងហ្វា ដែលយួនយករហូតមក ។

សំណួរ :– ក្សត្រណា ដែលត្រូវជាព្រះរាជទាយាទនៃព្រះបាទពញាអាន ? ឱកាសយ៉ាងម្តេច បានជាព្រះបាទពញាយ៉ុមឡើងគ្រងរាជ្យបាន ? ហេតុម្តេច បានជាព្រះបាទស្រីសុរិយោពណ៌ទៅគង់នៅឯសៀម ? ព្រះអង្គតាំងព្រះរាជធានីនៅឯណា ? ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី ២ មានព្រឹត្តិការណ៍សំខាន់អ្វីខ្លះ ?

* * *

## ២៩ – ការប្រជែងរាជសម្បត្តិ

### « រវាងព្រះរាជបុត្រព្រះបាទជ័យជេដ្ឋាទី២ និងព្រះបាទឧទ័យ »

ព្រះបាទធម្មរាជារាជសំភារ (ព្រះពញាតូ) (១៦២៩-១៦៣៤)(១) និងព្រះឧទ័យ :– *កាលព្រះបាទជ័យជេដ្ឋាទី ២ សុគតទៅ ព្រះពញាតូដែលជាព្រះរាជបុត្រព្រះអង្គ ទ្រង់គង់ក្នុងផ្នួស ។ ព្រះឧទ័យដែលជាព្រះបិតុលា ព្រះអង្គទ្រង់កាន់កិច្ចការរជ្ជជំនួសព្រះអង្គ ។ លុះដល់ព្រះពញាតូឡើងគ្រងរាជ្យ ព្រះអង្គទុកព្រះឧទ័យជាព្រះឧបរាជ ។ កាលនោះព្រះរាជាគង់នៅឯកោះឃ្លោក(ខេត្តកណ្តាល)ហើយព្រះឧបរាជឯឧដុង្គ ។*

*ព្រះបាទធម្មរាជារាជសំភារ ព្រះអង្គសព្វព្រះទ័យនឹងអក្សរសាស្ត្រ*

(១) ឯកសារខ្មែរ ១៦២៩-១៦៣១ ។

ណាស់ ។

នៅឆ្នាំ ១៦២៩ ព្រះបាទធម្មរាជារាជសំការ ព្រះអង្គបានលើកទ័ពទៅវាយសៀមដើម្បីយកគូរ៉ាតមកវិញ តែពុំបានសម្រេចដូចព្រះរាជបំណង គ្រាន់តែបានកៀរអ្នកស្រុកប្រមាណ ១០០០០ នាក់ ។

នៅឆ្នាំ ១៦៣១ ព្រះអង្គត្រូវព្រះឧទ័យធ្វើគត ព្រោះព្រះអង្គបានលួចស្រឡាញ់ស្នំព្រះជាយាព្រះឧទ័យព្រះនាមបុប្ផាវតី ។

**ព្រះបាទអង្គនន្ទទី១ (១៦៤០-១៦៤២) និង ព្រះបាទរាមាធិបតីចន្ទ (ព្រះអង្គច័ន្ទ) (១៦៤២-១៦៥៨)** :— បន្ទាប់មក ព្រះឧទ័យដែលជាព្រះឧបរាជ បានលើកព្រះរាជបុត្រព្រះបាទជ័យជេដ្ឋាទី២ មួយអង្គទៀតឲ្យឡើងសោយរាជ្យ ។ គឺព្រះពញានូដែលទ្រង់ព្រះនាមថា ព្រះបាទអង្គទងទី១ (១៦៣៤-១៦៣០) ។ លុះសោយរាជ្យបាន ៦ ឆ្នាំ ព្រះអង្គសុគតទៅ ព្រះឧទ័យ ក៏ថ្វាយរាជបល្ល័ង្កមកឲ្យព្រះរាជបុត្រព្រះអង្គបង្កើតព្រះនាមព្រះបាទអង្គនន្ទទី ១ ។

ព្រះពញាចន្ទ ដែលត្រូវជាព្រះរាជបុត្រព្រះជ័យជេដ្ឋាទី ២ ទ្រង់អាក់អន់ព្រះទ័យក្នុងរឿងរាជសម្បត្តិនេះ ។ ដោយព្រះអង្គមានព្រះជាយាជាតិចាម ហើយដោយព្រះអង្គទ្រង់កាន់សាសនាឥស្លាមផង ព្រះអង្គក៏បំបះបំបោរពួកចាមឲ្យប្រឆាំងនឹងព្រះមហាក្សត្រ និងឲ្យធ្វើគតព្រះបាទអង្គនន្ទទី ១ និងព្រះឧទ័យ ។ នៅឆ្នាំ ១៦៤២ ព្រះអង្គឡើងគ្រងរាជ្យ

ហើយទ្រង់ព្រះនាមជាព្រះបាទរាមាធិបតីចន្ទ ដែលខ្លះហៅព្រះអង្គថាព្រះអង្គច័ន្ទមហាម៉ាត់អ៊ីប្រាហ៊ីម ។

**ព្រះបាទបទុមរាជា** ( ព្រះពញាសូ ) ( ១៦៥៨-១៦៧២ ):– កាលនោះព្រះពញាសូ និងព្រះពញាតន់ ដែលជាព្រះរាជបុត្រព្រះឧទ័យ ព្រះអង្គទ្រង់បានពឹងយួនឲ្យជួយ ។ នៅឆ្នាំ ១៦៥៨ ទ័ពយួនចូលមកចាប់ព្រះបាទរាមាធិបតីចន្ទបាន ដាក់ទ្រុងដែក ហើយបញ្ជូនទៅក្វាងទិញ(Quang Tinh) ជិតព្រំគុងកឹង ។ មួយឆ្នាំក្រោយមកព្រះអង្គក៏សុគតទៅ ។

នៅឆ្នាំ ១៦៥៨នោះ ព្រះពញាសូក៏ឡើងគ្រងរាជ្យ ហើយទ្រង់ព្រះនាមជាព្រះបាទបទុមរាជា ។

—oOo—

**សេចក្តីសង្ខេប**:—កាលព្រះបាទជ័យជេដ្ឋាសុគតទៅ ព្រះរាជបុត្រព្រះអង្គព្រះនាមពញាតូទ្រង់នៅក្មេងផ្នួស ។ ព្រះឧទ័យទ្រង់កាន់កិច្ចការរដ្ឋជំនួសព្រះអង្គ ។ មួយឆ្នាំក្រោយមក ទើបព្រះពញាតូទ្រង់គ្រងរាជ្យ ហើយទ្រង់ព្រះនាមថាព្រះបាទធម្មរាជារាជសំភារ ។ កាលនោះព្រះអង្គបានលើកទ័ពទៅវាយសៀម ដើម្បីយកក្រុំតមកវិញតែពុំបានសម្រេច។នៅឆ្នាំ១៦៣១ ព្រះអង្គត្រូវព្រះឧទ័យធ្វើគត ដោយព្រះអង្គទៅយកជាយាព្រះឧទ័យធ្វើជាព្រះមហេសី។ បន្ទាប់មក ព្រះអង្គទង ដែលត្រូវជាព្រះអនុជព្រះបាទធម្មរាជារាជសំភារ ឡើងសោយរាជ្យបាន៦ឆ្នាំ ហើយព្រះអង្គក៏សុគតទៅ ។ ពេលនោះ ព្រះឧទ័យថ្វាយរាជ្យមកព្រះអង្គនន្ទ ជាព្រះរាជបុត្រព្រះអង្គ ដែលជាហេតុនាំឲ្យព្រះអង្គច័ន្ទ ព្រះអនុជព្រះអង្គទងអាក់អន់ព្រះទ័យ។ព្រះអង្គច័ន្ទ ដោយព្រះអង្គកាន់សាសនាឥស្លាមផង ព្រះអង្គក៏បំបះពួកចាមឲ្យធ្វើគតព្រះបាទអង្គនន្ទនិងព្រះឧទ័យ ។ ព្រះអង្គច័ន្ទឡើងគ្រងរាជ្យទ្រង់ព្រះនាមថា ព្រះបាទរាមាធិបតីច័ន្ទ ។

សោយរាជ្យមិនបានប៉ុន្មាន ព្រះពញាសូនិងព្រះពញាតន់ ដែលជាព្រះរាជបុត្រព្រះឧទ័យបានទៅពឹងកំឡាំងយួន ហើយចាប់ព្រះបាទរាមាធិបតីច័ន្ទបាន ។ នៅឆ្នាំ១៦៥៨ ព្រះពញាសូឡើងគ្រងរាជ្យ ហើយទ្រង់ព្រះនាមព្រះបាទបទុមរាជា ។

**សំណួរៈ–** កាលដែលព្រះបាទជ័យជេដ្ឋាទី២ សុគតទៅ ហេតុអ្វីបានជាព្រះពញាតូមិនឡើងគ្រងរាជ្យភ្លាម? ក្នុងពេលនោះអ្នកណាកាន់ការរដ្ឋ? ហេតុអ្វីបានជាព្រះបាទធម្មរាជារាជសំភារចំប្បាំងនឹងសៀម? ហេតុម្ដេចបានជាព្រះឧទ័យធ្វើគតព្រះអង្គ? បន្ទាប់មកព្រះរាជាអង្គណាគ្រងរាជ្យ? ចុះបន្ទាប់មកទៀត? ហេតុអ្វីបានជាព្រះអង្គច័ន្ទអាក់អន់ព្រះទ័យក្នុងរឿងរាជសម្បត្តិ? ដើម្បីយករាជ្យ ព្រះអង្គធ្វើអ្វី?

*　*　*

## ៣០–ព្រះបាទជ័យជេដ្ឋាទី ៤

**ស្ថានភាពដ៏ធ្ងន់ធ្ងរក្នុងព្រះរាជវង្សមុនរជ្ជកាលព្រះបាទជ័យជេដ្ឋាទី៤:–** *នៅឆ្នាំ ១៦៧២ ព្រះរាជបុត្រព្រះបាទរាមាធិបតីច័ន្ទ បានធ្វើគតព្រះបាទបទុមរាជាហើយបានឡើងគ្រងរាជ្យ ហើយទ្រង់ព្រះនាមថា ព្រះបាទជ័យជេដ្ឋាទី៣ (១៦៧២-១៦៧៣) ។ សោយរាជ្យបានតែ៦ខែ ព្រះអង្គក៏ត្រូវព្រះមហេសី ព្រះបាទបទុមរាជាញុះញង់ចាមនិងជ្វាឲ្យធ្វើគតព្រះអង្គទៅទៀត ។ កាលនោះ ព្រះអង្គជ័យ ដែលត្រូវជាព្រះរាជបុត្រព្រះបទុមរាជា បានឡើងគ្រងរាជ្យ ។ តែមិនបានប៉ុន្មាន ព្រះអង្គក៏ត្រូវសុគតទៅនៅពេលដែលយួនលើកទ័ពមកធ្វើអន្តរាគមន៍ ដើម្បីព្រះអង្គនន្ទ (ព្រះ*

រាជនត្តាព្រះឧទ័យ) បន្ទាប់មកព្រះអង្គសូរ ដែលត្រូវជាព្រះអនុជព្រះបាទអង្គជ័យ ក៏បានវាយកំចាត់យួនទៅវិញ ហើយព្រះអង្គទ្រង់គ្រងរាជ្យ ដោយទ្រង់ព្រះនាមថា ព្រះបាទជ័យជេដ្ឋាទី ៤ ។

**រជ្ជកាលព្រះបាទជ័យជេដ្ឋាទី ៤ :–** ព្រះបាទជ័យជេដ្ឋាទី ៤ សោយរាជ្យ ៤ លើក ។

**រជ្ជកាលទី ១ (១៦៧៤-១៦៩៥) :–** ក្នុងរជ្ជកាលនេះ ព្រះអង្គត្រូវតយុទ្ធនឹងព្រះបាទអង្គនន្ទបីលើក ។ តែទាំងបីលើក ព្រះមហាក្សត្រព្រះអង្គមានជោគជ័យជាដរាប ហើយព្រះអង្គនន្ទសុគតនៅឆ្នាំ ១៦៩១។ ធៀតឱកាសដែលមានសន្តិភាព ព្រះអង្គទ្រង់សើរើរៀបចំច្បាប់ទំលាប់ឡើងវិញ។ នៅឆ្នាំ១៦៩៥ ព្រះអង្គបានដាក់រាជ្យដើម្បីព្រះភាគនេយ្យព្រះអង្គមួយអង្គព្រះនាម ព្រះបាទឧទ័យ ។

**រជ្ជកាលទី២ (១៦៩៦-១៧០០):–** ដោយព្រះបាទឧទ័យ សោយរាជ្យបានតែ១០ ខែទ្រង់សុគតទៅ ព្រះអង្គក៏ឡើងគ្រងរាជ្យជាលើកទី២ ។ នៅឆ្នាំ ១៦៩៧ ដើម្បីបង្រួបបង្រួមព្រះញាតិវង្ស ព្រះអង្គបានផ្សំផ្គុំព្រះអង្គអិមព្រះរាជបុត្រព្រះអង្គនន្ទ ជាព្រះសុណិសាព្រះអង្គ ។ ក្នុងរជ្ជកាលទី២នេះ មានមន្ត្រីម្នាក់ឈ្មោះនរិនអិមបង្កើតការបះបោរមួយប្រឆាំងនឹងព្រះអង្គ ដោយមានយួនជួយគាំទ្រ ។ តែការបះបោរនោះក៏បរាជ័យទៅវិញ នៅកំពង់ឆ្នាំងហើយនរិនអិមក៏ត្រូវស្លាប់ ។ នៅឆ្នាំ ១៧០០ ព្រះអង្គទ្រង់ដាក់

រាជ្យ ដើម្បីព្រះអង្គអិម ជាព្រះសុណិសា ។

**រជ្ជកាលទី ៣** (១៧០១-១៧០២):— ព្រះបាទអង្គអិមពុំមានសមត្ថភាព ព្រះបាទជ័យជេដ្ឋាទី ៤ ព្រះអង្គក៏ទ្រង់ឡើងគ្រងរាជ្យទៀត ។ បាន តែមួយឆ្នាំព្រះអង្គក៏ទ្រង់ដាក់រាជ្យទៅវិញ ដើម្បីព្រះរាជបុត្រព្រះអង្គព្រះ នាមព្រះបាទធម្មរាជាទី ២ ។

**រជ្ជកាលទី៤** (១៧០៤-១៧០៦):— ដោយព្រះបាទធម្មរាជាទី ២ នៅ កុមារពេកព្រះជន្មបានតែ ១២ ព្រះវស្សា ព្រះអង្គក៏ទ្រង់ឡើងគ្រងរាជ្យ ទៀត ។ នៅឆ្នាំ១៧០៤ មានព្រះរាជវង្សព្រះរាជាលាវ ដែលត្រូវពួកក្សត្រ លាវមួយអង្គទៀតបះប្រឆាំង បាន់រត់មកសុំជ្រកនៅកម្ពុជាយើង ។ នៅឆ្នាំ ១៧០៦ព្រះបាទជ័យជេដ្ឋាទី៤ ព្រះអង្គទ្រង់ដាក់រាជ្យជាស្ថាពរ ដើម្បីព្រះ រាជបុត្រព្រះអង្គព្រះបាទធម្មរាជាទី២ ដែលមានព្រះជន្មបាន១៦ព្រះវស្សា។

—oOo—

**សេចក្ដីសង្ខេប**:—មុនរជ្ជកាលព្រះបាទជ័យជេដ្ឋាទី ៤ ស្ថានភាពក្នុងព្រះរាជវង្សានុវង្ស ធ្ងន់ធ្ងរ ណាស់ ។ ក្នុងរយៈពេលតែ ៧ ឆ្នាំ មានព្រះរាជាបីអង្គសុគតដោយឃាតកម្ម ។

បន្ទាប់ពីបានកំចាត់យួនដែលចូលមកធ្វើអន្តរាគមន៍ មកព្រះអង្គសិបានឡើងគ្រង រាជ្យហើយទ្រង់ព្រះនាមថាព្រះជ័យជេដ្ឋាទី ៤ ។ ព្រះបាទជ័យជេដ្ឋាទី៤ ព្រះអង្គទ្រង់ ដាក់រាជ្យ៤លើក លើកទី១ ដើម្បីព្រះបាទឧទ័យ លើកទី២ដើម្បីព្រះបាទអង្គអិម លើក ទី ៣ និងទី៤ ដើម្បីព្រះរាជបុត្រព្រះអង្គព្រះនាម ព្រះបាទធម្មរាជាទី ២ ។

ក្នុងរជ្ជកាលព្រះអង្គ ព្រះអង្គបានតទល់នឹងព្រះអង្គនន្ទ និងឧកញ៉ានរិនអិម ។

នៅពេលមានសន្តិសុខ ព្រះអង្គបានរៀបចំប្បាប់ទំលាប់ ។

នៅចុងរជ្ជកាលព្រះអង្គ មានព្រះរាជវង្សានុវង្សលាវបានមកសុំជ្រកកោនដោយនៅវៀងច័ន្ទ មានការបះបោរ ។

**សំណួរ :** — មុនរជ្ជកាលព្រះបាទជ័យជេដ្ឋាទី៤ ព្រះរាជវង្សានុវង្សមានស្ថានភាពដូចម្ដេច ? ស្ថានភាពនោះបណ្ដាលមកពីអ្វី ? ព្រះបាទជ័យជេដ្ឋាទី៤ សោយរាជ្យប៉ុន្មានលើក ? ហេតុអ្វី ? ក្នុងរជ្ជកាលព្រះអង្គ មានអសន្តិសុខទេ ? ព្រះអង្គត្រូវតទល់នឹងអ្នកណា ? នៅពេលសានគ្រានព្រះអង្គទ្រង់ធ្វើអ្វី ? ហេតុអ្វីបានជាព្រះរាជវង្សានុវង្សលាវមកសុំជ្រកនៅស្រុកខ្មែរ ?

* * *

## ៣១ – ការច្របូកច្របល់ក្នុងរឿងរាជសម្បត្តិ « ព្រះបាទធម្មរាជាទី២ និង ព្រះបាទអង្គអិម ព្រះបាទសត្ថាទី២ និង ព្រះបាទធម្មរាជាទី២ »

### ព្រះបាទធម្មរាជាទី ២ (រជ្ជកាលទី២) *(១៧០៦-១៧១០)* និង ព្រះបាទអង្គអិម (រជ្ជកាលទី២) *(១៧១០-១៧២២)*.—

**ព្រះអង្គអិមទ្រង់យករាជ្យ :** — *ព្រះអង្គអិមដែលបានសោយរាជ្យម្ដង កាលព្រះបាទជ័យជេដ្ឋាទី ៤ ទ្រង់ដាក់រាជ្យលើកទី ២ ឥឡូវព្រះអង្គត្រូវជាគូប្រជែងក្នុងរឿងរាជសម្បត្តិជាមួយនឹងព្រះបាទធម្មរាជាទី ២ ដែលជាព្រះរាជបុត្រព្រះបាទជ័យជេដ្ឋាទី ៤ ។*

ឆ្លៀតឱកាស នៅពេលដែលមានលាវនៅភូមិបារាយណ៍ក្បត់ជុំនាំគ្នាបះបោរ ព្រះអង្គអិមបានតាំងព្រះអង្គជាមេនៃពួកលាវទាំងនោះហើយ ដោយមានជំនួយពីយួនថែមទៀតផង ព្រះអង្គអិមទ្រង់លើកទ័ពទៅវាយក្រុងឧដុង្គ ។ តែនៅពេលនោះ ព្រះបាទធម្មរាជាទី២ ព្រមទាំងព្រះអនុជព្រះនាមតន់ និងព្រះរាជបុត្រមួយអង្គទៀត បានភៀសព្រះអង្គទៅប្រទេសសៀមបាន ។ នៅពេលនោះ ព្រះអង្គអិមក៏ទ្រង់ឡើងគ្រងរាជ្យជាលើកទី ២ ។

**សៀមឆ្លួចរឿងរាជសម្បត្តិខ្មែរ :—** ដើម្បីគាំទ្រព្រះបាទធម្មរាជាទី ២ នៅឆ្នាំ ១៧២២ សៀមបានលើកទ័ពមកវាយខ្មែរ តាមជើងគោកផង ជើងទឹកផង ។ នៅខាងពាម (ហាទៀង) ខ្មែរបានពន្លិចសំពៅសៀមយ៉ាងច្រើន ។ តែខាងជើងគោក ទ័ពសៀមបានចូលដល់ក្រុងឧដុង្គ ។ ដើម្បីរក្សាព្រះរាជសម្បត្តិទៅទៀត ព្រះរាជាត្រូវសុខព្រះទ័យទទួលព្រះឋានៈព្រះអង្គជាព្រះសមន្តរាជនៃប្រទេសសៀម ។

នៅឆ្នាំដដែលនោះ ព្រះបាទអង្គអិមទ្រង់ដាក់រាជ្យ ដើម្បីព្រះរាជបុត្រព្រះអង្គព្រះនាមអង្គជ័យ (ព្រះបាទសត្ថាទី២) ។

## ព្រះបាទសត្ថាទី ២ (ព្រះអង្គជ័យ) ( ១៧២២-១៧២៩)(១៧៣០-១៧៣៦)
## និង ព្រះបាទធម្មរាជាទី ២ (រជ្ជកាលទី៣) ( ១៧៣៦-១៧៤៧)

**រជ្ជកាលព្រះសត្ថាទី២ :—** នៅឆ្នាំ ១៧២២ ព្រះអង្គជ័យឡើងគ្រងរាជ្យ ហើយទ្រង់ព្រះនាមថា ព្រះបាទសត្ថាទី២ ។ នៅឆ្នាំ១៧២៩ ព្រះព្រះអង្គអិមទ្រង់យករាជសម្បត្តិទៅវិញ ។ បានតែ ៧ ខែ ព្រះបាទអង្គអិម ព្រះអង្គត្រូវដាក់រាជ្យទៅវិញ ដើម្បីព្រះអង្គជ័យ (ព្រះសត្ថាទី២) ព្រោះមានរាស្ត្រប្រជាពុំសូវពេញចិត្ត ។

**ខេត្តលង់ហោ (ទិញឡុខ) និង មេសរ (មីថរ) បានទៅយួន :—** នៅឆ្នាំ ១៧៣១ មានលាវម្នាក់នៅប្រសូត (ស្វាយរៀង) បះបោរដើម្បីកាប់សម្លាប់យួន ។ យួនយករឿងនោះធ្វើជាលេស ក៏លើកទ័ពមកវាយខ្មែរ នៅឆ្នាំ ១៧៣២ ។ ព្រះបាទសត្ថាទី ២ ព្រះអង្គបានតយុទ្ធយ៉ាងអង់អាច ។ ទ័ពយួនបរាជ័យថយទៅវិញ ទៅជាប់នៅលង់ហោ និងមេសរ ដែលយួនយករហូតមក ។

**ព្រះបាទធម្មរាជាទី២ ឡើងគ្រងរាជ្យ :—** នៅឆ្នាំ ១៧៣៦( ) ដោយព្រះអង្គមានសេចក្តីសង្ស័យចំពោះព្រះមហេសី និងព្រះញាតិវង្សខ្លះ ព្រះបាទសត្ថាទី ២ ព្រះអង្គក៏បានប្រុងនឹងចាប់ក្សត្រទាំងនោះធ្វើគត ។ លុះបានជ្រាបដំណាំងនេះ ព្រះមហេសី និងក្សត្រទាំងឡាយនោះ ក៏រត់ទៅរកព្រះបាទធម្មរាជាទី២ នៅស្រុកសៀម ។ លុះព្រះបាទធម្មរាជាទី ២ និងសៀមលើកទ័ពមក ព្រះបាទសត្ថាទី ២ ព្រះអង្គក៏ភៀសព្រះអង្គទៅ

---

(១) ឯកសារខ្លះថា១៧៣៨ ។

ប្រទេសយួន ។ នៅពេលនោះ ព្រះបាទធម្មរាជាទី ២ ក៏ឡើងគ្រងរាជ្យជាលើកទី ៣ ។

**យួនយកខេត្តស្រុកត្រាំង :**— ក្នុងរជ្ជកាលទី៣ នេះ ព្រះបាទធម្មរាជាទី២ ព្រះអង្គបានទំទប់ទល់នឹងយួន ការពារបូរណភាពដែនដីណាស់ ។ នៅឆ្នាំ ១៧៤៣ យួនបានចូលមកយាយីដល់ខេត្តស្រុកត្រាំង (សុខត្រាំង) តែខ្មែរបានវាយឲ្យថយទៅវិញ ។ តែ ៤ ឆ្នាំក្រោយមក យួនក៏យកខេត្តនោះបាន ហើយចូលដល់ក្រុងឧដុង្គ ។ ព្រះរាជាទ្រង់ថយទៅពោធិ៍សាត់ ។ ព្រះអង្គសុគតនៅឆ្នាំ ១៧៤៧ ។

—oOo—

**សេចក្ដីសង្ខេប :**— ព្រះអង្គអិមឆ្ងៀតឱកាសដែលមានពួកលាវបះ ព្រះអង្គក៏តាំងព្រះអង្គជាមេហើយមកឡោមព័ទ្ធវាយក្រុងឧដុង្គ ។ កាលនោះព្រះបាទធម្មរាជាទី២ ព្រះអង្គភៀសព្រះអង្គរួចទៅខាងសៀម ។ នៅឆ្នាំ ១៧២២ ដើម្បីគាំទ្រព្រះបាទធម្មរាជាទី ២ សៀមបានលើកទ័ពចូលមកដល់ឧដុង្គ ។ ដើម្បីរក្សារាជសម្បត្តិតមកទៀត ព្រះបាទអង្គអិមព្រះអង្គត្រូវទទួលជាសមន្តរាជនៃប្រទេសសៀម ។ នៅឆ្នាំនោះដែរ ព្រះអង្គទ្រង់ដាក់រាជ្យដើម្បីព្រះរាជបុត្រព្រះអង្គព្រះនាមព្រះបាទសត្ថាទី ២ ។

នៅឆ្នាំ ១៧៣១ ដោយមានលាវម្នាក់បំបះនាំអ្នកស្រុកឲ្យកាប់សម្លាប់យួន យួនយករឿងនោះជាលេសក៏បានលើកទ័ពមកវាយខ្មែរ ហើយយកបានលង់ហោនិងមេសរ។

នៅឆ្នាំ ១៧៣៨ ដោយមានការ „បដិវត្តិ” មួយនៅព្រះរាជវាំង ព្រះសត្ថាទី ២ ក៏ភៀសព្រះអង្គនៅប្រទេសយួន ។ ក្នុងពេលនោះ ព្រះបាទធម្មរាជាទី ២ ទ្រង់ត្រឡប់ពីសៀមក៏ឡើងគ្រងរាជ្យ ។ ក្នុងរជ្ជកាលនេះ មានការវាយពីខាងយួន ហើយយួនយកបានខេត្តស្រុកត្រាំង ។

**សំណួរៈ—** ព្រះអង្គអិមដណ្ដើមរាជ្យពីព្រះអង្គធម្មរាជាទី ២ យ៉ាងម្ដេចបាន ? ដើម្បីតាំងព្រះបាទធម្មរាជាទី២ សៀមធ្វើអ្វី? ហេតុអ្វី សៀមមិនយករាជ្យថ្វាយព្រះបាទធម្មរាជាទី ២ ទៅ នៅពេលនោះ? ក្សត្រណាសោយរាជ្យបន្ទាប់ពីព្រះបាទអង្គអិម? នៅឆ្នាំ ១៧៣១ ហេតុអ្វីបានជាយួនចូលមកវាយខ្មែរ? ពេលនោះខ្មែរខាតបង់អ្វី? ហេតុម្ដេច បានជារាជ្យបានមកព្រះបាទធម្មរាជាទី ២ វិញ? ក្នុងរជ្ជកាលព្រះអង្គនេះមានព្រឹត្តិការណ៍អ្វីសំខាន់ ?

* * *

## ៣២–ការច្របូកច្របល់ក្នុងរឿងរាជសម្បត្តិ (ក)

### «ក្នុងរជ្ជកាលព្រះបាទអង្គទងទី ២ »

### រជ្ជកាលទី ១ នៃព្រះបាទអង្គទងទី ២ ( *១៧៤៧-១៧៤៩* ).—

**រាជសម្បត្តិបានមកព្រះបាទអង្គទងទី ២ :—** *កាលព្រះបាទធម្មរាជាទី ២ សុគតទៅ រាជសម្បត្តិបានមកព្រះបាទធម្មរាជាអង្គអិម ឬ ព្រះបាទធម្មរាជាទី ៣ ដែលត្រូវជាព្រះរាជបុត្រព្រះអង្គ ។ សោយរាជ្យបានតែមួយឆ្នាំ ព្រះបាទធម្មរាជាអង្គអិម ត្រូវព្រះអង្គអ៊ីងស្រ៊ីសុរិយោ ហៅអង្គអ៊ីង ធ្វើគត ។ ព្រះអង្គអ៊ីងនេះត្រូវជាព្រះអនុជព្រះបាទធម្មរាជាអង្គអិម មានព្រះមាតាជាសៀម ។ តែដោយព្រះរាជវង្សានុវង្សមិនសព្វព្រះទ័យនឹងព្រះអង្គអិម រាជសម្បត្តិក៏ត្រូវថ្វាយទៅព្រះអង្គទងវិញដែលត្រូវជាព្រះ*

អនុជព្រះបាទធម្មរាជាទី ២ ។

**ចម្បាំងនឹងព្រះសត្ថាទី ២:** –សោយរាជ្យបាន២ ឆ្នាំ ព្រះបាទអង្គទងទី ២ ព្រះអង្គក៏ទ្រង់ភៀសព្រះអង្គទៅខាងសៀម ព្រោះព្រះបាទសត្ថាទី២ ដែលបានភៀសព្រះអង្គទៅស្រុកយួន បានលើកទ័ពមកច្បាំងនឹងព្រះអង្គ ។ នៅពេលនោះ មានមន្ត្រីម្នាក់ឈ្មោះឧកបានធ្វើចម្បាំងតទល់នឹងព្រះបាទសត្ថាទី ២ រហូតបានជោគជ័យ, ដោយបានធ្វើគតព្រះបាទសត្ថាទី ២ នៅក្នុងចម្បាំងនោះ ។

**ព្រះបាទជ័យជេដ្ឋាទី ៥ (ព្រះអង្គស្ងួន)** (១៧៤៩-១៧៥៥):– នៅឱកាសដែលព្រះបាទអង្គទងគង់នៅសៀម រាជបល្ល័ង្ក ក៏ត្រូវថ្វាយទៅព្រះបាទជ័យជេដ្ឋាទី៥ ដែលត្រូវជាព្រះរាជបុត្រព្រះបាទធម្មរាជាអង្គអិម ។ សោយរាជ្យបាន ៧ ឆ្នាំ ព្រះអង្គក៏សុគតទៅ ។

**រជ្ជកាលទី ២ នៃព្រះបាទអង្គទង** (១៧៥៦-១៧៥៧):– ព្រះបាទជ័យជេដ្ឋាទី ៥·សុគតទៅព្រះបាទអង្គទង ទី ២ ក៏យាងមកពីសៀមវិញគ្រងរាជ្យជាលើកទី ២ ។ ព្រះអង្គទ្រង់លើកព្រះឧទ័យអង្គតន់ (ព្រះឧទ័យទី ២) ជាព្រះមហាឧបរាជ ។

**ចម្បាំងនឹងព្រះអង្គអ៊ីង:** – ព្រះអង្គអ៊ីងដែលបានធ្វើគតព្រះធម្មរាជាអង្គអិមបានបង្ករលើកទ័ពវាយឧដុង្គ ។ កាលនោះព្រះបាទអង្គទងទី ២ ទ្រង់ភៀសព្រះអង្គទៅឯពោធិសាត់ ហើយក្រោយមក ព្រះអង្គក៏ទ្រង់សុគត

នៅទីនោះទៅ ។ រីឯព្រះមហាឧបរាជបានកៀសព្រះអង្គ ទៅឯពាម (ហាទៀន) ទៅគង់នៅជាមួយព្រះសុទ័ត ។

**ជំនួយពីព្រះសុទ័ត**:— ព្រះសុទ័តជាជនជាតិចិន នាមដើមម៉ក់គុង ជាបុត្រ របស់ ម៉ក់ គីវ ដែលបានតាំងជាសម្តេចនៅពាម ។ ដោយបានកំលាំង ពីព្រះសុទ័តនេះ ព្រះឧទ័យអង្គតន់ ក៏បានសម្រេចជោគជ័យ រហូត បានធ្វើគតព្រះអង្គអិម ព្រមទាំងព្រះញាតិវង្សឯទៀតផង នៅសល់តែ ព្រះអង្គនន្ទ (ព្រះរាជបុត្រព្រះបាទជ័យជេដ្ឋាទី៤ ) ដែលបានកៀសព្រះ អង្គទៅសៀមរួច ។ តមកព្រះឧទ័យអង្គតន់ឡើងសោយរាជ្យ ហើយ ទ្រង់ព្រះនាមថាព្រះបាទឧទ័យទី២ ។

— oOo —

**សេចក្តីសង្ខេប**:— ព្រះអង្គអិមស្រីសុរិយោ ទ្រង់ធ្វើគតព្រះបាទធម្មរាជាអង្គអិម ដែលសោយ រាជ្យបន្តពីព្រះបាទធម្មរាជាទី ២ ។ តែដោយព្រះរាជវង្សានុវង្សមិនសព្វព្រះទ័យនឹងព្រះអង្គ អ៊ឹងស្រីសុរិយោ រាជសម្បត្តិក៏បានមកព្រះបាទអង្គទងទី ២ ដែលត្រូវជាព្រះអនុជព្រះបាទ ធម្មរាជាទី ២ ។ ក្នុងរជ្ជកាលនេះ ព្រះសត្ថាទី ៣ បានលើកទ័ពមកច្បាំង ។ ព្រះបាទ អង្គទងបណ្តោះព្រះអង្គទៅសៀម ។ តែព្រះសត្ថា ទី ៣ ត្រូវមន្ត្រីម្នាក់ឈ្មោះឧកធ្វើគត បាន ។ ពេលនោះដោយព្រះបាទអង្គទងគង់នៅឯសៀម រាជសម្បត្តិក៏ត្រូវថ្វាយមកព្រះបាទ ជ័យជេដ្ឋាទី ៤ ។

លុះព្រះបាទជ័យជេដ្ឋាទី ៤ សុគតទៅ ព្រះបាទអង្គទង ទី ២ ក៏យាងមកគ្រងរាជ្យ ទៀត ។ លុះព្រះអង្គអ៊ឹងលើកទ័ពមកវាយឧដុង្គ ព្រះបាទអង្គទងក៏កៀសព្រះអង្គទៅពោធិសាត់ ហើយសុគតទៅ ។ ចំណែកឯព្រះឧបរាជព្រះនាម ឧទ័យអង្គតន់ ព្រះអង្គបានពឹងឲ្យព្រះ

សុទ័តជួយ ។ បានជោគជ័យហើយ ព្រះឧទ័យឡើងគ្រងរាជ្យ ហើយទ្រង់ព្រះនាមថាព្រះបាទឧទ័យទី ២ ។

**សំណួរ:—** ព្រះមហាក្សត្រអង្គណាដែលសោយរាជ្យបន្ទាប់ពីព្រះបាទធម្មរាជា ទី ២ ? ក្សត្រអង្គណាដែលបានធ្វើគតព្រះបាទធម្មរាជាអង្គអិម ? ហេតុអ្វីបានជាព្រះអង្គអ៊ុងសុរិយោប៉ិនបានសោយរាជ្យ ? រាជ្យបានមកព្រះរាជាអង្គណា ? កាលព្រះសត្វាទី ២ លើកទ័ពមកវាយ ព្រះបាទអង្គទងទី ២ ហេងទៅឯណា ? ព្រះសត្វាទី ២ ព្រះអង្គមានជោគជ័យទេ ? ហេតុអ្វីបានជារាជសម្បត្តិ ត្រូវថ្វាយមកព្រះបាទជ័យជេដ្ឋា ទី ៥ វិញ? ក្នុងពេលណាដែលព្រះអង្គទងឡើងគ្រងរាជ្យជាលើកទី ២? ក្នុងរជ្ជកាលនោះមានព្រឹត្តិការណ៍យ៉ាងម្ដេច? ពេលនោះព្រះបាទអង្គទង ទ្រង់យាងទៅឯណា ? ព្រះអង្គអ៊ុងធ្វើចម្បាំងនឹងព្រះឧទ័យអង្គតន់បានលទ្ធផលយ៉ាងម្ដេច ? ព្រះឧទ័យអង្គតន់បានគ្រងរាជ្យទ្រង់ព្រះនាមយ៉ាងម្ដេច ?

* * *

## ៣៣– ព្រះបាទឧទ័យទី ២ - ព្រះបាទអង្គនន្ទ

## «ព្រះបាទអង្គអេង»

**ព្រះបាទឧទ័យទី ២** *(១៧៥៨-១៧៧៥) :— ព្រះឧទ័យអង្គតន់ បន្ទាប់ពីបានធ្វើឃាតព្រះអង្គអ៊ឹង ឡើងគ្រងរាជ្យហើយ ទ្រង់ព្រះនាមថាព្រះបាទឧទ័យទី ២ ឬ ព្រះនារាយណ៍រាជាធិរាជរាមាធិបតី ។*

**ស្រុកឃ្លាំងនិងព្រះត្រពាំងបាននៅយួន:—** *ដើម្បីរកសេចក្ដីសុខជាមួយយួន ព្រះបាទឧទ័យទី ២ ព្រះអង្គបានយល់ព្រមឲ្យយួនតាំងនៅស្រុក*

នៅស្រុកឃ្លាំង និងព្រះត្រពាំង (ត្រាវិញ) ។ តែយួនរំលោភលើថែម ទៀត នៅខេត្តផ្សារដែក (សាដិច) កោះតែង (គូឡៅយ៉ាង) និងមាត់ជ្រូក (ចូដុក) ។

**ចម្បាំងនឹងព្រះអង្គនន្ទ** :— នៅឆ្នាំ ១៧៦៩ ដោយព្រះបាទឧទ័យ ព្រះអង្គមិនព្រមនាំសួយទៅថ្វាយស្តេចស្រុកសៀម ស្តេចសៀមបានបញ្ជូនព្រះអង្គនន្ទ ដែលជាព្រះរាជបុត្រព្រះបាទជ័យជេដ្ឋាទី ៤ ហើយដែលបានភៀសព្រះអង្គ ទៅគង់ឯសៀម ឲ្យមកចំបាំងដណ្តើមរាជ្យពីព្រះបាទឧទ័យទី ២ ។ ចម្បាំងបានកើតឡើងជាច្រើនលើកច្រើនគ្រា ។ ខាងព្រះបាទឧទ័យ មានជំនួយពីយួនជាកំលាំង ។ តែនៅទីបំផុត នៅឆ្នាំ ១៧៧៧ ព្រះបាទឧទ័យទី២ ព្រះអង្គទ្រង់យល់ព្រមថ្វាយរាជ្យទៅព្រះអង្គនន្ទ ដើម្បីបៀសវាងចម្បាំង ដែលនាំឲ្យរាស្ត្រវេទនាកាន់តែខ្លាំង ។

**ព្រះបាទអង្គនន្ទទី ២ ( ១៧៧៥-១៧៧៩ )** :— ព្រះអង្គនន្ទឡើងគ្រងរាជ្យ ហើយទ្រង់ព្រះនាមថាព្រះអង្គនន្ទទី២ ឬ ព្រះអង្គនន្ទរាមា ។

**ចម្បាំងនឹងយួន** :— កាលនោះ ប្រទេសយួនត្រូវពួកតាយសឺងបះបោរ ។ យួនសុំឲ្យខ្មែរជួយ ។ ព្រះអង្គនន្ទទី ២ ព្រះអង្គប្រកែកមិនយល់ព្រម ។ បន្ទាប់មកយួនលើកទ័ពមកវាយខ្មែរដល់ភ្នំពេញ ។ តែយួនត្រូវបរាជ័យថយទៅវិញ ។

**មន្ត្រីក្បត់**:— នៅឆ្នាំ ១៧៧៩ មាននាម៉ឺន ៣ នាក់ ឈ្មោះវិបុល សួ

មូ និង បែន ចូលដៃនឹងយួន ហើយបានធ្វើឃាតព្រះមហាក្សត្រ និងព្រះរាជបុត្រព្រះអង្គ ៤ អង្គទៀត ។ បន្ទាប់មក មូ ប្រកាសខ្លួនជាសម្តេចចៅហ្វា ហើយលើករាជ្យថ្វាយទៅព្រះរាជបុត្រព្រះឧទ័យ ទី ២ ព្រះនាម អង្គអេង ។

**ព្រះបាទអង្គអេង** (១៧៧៩-១៧៩៦) :– កាលនោះ ព្រះបាទអង្គអេងទើបនឹងមានព្រះជន្ម ៦ ព្រះវស្សា ។ សម្តេចព្រះចៅហ្វាមូ បានឡើងជារាជានុសិទ្ធ វិបូលសួជាក្រឡាហោម និងបែនជាយោមរាជ ។

**យោមរាជបែន** :– ទាស់នឹងសម្តេច មូ យោមរាជ បែន រត់ទៅសៀម ។ ក្រោយមកនៅឆ្នាំ ១៧៨២ យោមរាជ បែន និងក្រឡាហោម សួ បានផ្សំគំនិតគ្នាសំលាប់មូ ។ លុះសម្លាប់មូបានហើយ បែនសម្លាប់ សួ ទៅទៀត ។ កាលនោះឧកញ៉ា អរជួន ស្តេចត្រាញ់នៅត្បូងឃ្មុំ លើកទ័ពមកចាប់បែន ។ តទល់មិនឈ្នះ យោមរាជបែនរត់ទៅសៀមទៀត នាំទាំងព្រះរាជកុមារព្រះអង្គអេងទៅផង ។

**សៀមយកដីបាត់ដំបង និងសៀមរាប** :– សៀមឃាំងព្រះអង្គអេងរហូតដល់ឆ្នាំ ១៧៩៤ ទើបបើកឲ្យព្រះអង្គយាងមកកាន់កម្ពុជាវិញ ។ ឯយោមរាជបែន សៀមតាំងជាចៅហ្វាយខេត្តនៃខេត្តបាត់ដំបង និងសៀមរាប ដែលសៀមយកធ្វើជារបស់វា ។

ព្រះបាទអង្គអេងសុគតក្នុងព្រះជន្មបាន ២៥ ព្រះវស្សា ។ ព្រះ

*រាជបុត្រព្រះអង្គព្រះនាមព្រះអង្គច័ន្ទសោយរាជ្យតពីព្រះអង្គមក ។*

—oOo—

**សេចក្ដីសង្ខេប**:— ដើម្បីរកសេចក្ដីសុខជាមួយយួន ព្រះបាទឧទ័យទី ២ ព្រះអង្គបានយល់ព្រមឲ្យយួនតាំងនៅស្រុកឃ្លាំង និងព្រះត្រពាំង ។ តែយួនរំលោភយកថែមទៀតនូវផ្សារដែក កោះតែង និងមាត់ជ្រូក ។ ព្រះបាទឧទ័យដោយព្រះអង្គពុំព្រមចុះញ៉មសៀម សៀមបានលើកទ័ពមកឈ្លានពានច្រើនលើក ដោយបញ្ចេះឲ្យព្រះអង្គនន្ទមកដណ្ដើមរាជ្យ ។ នៅទីបំផុតព្រះអង្គបានព្រមថ្វាយរាជ្យទៅព្រះអង្គនន្ទ ។

ក្នុងរាជ្យនៃព្រះបាទអង្គនន្ទ យួនបានលើកទ័ពមកវាយខ្មែរ ព្រោះព្រះអង្គពុំព្រមទៅជួយយួនក្នុងចម្បាំងនឹងពួក តាយសឺង ។ ព្រះអង្គសុគត ដោយមានមន្ត្រី ៣ នាក់ សួ មូ និង បែន, ក្បត់ចូលយួន ហើយធ្វើគតព្រះអង្គ ។ បន្ទាប់ពីបានលើករាជ្យថ្វាយទៅព្រះអង្គអេង ពួកក្បត់ទាំងបីនាក់ឈ្លោះគ្នា ។ បែនសម្លាប់មូ និងសួបានហើយមិនហ៊ាននៅស្រុក ក៏នាំព្រះអង្គអេងរត់ទៅស្រុកសៀម ។ សៀមឃាំងព្រះអង្គអេងនៅឯសៀម ១២ ឆ្នាំ ។ សៀមយកបាត់ដំបង សៀមរាប ហើយដាក់បែនឲ្យត្រួតត្រាជាស្ដេចត្រាញ់ ។

**សំណួរ**:— ហេតុអ្វីបានជាព្រះបាទឧទ័យទី ២ ព្រះអង្គព្រមឲ្យស្រុកឃ្លាំង និងព្រះត្រពាំងទៅយួន? ចុះផ្សារដែក កោះតែង និងមាត់ជ្រូក ហេតុម្ដេចក៏បានទៅយួនដែរ? ក្នុងរជ្ជកាលព្រះបាទឧទ័យ ហេតុម្ដេចបានជាសៀមមកឈ្លានពានលើទឹកដីខ្មែរ? ហេតុបានជាយួនមកវាយខ្មែរ? ព្រះអង្គសុគតដោយហេតុអ្វី? ក្រោយមក ហេតុអ្វីបានជាព្រះអង្គអេងយាងទៅឯសៀម? សៀមឃាំងព្រះអង្គឯស្រុកសៀមប៉ុន្មានឆ្នាំ? ចូរនិយាយអំពីអាកប្បកិរិយាថោកទាបរបស់បែនចំពោះជាតិ?

*  *  *

# ៣៤- សៀមនិងយួនរំលោភលើខ្មែរ

## « ក្នុងរជ្ជកាលព្រះបាទអង្គច័ន្ទទី ២ »

**មុនរជ្ជកាលព្រះបាទអង្គច័ន្ទទី ២ សម្ដេចចៅហ្វាប៉ុក** :— ព្រះបាទអង្គអេងព្រះអង្គមានព្រះរាជបុត្រ ប្រាំ ព្រះអង្គ ៗ គឺព្រះអង្គចន្ទ ព្រះអង្គភិម ព្រះអង្គស្ងួន ព្រះអង្គអិម និងព្រះអង្គឌួង ៗ កាលព្រះអង្គអេងសុគតទៅ ព្រះរាជបុត្រច្បងព្រះអង្គ ព្រះនាមអង្គចន្ទទី ២ ព្រះជន្មបានតែ ៦ ព្រះវស្សា ៗ តាមប្រពៃណីខ្មែរព្រះអង្គអាចគ្រងរាជ្យបាន ៗ តែដោយមានបង្គាប់មកពីសៀម ព្រះរាជបល្ល័ង្កក៏ត្រូវទំនេរអស់កាល ១០ ឆ្នាំ (១៧៩៦-១៨០៦)ៗ ក្នុងខណៈនោះសម្ដេចចៅហ្វាប៉ុក ដែលជាអ្នកកាន់កាប់ព្រះរាជរដ្ឋាភិបាល បានទៅជាឧបករណ៍មួយរបស់សៀម ៗ នៅឆ្នាំ ១៧៩៨ គឺកាលដែលសៀមកំពុងច្បាំងនឹងភូមា សម្ដេចចៅហ្វាប៉ុកបានចាត់កងទ័ពខ្មែរឲ្យទៅជួយវាយសៀមៗ នៅឆ្នាំ ១៨០០ គឺកាលដែលពួកតាយសឺងវាយព្រះបាទយ៉ាឡុង ព្រះបាទ យ៉ាឡុង បានទៅពឹងសៀម ៗ សៀមមានបង្គាប់មកសម្ដេចចៅហ្វាប៉ុក ៗ សម្ដេចចៅហ្វាប៉ុកបានចាត់កងទ័ពខ្មែរឲ្យទៅជួយព្រះបាទយ៉ាឡុង ៗ

**រជ្ជកាលព្រះបាទអង្គច័ន្ទទី ២ (១៨០៦-១៨៣៤)**

**ក្រោមអំណាចសៀមនិងយួន** :— លុះព្រះជន្មបាន ១៦ ព្រះវស្សា ព្រះអង្គចន្ទ ទី ២ យាងទៅបាងកក ដើម្បីទទួលព្រះរាជាភិសេកពីព្រះចៅសៀម

ទើបយាងមកឧដុង្គវិញ ។ ព្រះបាទយ៉ាឡុងព្រះរាជាយួនមានសេចក្ដីប្រណែន ក៏ចាត់កងទ័ពឲ្យមកបន្ទំព្រះបាទអង្គចន្ទទី ២ ឲ្យបំណុះយួនផង ។ កាលនោះ កម្ពុជានៅក្រោមអំណាចសៀមផងយួនផង ។

**សៀមធ្វើអ្វីៗ តាមធំនើងចិត្ត:—** នៅឆ្នាំ ១៨១០ ព្រះចៅសៀមសុគតៗ ព្រះអង្គចន្ទ ទ្រង់បានចាត់ ព្រះអនុជពីរអង្គ គឺព្រះអង្គស្ងួន និងព្រះអង្គអិម ឲ្យទៅថ្វាយបង្គំព្រះសព និងព្រះចៅដែលសោយរាជ្យថ្មី ។ កាលនោះ ព្រះចៅសៀមបានតាំងព្រះអង្គស្ងួនជាព្រះជ័យជេដ្ឋាមហាឧបយោរាជ និងព្រះអង្គអិម ជាព្រះស្រីជ័យជេដ្ឋាមហាឧបយោរាជ ដោយឥតមានប្រឹក្សា នឹងព្រះរាជាខ្មែរឡើយ ហើយព្រះចៅសៀមបញ្ជាឲ្យកេណ្ឌរាស្ត្រខ្មែរយកទៅរក្សាក្រុងបាងកក ។

**ព្រះរាជប្រតិកម្មនៃព្រះបាទអង្គចន្ទទី ២ :—** ដោយព្រះបាទអង្គចន្ទទី ២ ព្រះអង្គមិនសព្វព្រះទ័យនឹងរឿងកេណ្ឌនោះ ព្រះអង្គបានឲ្យចាប់ឧកញ៉ាក្រឡាហោមមឿង និងឧកញ៉ាចក្រីបែន ដែលបានធ្វើកំណេណ្ឌឲ្យសៀមមកសម្លាប់ ។ ឃើញដូច្នោះ ព្រះអង្គស្ងួន ក៏គៀសព្រះអង្គចេញពីឧដុង្គ ។

**សៀមវាយខ្មែរ :—** នៅឆ្នាំ ១៨១១ សៀមលើកទ័ពមកវាយឧដុង្គជាមួយនឹងព្រះអង្គស្ងួន ។ តយុទ្ធមិនបាន ព្រះរាជាក៏ទ្រង់ថយទៅ

ព្រៃនគរ ។ នៅឆ្នាំ ១៨១៣ ព្រះអធិរាជ យ៉ាឡុង បានឲ្យទ័ពហែព្រះអង្គចន្ទ មកគ្រងរាជ្យវិញ ។ ឯចំណែកព្រះអង្គស្ងួន យាងត្រឡប់ទៅស្រុកសៀមវិញ ហើយសុគតទៅ ។

**សៀមនិងយួនយកដីខ្មែរ :–** នៅឆ្នាំ ១៨១៣ ចៅហ្វាយខេត្តកំពង់ស្វាយឈ្មោះម៉េនចូលដៃនឹងសៀម ។ សៀមចូលមកយកម្លូព្រៃ ទន្លេរពៅ និងស្ទឹងត្រែងដោយសំអាងថា ខ្មែរនៅតំបន់នោះចង់រស់នៅជាមួយសៀម ។ នៅពេលនោះយួនក៏ផ្ដើមដៃដែរ ។ ព្រះអធិរាជយួនបានបើកឲ្យរាជការកូសាំងស៊ីន ប្រើអំណាចមកលើខ្មែរទាំងមូល ឲ្យកេណ្ឌរាស្ត្រខ្មែរ ជីកព្រែកពីមាត់ជ្រូក (ចូដុក) ទៅពាម( ហាទៀង ) ហើយយកដីខ្មែរទាំងប៉ុន្មាន ដែលនៅខាងត្បូងព្រែកនោះ ។

**សៀមវាយខ្មែរម្ដងទៀត :–** នៅឆ្នាំ ១៨២៩ (១) ចៅហ្វាយខេត្តពោធិ-សាត់ឈ្មោះ កា បានកេណ្ឌរាស្ត្រខ្មែរឲ្យសៀម ហើយទៅហៅសៀមឲ្យមកវាយខ្មែរ ។ ទ័ពសៀមមកលុកលុយខេត្តពោធិសាត់ និងកំពង់ឆ្នាំង ។ ព្រះបាទអង្គចន្ទទ្រង់ថយទៅគង់នៅកូសាំងស៊ីនទៀត ។ តែទ័ពសៀម ត្រូវទ័ពបក្រីឡុងនិងទ័ពយួនវាយឲ្យថយទៅវិញ ។ នៅឆ្នាំ ១៨៣៤ យួនហែព្រះអង្គចន្ទមកកាន់ឧដុង្គវិញ ។ ព្រះអង្គសុគត

(១) Monarchie Cambodgienne គឺឆ្នាំ ១៨៣២ ។

នៅឆ្នាំនោះដែរ ។

—oOo—

**សេចក្ដីសង្ខេប :—** មុនព្រះបាទអង្គចន្ទឡើងគ្រងរាជ្យ កិច្ចការរដ្ឋនៅលើបន្ទុកសម្ដេចចៅហ្វាប៉ុក ។ តែក្នុងដំណែងនេះ សម្ដេចចៅហ្វាប៉ុកគ្រាន់តែជាឧបករណ៍មួយរបស់សៀម ។ ក្នុងរជ្ជកាលព្រះអង្គ សៀមនិងយួនបានរំលោភយ៉ាងខ្លាំងមកលើខ្មែរ ។ សៀមឲ្យព្រះអង្គចន្ទយាងទៅទទួលរាជាភិសេកឯបាងកក ។ ស្ដេចយួនបង្ខំព្រះអង្គឲ្យចំណុះយួន ។

នៅឆ្នាំ ១៨១១ លុះព្រះរាជាមិនបណ្ដោយឲ្យក្រឡាហោមមឿងនិងចក្រីបែនកេណ្ឌរាស្ត្រខ្មែរឲ្យសៀម សៀមលើកទ័ពមកវាយខ្មែរ ។

នៅឆ្នាំ ១៨១៣ ដោយមានចៅហ្វាយខេត្តកំពង់ស្វាយឈ្មោះម៉ែងក្បត់ព្រះរាជាខ្មែរ សៀមបានយកម្លូព្រៃ ទន្លេរពៅ និងស្ទឹងត្រែង ដោយគ្រាន់តែសំអាងថា ខ្មែរស្រុកនោះចង់រស់នៅជាមួយសៀម ។ ក្នុងពេលនោះដែរ យួនយកដីភាគខាងត្បូង ព្រែកជីក ពីចូដុកទៅហាទៀង ។

នៅឆ្នាំ ១៨៣២ សៀមលើកទ័ពមកវាយខ្មែរទៀត ហើយមានចៅហ្វាយខេត្តពោធិ-សាត់ឈ្មោះ កា ក្បត់ចូលដៃ ។ នៅពេលនោះព្រះបាទអង្គចន្ទយាងទៅឯស្រុកកូសាំងស៊ីន តែទ័ពសៀមត្រូវថយទៅវិញ ដោយត្រូវទ័ពចក្រីឡុង និងទ័ពយួនវាយ ។

**សំណួរ :—** មុនព្រះបាទអង្គចន្ទឡើងគ្រងរាជ្យ អ្នកណាទទួលបន្ទុកខាងកិច្ចការរដ្ឋ ? ព្រះបាទអង្គចន្ទទី ២ ព្រះអង្គទ្រង់បានទទួលព្រះរាជាភិសេកនៅឯណា ? ពេលនោះយួនបានរំលោភយ៉ាងម្ដេចដែរ មកលើខ្មែរ ? នៅឆ្នាំ ១៨១១ ហេតុអ្វីបានជាសៀមមកវាយខ្មែរ? នៅឆ្នាំ ១៨១៣ សៀមយកខេត្តខ្មែរណាខ្លះ ? ដោយសំអាងទៅលើអ្វី ? ចុះយួន ? នៅឆ្នាំ ១៨៣២ ហេតុអ្វីដែរបានជាសៀមមកវាយខ្មែរ ? ចម្បាំងនោះយ៉ាងម្ដេច ?

* * *

# ៣៥– មហាក្សត្រីយានីអង្គមី

## « អាណាព្យាបាលយួន »

សៀមប្រាថ្នាបំបាត់វង្សក្សត្រិយ៍ខ្មែរតាំងពីយូរមកហើយ ឥឡូវយួនប្រាថ្នាបំបាត់វង្សក្សត្រិយ៍ខ្មែរទៀត ។

**យួនចង់យកកម្ពុជា ដោយបំបាត់វង្សក្សត្រខ្មែរ** :– ព្រះបាទអង្គច័ន្ទទី ២ ដែលសុគតទៅ ព្រះអង្គមានតែព្រះរាជបុត្រី ។ យួនមិនព្រមឲ្យថ្វាយរាជ្យដល់ព្រះអង្គអិម ឬ ព្រះអង្គឌួងទេ ដោយសំអាងលេសថា ក្សត្រទាំងពីរអង្គនេះនៅក្រោមឧវាទសៀម ។ ក្នុងរឿងរាជសម្បត្តិ ព្រះចៅអធិរាជយួនបំរុងនឹងលើកព្រះអង្គម្ចាស់ក្សត្រីបែន ដែលជាព្រះរាជបុត្រីច្បងព្រះបាទអង្គចន្ទទី ២ ឲ្យឡើងគ្រងរាជ្យ ហើយអភិសេកជាមួយនឹងព្រះរាជឱរសយួនមួយព្រះអង្គ ។ តែដោយគំនិតនេះមិនស្របនឹងមតិនាម៉ឺនមុខមន្ត្រីខ្មែរទាំងឡាយ យួនក៏ផ្អាករឿងនេះមួយអន្លើ ។

**ព្រះមហាក្សត្រីយានីអង្គមីគ្រងរាជ្យ (១៨៣៤-១៨៤១)** :– ព្រះអង្គម្ចាស់ក្សត្រីបែន ឈឺចាប់នឹងការលោភរបស់យួនណាស់ ។ ព្រះអង្គទ្រង់គៀសព្រះអង្គទៅបាងកក ។ តែដំណើរនេះដឹងដល់យួន យួនក៏ចាប់ព្រះអង្គម្ចាស់បែន ហើយលើកព្រះរាជធីតាទី ២ នៃព្រះបាទអង្គចន្ទទី២ ព្រះនាមអង្គមី ឲ្យគ្រងរាជ្យ ។

ក្នុងរជ្ជកាលព្រះមហាក្សត្រីយានីអង្គម៉ី ខ្មែរគ្មានអំណាចអ្វីទាំងអស់ ។ អំណាចទាំងអស់ នៅក្នុងកណ្ដាប់ដៃយួន ។ យួនដាក់ទ័ពក្នុងកម្ពុជា ហើយ តម្រូវឲ្យខ្មែរបិញ្ចឹមទ័ពនោះទៀត ។ ចៅហ្វាយស្រុកយួនត្រួតត្រាលើចៅហ្វាយស្រុកខ្មែរ ។ មន្ត្រីរាជការត្រូវស្លៀកពាក់តាមរបៀបយួន ។ ខេត្ត ស្រុកខ្លះ បានត្រូវផ្លាស់ឈ្មោះជាភាសាយួន ដូចជា ភ្នំពេញ ហៅជា ណាម យ៉ាង ។ ក្នុងកិច្ចការរដ្ឋ ត្រូវប្រើភាសាយួន ។ យួនខំបំផ្លាញបូជនីយដ្ឋានខាងព្រះពុទ្ធសាសនា មានបំផ្លាញចោលនូវព្រះពុទ្ធរូប កំទេចចេតិយ កាប់ដើមពោធិជាដើម ។

**ផែនការ អុង ទៀង គុន មិនបានសំរេច ( ONG TUONG KUN ):–**

នៅឆ្នាំ ១៨៤១ មេទ័ពយួនម្នាក់ឈ្មោះ អុង ទឿង គុន ធ្វើផែនការមួយ ដើម្បីយកកម្ពុជា ។ អុង ទៀង គុន ប្រឡោមចាប់ព្រះឧបរាជអង្គអិម រដ្ឋមន្ត្រីបីរូប និងព្រះរាជបុត្រីព្រះបាទអង្គចន្ទទី ២ ទាំងអស់ មានទាំង មហាក្សត្រីយានីអង្គម៉ីផង បញ្ជូនទៅស្រុកយួន ហើយធ្វើទារុណកម្ម ។

តែផែនការ អុង ទៀងគុននេះពុំបានសំរេច ។ អំពើយង់ឃ្នងរបស់យួនមកលើព្រះរាជវង្សានុវង្ស បានធ្វើឲ្យខ្មែរឈឺចាប់យ៉ាងខ្លាំង ។ ប្រជារាស្ត្រ ព្រះសង្ឃ នាម៉ឺនមន្ត្រីទាំងអស់ក្ដៅក្រហាយ ។ ខ្មែរទាំងព្រះរាជាណាចក្រនាំគ្នាបះបោរឡើង កាប់សម្លាប់យួនទាំងទាហាន ទាំងស៊ីវិល នៅគ្រប់កន្លែងអស់វេលា៨ថ្ងៃ ។

បន្ទាប់មក នាម៉ឺនមន្ត្រីខ្មែរ ប្រជុំគ្នាដោយស្ងាត់ ហើយព្រមព្រៀងគ្នាថា ត្រូវតែសុំឲ្យសៀមជួយ និងសុំឲ្យព្រះអង្គឌួងមកគ្រងរាជ្យនៅកម្ពុជាវិញ ។

នៅឆ្នាំ ១៨៤១ ដដែលនេះ ឃើញឳកាសល្អ ព្រះចៅសៀមបាន ចាត់ពញាបឌិន ជាមេទ័ពឲ្យដង្ហែរព្រះអង្គឌួងត្រឡប់មកកម្ពុជា ។

ចំណែកឯដំណើរខាតលាភនេះ យួនក៏ធ្វើគតព្រះអង្គម្ចាស់ក្សត្រីបែន ដោយយកព្រះអង្គទៅប្រកក្នុងបង់ ហើយយកទៅទំលាក់ក្នុងទឹកទន្លេឆ្នាំ ១៨៤២ ។ ឯព្រះឧបរាជអង្គអិម ព្រះអង្គក៏សុគតនៅស្រុកយួននៅ ឆ្នាំ ១៨៤៣ ។

—oOo—

សេចក្តីសង្ខេប :— ព្រះអង្គចន្ទទី២ ដែលសុគតទៅ ព្រះអង្គមានតែព្រះរាជបុត្រី ។ យួនមិនព្រមឲ្យថ្វាយរាជ្យទៅព្រះអង្គអិម ឬ ព្រះអង្គឌួងទេ ដោយសំអាងលេសថា ក្សត្រទាំងពីរអង្គនេះ នៅក្រោមឱវាទសៀម ។ ក្នុងរឿងរាជសម្បត្តិ ព្រះអធិរាជយួន បំរុងនឹងលើកព្រះម្ចាស់ក្សត្រីបែន ដែលជាព្រះរាជធីតាទី ១ នៃព្រះបាទអង្គចន្ទឲ្យគ្រងរាជ្យ ហើយអភិសេកជាមួយនឹងព្រះរាជឱរសយួនមួយព្រះអង្គ ។ តែដោយគំនិតនេះពុំស្របនឹងមតិនាម៉ឺនមុខមន្ត្រីខ្មែរទាំងឡាយ យួនក៏ផ្អាករឿងនេះទៅ ។ ឃើញថាព្រះអង្គម្ចាស់មិនចូលចិត្តនឹងយួន យួនក៏លើកព្រះអង្គ ម៉ី ឲ្យគ្រងរាជ្យវិញ ។ នៅក្នុងពេលនោះអំណាចទាំងប៉ុន្មាន នៅក្នុងកណ្តាប់ដៃយួនទាំងអស់ ។ យួនខំបំបាត់របៀបរដ្ឋាភិបាលខ្មែរ ទំនៀមទំលាប់ ភាសា សាសនា ។ បន្ទាប់មក ដើម្បីយកកម្ពុជា យួនបានចាប់ព្រះឧបរាជអង្គអិត ព្រះរាជធីតា

ព្រះបាទអង្គចន្ទទាំងអស់ និងរដ្ឋមន្ត្រីបីនាក់ ។ តែគំនិតនេះមិនសំរេច ។ ខ្មែរទាំងព្រះរាជាណាចក្រឈឺចាប់ នាំគ្នាបះកាប់សម្លាប់យួន ហើយនាំគ្នាទៅសុំព្រះអង្គឌួងពីសៀមមកគ្រងរាជ្យវិញ ។

**សំណួរ:**— បន្ទាប់ពីព្រះបាទអង្គចន្ទ ក្នុងបញ្ហារាជសម្បត្តិ យួនធ្វើយ៉ាងម្ដេច? ហេតុអ្វីបានជាយួនមិនព្រមថ្វាយរាជ្យទៅព្រះអង្គអិម ឬ ព្រះអង្គឌួង? ហេតុអ្វី បានជាព្រះអង្គម្ចាស់ក្សត្រីបែនមិនបានសោយរាជ្យវិញ? ក្នុងរជ្ជកាលព្រះអង្គមី យួនធ្វើអ្វីខ្លះ? ដើម្បីយកកម្ពុជា យួនប្រើឧបាយយ៉ាងម្ដេច? ហេតុម្ដេចបានជាឧបាយយួនមិនបានសំរេច?

*     *

*

# ជំពូកទី៥:- សម័យថ្មី

## ៣៦- ព្រះបាទអង្គឌួង ឬ (ព្រះហរិរក្សរាមា)

(១៨៤៥-១៨៥៩)

**អំពីហេតុដែលនាំឱ្យព្រះអង្គឌួងយាងត្រឡប់មកកាន់ ប្រទេសកម្ពុជាវិញ:-** ដោយនៅក្នុងព្រះនគរ យួនបានធ្វើទុក្ខបុកម្នេញខ្មែរខ្លាំងពេក ប្រជារាស្ត្រខ្មែរ ក៏បានសុំឲ្យព្រះអង្គឌួង ដែលគង់នៅប្រទេសសៀម ស្ដេចយាងមកគ្រប់គ្រងរាជ្យ ជាម្ចាស់ផែនដីវិញ ។ បានឱកាសល្អយ៉ាងនេះសៀមក៏ចាត់ឧត្តមសេនីយម្នាក់ ឈ្មោះ ចៅពញាបឌិន ឲ្យដង្ហែរព្រះអង្គឌួងមកកាន់កម្ពុជា ។ គ្រានោះប្រទេសកម្ពុជាភាគខាងកើត ស្ថិតនៅក្រោមការកាន់កាប់របស់យួន ។ ដើម្បីរៀបចំព្រះនគរឲ្យមានការរៀបរយ ហើយនិងមានឯកភាពឡើងវិញ ព្រះអង្គទ្រង់ត្រូវកំចាត់យួនឲ្យចេញផុតពីដីខ្មែរជាមុន ។

**ចម្បាំងនឹងយួន:-** ចម្បាំងនឹងយួនមានពីរលើក ។ លើកទីមួយ ទ័ពសៀមដែលមានចៅពញាបឌិនជាអ្នកដឹកនាំ បានទប់ទល់នឹងទ័ពយួន ហើយថយដៃព្រោះទ័ពយួនខ្លាំងដាង ។ យួនក៏បានចូលមកកាន់កាប់ក្រុងភ្នំពេញឡើង ។

លើកទីពីរ ទ័ពយួនចង់ចូលទៅវាយលុកក្រុងឧដុង្គទៀត តែម្ដងនេះ ព្រះអង្គឌួង និងចៅពញាបឌិន បានរៀបចំទ័ពទប់ទល់យ៉ាងអង់អាចៗ

ទ័ពយួនប្រយុទ្ធមិនឈ្នះ ក៏បានព្រមទទួលចុះហត្ថលេខាឈប់ច្បាំងរវាងខ្មែរនិងយួននៅឆ្នាំ ១៨៤៦ ។

**ព្រះអង្គឌួងឡើងសោយរាជ្យ ជាព្រះមហាក្សត្រ កម្ពុជាៈ—** *លុះឈប់ច្បាំងនឹងខ្មែរហើយ ទើបយួនទទួលស្គាល់ព្រះអង្គឌួង ជាព្រះមហាក្សត្រពេញទីនៃប្រទេសកម្ពុជា ។ ចំណែកព្រះក្សត្រីអង្គមី និងព្រះញាតិវង្ស ដែលយួនឃាត់ទុកឲ្យគង់ប្រថាប់នៅប្រទេសយួនពេលមុននោះ យួនបានដោះលែងព្រះអង្គឲ្យយាងមកកាន់មាតុប្រទេសវិញ ព្រមទាំងនាំព្រះខ័នមាស និងលំពែងមកប្រគល់ថ្វាយព្រះរាជាខ្មែរវិញផង ។*

*ព្រះអង្គឌួងបានទទួលព្រះរាជប្រាប្តាភិសេកនៅក្រុងឧដុង្គ នៅឆ្នាំ ១៨៤៧ ។*

—oOo—

**សេចក្តីសង្ខេប :—** កាលនោះ យួនបានធ្វើទុក្ខបុកម្នេញខ្មែរខ្លាំងណាស់ ។ ប្រជារាស្ត្រខ្មែរបាននាំគ្នាសុំយាងព្រះអង្គឌួង ពីប្រទេសសៀមមកគ្រប់គ្រងរាជ្យនៅប្រទេសកម្ពុជា ។ មេទ័ពសៀមឈ្មោះ ចៅពញាបឌិន បាននាំព្រះអង្គឌួងមកកាន់ប្រទេសខ្មែរ ។

ព្រះបាទអង្គឌួង និងចៅពញាបឌិនបានធ្វើសង្គ្រាមនឹងយួនពីរលើក ។ លើកទី ១ យួនមានជ័យជំនះ ហើយមកកាន់កាប់ភ្នំពេញ ។ លើកទី ២ យួនវាយមិនឈ្នះទ័ពខ្មែរ និងទ័ពពញាបឌិននៅក្រុងឧដុង្គ ហើយក៏ទទួលឈប់ច្បាំងនឹងខ្មែរទៅ ។

ពីពេលនោះមក យួនទទួលស្គាល់ព្រះអង្គឌួង ជាព្រះមហាក្សត្រខ្មែរពេញទី។ ព្រះអង្គឌួងទទួលប្រាប្តាភិសេកនៅក្រុងឧដុង្គនៅឆ្នាំ ១៨៤៧ ។

**សំណួរ ៖—** ហេតុអ្វីបានជាប្រជារាស្ត្រខ្មែរទៅសុំព្រះអង្គឌួងមកគ្រងរាជ្យវិញ? កាលនោះព្រះអង្គឌួងគង់នៅឯណា? មេទ័ពសៀមដែលហែរព្រះអង្គឌួងមកកាន់ប្រទេសខ្មែរឈ្មោះអ្វី? ព្រះអង្គឌួង និងទៅពញាបឌិនធ្វើសង្គ្រាមនឹងយួនប៉ុន្មានលើក? បានលទ្ធផលយ៉ាងម្តេច? ព្រះអង្គឌួងទ្រង់ទទួលព្រះប្រាព្ធាភិសេកនៅឯណា? នៅឆ្នាំណា?

* * *

## ៣៧–អំពីព្រះរាជនយោបាយក្រៅប្រទេសនៃ «ព្រះបាទអង្គឌួង ក្នុងការរំដោះប្រទេសខ្មែរពីសៀមនិងយួន»

សៀមនិងយួនព្រមព្រៀងគ្នាទទួលស្គាល់ព្រះបាទអង្គឌួង ជាព្រះមហាក្សត្រ នៃប្រទេសកម្ពុជា តែសៀមនិងយួនមិនព្រមប្រគល់ដីទាំងប៉ុន្មានដែលខ្លួនបានកាន់កាប់មកខ្មែរវិញសោះ ។

**សៀមយកដីខ្មែរ :—** សៀមបានសុំព្រះបាទអង្គឌួងសំរេចសន្និសញ្ញាផ្តាច់យកខេត្តមង្គលបុរី និងទន្លេរពៅ ដែលសៀមយកបានកាលពីមុន ។ ព្រះបាទសម្តេចព្រះអង្គឌួងទ្រង់មានព្រះតម្រាស់ថា ៖

"ខ្ញុំមិនឲ្យអ្វីទៅសៀមទាំងអស់ ប៉ុន្តែ សៀមខ្លាំងពូកែ សៀមទុកសិនទៅចុះ ខេត្តណាដែលសៀមយកបានពីមុន ៗ នោះ" ។

នៅក្នុងខេត្តណា ដែលសៀមយកបាន សៀមបានប្រើមធ្យោបាយត្រជាក់ គឺបានបន្ថយពន្ធដារពីប្រជារាស្ត្រ ហើយយកតែកម្រែបន្តិចបន្តួចទៅប្រទេសខ្លួន ។

**យួនយកដីខ្មែរៈ**— យួនប្រើនយោបាយខុសពីសៀម គឺនៅគ្រប់ខេត្តទាំង ប៉ុន្មានដែលវាយកបានពីខ្មែរ យួនប្រើមធ្យោបាយខិតខំបំបាត់ដំណែល ការគ្រួតត្រាចាស់របស់ខ្មែរ ឲ្យសាបសូន្យ ហើយប្រមូលយកយួនមក តាំងនៅជាជំនួសវិញ ។ ខ្មែរខ្លះ មិនអាចទ្រាំបានក្នុងការជិះជាន់របស់ យួន ក៏បានភៀសខ្លួនមកជ្រកនៅប្រទេសកម្ពុជា ។

**អំពីការទាក់ទងនឹងបារាំងសែសៈ**— កាលនោះ នៅប្រទេសយួន មាន បារាំងសែសបានចូលមក ធ្វើអន្តរាគមក្នុងការវិវាទរវាងយួន និងពួកកាតូ-លិក ។ លុះដំណឹងនេះបានឮមកដល់កម្ពុជាហើយ ព្រះបាទអង្គឌួង ទ្រង់សម្រេចព្រះហឫទ័យ នឹងចងស្ពានមេត្រីជាមួយបារាំង ក្នុងព្រះរាជ បំណងរំដោះកម្ពុជា ឲ្យរួចពីកណ្ដាប់ដៃសៀមនិងយួន និងទាមទារខេត្ត របស់ខ្មែរមកវិញ ។ នៅឆ្នាំ ១៨៥៥ ព្រះអង្គបានចាត់ឲ្យបញ្ជូនព្រះ រាជសារលិខិតមួយច្បាប់ទៅថ្វាយព្រះអធិរាជណាប៉ូឡេអុង ទី៣ ( S.M. Napoléon III ) នៃប្រទេសបារាំង ដើម្បីសំដែងព្រះមិត្តភាពរវាងព្រះអង្គ ចំពោះបារាំង ។ បារាំងបានបញ្ជូនលោក ដឺម៉ុងទីញី ឲ្យមកក្រាប បង្គំគាល់ព្រះអង្គ ។ តែដោយលោក ដឺម៉ុងទីញី មានការប្រហែស ប្រាប់សៀមឲ្យដឹងមុន ការក្រាបបង្គំគាល់នោះក៏អាក់ខានទៅវិញ ។ នៅឆ្នាំ ១៨៥៦ ព្រះអង្គទ្រង់ឲ្យបញ្ជូន ព្រះរាជសារលិខិតមួយច្បាប់ទៀត ទៅព្រះចៅណាប៉ូឡេអុង ទី ៣ ។ ក្នុងព្រះរាជសារលិខិតនោះ ព្រះ

អង្គទ្រង់រំឭកពីទឹកដីខ្មែរ ដែលយួនយក និងសូមកុំឲ្យបារាំងទទួលដីទាំងនោះពីយួនឡើយ ។

នៅឆ្នាំ ១៨៥៩ គឺនៅពេលដែលយួនកំពុងបរាជ័យ ក្នុងការទប់ទល់នឹងបារាំង ព្រះអង្គឌួង ព្រះអង្គទ្រង់ចាត់ការវាយយួនតទៅទៀត ។ ព្រះអង្គបានចាត់ឲ្យធ្វើបន្ទាយជាច្រើននៅជិតមាត់ជ្រូកនិងពាម ហើយទ្រង់ចាត់មន្ត្រីម្នាក់ឈ្មោះ កែប ឲ្យធ្វើជាមេទ័ព ។ ជោគជ័យលើកដំបូងបានធ្វើឲ្យព្រះអង្គមានសេចក្ដីសង្ឃឹមច្រើនណាស់ ។ តែដោយនៅឆ្នាំ ១៨៦០ ព្រះអង្គទ្រង់សោយទីវង្គតទៅ មេទ័ពកែប ក៏ត្រឡប់មកកាន់ព្រះរាជធានីឧដុង្គវិញ ។

—oOo—

**សេចក្ដីសង្ខេប** :– សៀម និងយួន យល់ព្រមទទួលស្គាល់ព្រះបាទអង្គឌួង ជាព្រះមហាក្សត្រនៃប្រទេសកម្ពុជា តែសៀមនិងយួនមិនព្រមប្រគល់ដី ដែលខ្លួនកាន់កាប់មកខ្មែរវិញឡើយ ។ សៀមបានសុំយកខេត្តម្លូព្រៃ និងទន្លេរពៅ ។ ដើម្បីកាន់កាប់ដីខ្មែរ សៀមបានប្រើមធ្យោបាយត្រជាក់ ។ ឯយួនវិញប្រើមធ្យោបាយផ្ទុយ គឺខំបំបាត់ដំណែលការគោរពគ្រាចាស់របស់ខ្មែរឲ្យសាបសូន្យ និងប្រមូលយួនឲ្យមកនៅជាជំនួសខេត្តណាដែលខ្មែរទ្រាំនៅមិនបានដោយរាជិះជាន់ខ្លាំងពេក ។

ក្នុងព្រះរាជបំណងរំដោះប្រទេសកម្ពុជាពីសៀម និងយួន ព្រះបាទអង្គឌួងទ្រង់បានបញ្ជូនព្រះសារលិខិតមួយច្បាប់ទៅព្រះចៅណាប៉ូឡេអុង ទី ៣ ដើម្បីទាក់ទងជាមិត្ត

ជាមិត្តភាពជាមួយបារាំងសែស និងក្រោយមក មួយច្បាប់ទៀតដើម្បីសុំកុំឲ្យបារាំងទទួលយកដីខ្មែរ ដែលយួនយកបាន ។ មិនមានដំណឹងពីបារាំង ព្រះអង្គក៏ទ្រង់ឲ្យមេទ័ពកែប រៀបចំការតស៊ូវាយយួនប្រកបដោយជោគជ័យនៅឆ្នាំ ១៨៥៩ ។ មួយឆ្នាំក្រោយមក ព្រះអង្គទ្រង់សោយទីវង្គត ។ មេទ័ពកែបក៏ត្រឡប់មកកាន់ក្រុងឧដុង្គវិញ។

សំណួរៈ– សៀមនិងយួនទទួលស្គាល់ព្រះបាទអង្គឌួងជាព្រះចៅកម្ពុជា សៀមនិងយួនប្រគល់ទឹកដីមកខ្មែរវិញទេ? ដើម្បីយកដីខ្មែរ សៀមប្រើមធ្យោបាយម្ដេច? ឯយួនវិញ គេធ្វើយ៉ាងម្ដេច? ក្នុងព្រះរាជបំណងយកទឹកដីពីសៀមនិងយួន ព្រះអង្គទ្រង់បានធ្វើអ្វី? ក្នុងព្រះសារលិខិតទីមួយដែលព្រះអង្គផ្ញើទៅព្រះចៅណាប៉ូឡេអុង ទី ៣ ព្រះអង្គទ្រង់ថ្លែងពីអ្វី? ចុះក្នុងព្រះសារលិខិតទី ២ ? ខាងផ្លូវសឹកព្រះអង្គបានធ្វើអ្វី ? ហើយបានលទ្ធផលយ៉ាងណា?

* * *

## ៣៨– ការរៀបចំប្រទេសក្នុងរាជ្យព្រះបាទអង្គឌួង

*ព្រះបាទអង្គឌួង ជាម្ចាស់ផែនដី ឈ្លាសវៃ ហើយប្រកបដោយទសពិធរាជធម៌ណាស់ ។ ព្រះអង្គបានរៀបចំរបៀបគ្រប់គ្រងប្រទេសឲ្យមានដំណើរល្អ និងទំនុកបំរុងការរៀនសូត្រនៃក្មេង ៗ ខ្មែរឲ្យបានល្អតលាស់ល្អប្រពៃ ។*

**ការទំនុកបំរុងវត្ត និង ព្រះពុទ្ធសាសនា** : – *ព្រះអង្គបានសាងវត្ត វិហារជាច្រើននៅឧត្តុង្គ តាំងអាចារ្យប្រដៅបរិយត្តិធម៌ បង្រៀនព្រះត្រៃបិដក។*

ទ្រង់ឲ្យសាងសាលាទានសំរាប់ធ្វើសង្ឃទាន និងធ្វើទានដល់បណ្ដាជនក្រីក្រលំបាកកំសត់អត់ឃ្លាន ។

**ការរៀបចំរបៀបគ្រប់គ្រងប្រទេស :–** ព្រះអង្គមានព្រះបញ្ជាឲ្យអ្នកចេះដឹងជ្រៅជ្រះ ផ្ទៀងច្បាប់ កែច្បាប់ តែងច្បាប់សម្រាប់ប្រើក្នុងប្រទេសតម្រូវតាមសម័យ ។ ឲ្យជ្រើសតាំងជានាម៉ឺនមន្ត្រីតែអ្នកមានចំណេះវិជ្ជាជ្រៅជ្រះពិតប្រាកដ ។ ទ្រង់ព្រះរាជបញ្ញត្តិ ដាក់ទណ្ឌកម្មយ៉ាងធ្ងន់ដល់នាម៉ឺនដក់អាកៀន និងនាម៉ឺនទុច្ចរិតទទួលសំណូក មិនឲ្យយកពន្ធដារពីរាស្ត្រ និងមិនឲ្យយកការប្រាក់ធ្ងន់ទេ ។ បានត្រាស់បង្គាប់ឲ្យធ្វើពុម្ពបោះប្រាក់ជាពងសំប៉ែត មានត្រាប្រាសាទម្ខាង រូបសត្វរាជហង្សម្ខាង ។ ទ្រង់បានសាងផ្លូវមួយពីឧដុង្គទៅកំពត យកកំពតជាកំពង់សមុទ្រ ហើយសាងសំពៅមួយសំរាប់ផ្ទុកទំនិញទៅសិង្គបូរី ។

**ការទំនុកបំរុងការរៀនសូត្រ :–** ទ្រង់បានព្រះរាជបញ្ញាឲ្យក្មេងចូលរៀនបានច្រើននៅវត្ត ហើយបានបំណាយព្រះរាជទ្រព្យ ចាត់កូនខ្មែរឲ្យទៅរៀនភាសាបារាំងសែសឯសិង្គបូរ សំរាប់ប្រើការក្នុងរាជការ ។

—oOo—

**សេចក្ដីសង្ខេប:–** ព្រះបាទអង្គឌួង ជាអម្ចាស់ផែនដីឈ្លាសវៃ ហើយប្រកបដោយទសពិធរាជធម៌ណាស់ ។ ព្រះអង្គទ្រង់បានរៀបចំរបៀបគ្រប់គ្រងប្រទេសឲ្យមានដំណើរល្អ ទំនុកបំរុងក្មេងៗខ្មែរ ឲ្យរៀនសូត្របានល្អណាស់ ។

ព្រះអង្គបានសាងវត្តវិហារជាច្រើននៅឧដុង្គ សង់សាលាទាន សាលាសំណាក់ និងធ្វើទានដល់ប្រជាពស្ត្រក្រីក្រលំបាកអត់ឃ្លាន ។ ព្រះអង្គបានបញ្ជាឲ្យអ្នកចេះដឹងជ្រៅជ្រះ ផ្ទៀងច្បាប់ កែងច្បាប់ និងធ្វើច្បាប់ ។ ទ្រង់ឲ្យធ្វើទណ្ឌកម្មដល់នាម៉ឺនជក់អាភៀន និងទទួលសំណូក មិនឲ្យយកពន្ធដារពីពស្ត្រ និងមិនឲ្យយកការប្រាក់ធ្ងន់ផង ។ ទ្រង់បញ្ជាឲ្យបោះប្រាក់សម្រាប់ចាយ ឲ្យសាងផ្លូវពីឧដុង្គទៅកំពត យកកំពតជាកំពង់សមុទ្ទ ចំណាយព្រះរាជទ្រព្យ ដើម្បីបញ្ជូនកូនខ្មែរឲ្យទៅរៀនភាសាបារាំងឯសឹង្គបុរ សម្រាប់ប្រើក្នុងការរាជការ ។

**សំណួរៈ**– ក្នុងរាជ្យព្រះបាទអង្គឌួង ប្រទេសមានដំណើរយ៉ាងដូចម្ដេច? ក្នុងការអប់រំជាតិព្រះអង្គទ្រង់បានធ្វើអ្វី? ព្រះអង្គទ្រង់បានសាងវិហារច្រើននៅឯណា? ព្រះអង្គបានសាងអ្វីទៀតដែលជាអំពើកុសល? ហេតុអ្វីបានជាព្រះអង្គឌួង ឲ្យកែប្រែច្បាប់ និងធ្វើច្បាប់? មនុស្សអាក្រក់បែបណា ដែលព្រះអង្គមិនសព្វព្រះហឫទ័យ? ខាងហិរញ្ញវត្ថុព្រះអង្គបានធ្វើអ្វី? ផ្លូវណាខ្លះ ដែលព្រះអង្គបានសាង? ហេតុអ្វីបានជាព្រះអង្គសាងផ្លូវទៅកំពត? ក្នុងរាជ្យព្រះអង្គ មានបញ្ជូននិស្សិតទៅប្រទេសក្រៅទេ? ដើម្បីរៀនអ្វី?

* * *

## ៣៩–ព្រះបាទនរោត្តម
### «អាណាព្យាបាលបារាំង»

**ព្រះបាទនរោត្តម (១៨៥៩-១៩០៤) និង ព្រះបាអង្គស៊ីវត្ថា**:– *ព្រះបាទអង្គឌួង ព្រះអង្គមានព្រះរាជបុត្របីអង្គ គឺព្រះអង្គរាជ្យ ព្រះស៊ីសុវត្ថិ និងព្រះស៊ីវត្ថា ។ នៅឆ្នាំ ១៨៥៩ លុះព្រះអង្គឌួងសុគតទៅ ព្រះអង្គរាជ្យទ្រង់*

ឡើងគ្រងរាជ្យ ហើយទ្រង់ព្រះនាមថាព្រះបាទនរោត្តម ។ កាលនោះ ព្រះអង្គស៊ីវត្ថា ព្រះអនុជព្រះអង្គ ទ្រង់មានសេចក្តីប្រណែននឹងព្រះរាជា ក្នុងរឿងរាជបល្ល័ង្ក ។ នៅឆ្នាំ ១៨៦១ ព្រះស៊ីវត្ថាបានបង្ករទ័ពច្បាំងនឹងព្រះរាជា ដោយយកស្រុកស្រុក និងមនោកែវជាមេទ័ព ។ មួយឆ្នាំបន្ទាប់មក ដោយមានជំនួយពីសៀមផង ព្រះរាជាក៏បង្ក្រាបការបះបោរនោះឲ្យស្ងប់រំងាប់ទៅវិញ ។

**សន្ធិសញ្ញា ១៨៦៣:–** បារាំង ក្រោយពីយកកូសាំងស៊ីនបាន មានការចាប់អារម្មណ៍មកលើកម្ពុជាទៀត ។ នៅឆ្នាំ ១៨៦៣ ឧត្តមនាវី ដឺឡាក្រ្គង់ឌីយែរ បានមកស្នើរឿងសន្ធិសញ្ញា ដែលព្រះអង្គទទួលតាំងពាស់ព្រះទ័យ ។ ដើម្បីរកមធ្យោបាយកុំឲ្យសន្ធិសញ្ញានេះបានសម្រេច ព្រះអង្គបានល្បងទាក់ទងនឹងសៀម ក្រោយមកទៀត ជាមួយនឹងអេស្ប៉ាញ៉ុល តែពុំបានសម្រេចដូចព្រះរាជបំណង ។

បន្ទាប់ពីសន្ធិសញ្ញានោះមក បារាំងបានរៀបព្រះរាជាភិសេកថ្វាយព្រះបាទនរោត្តមជាថ្មី ។ សៀមដែលមាននៅក្នុងកម្ពុជា ត្រូវទៅកាន់ប្រទេសខ្លួនវិញ ។ ព្រះរាជាព្រះអង្គទ្រង់ផ្លាស់ព្រះរាជធានីពីឧដុង្គមកភ្នំពេញវិញ ។ ក្នុងរវាងឆ្នាំ ១៨៦៥ ដល់ឆ្នាំ ១៨៦៧ មានការបះបោរពីក្រុមដឹកនាំដោយអាចារ្យស្វា និងពោរកំបោរ ។ តែការបះបោរនោះបានត្រូវបង្ក្រាបអស់ទៅវិញ ។

**សន្ធិសញ្ញា ១៨៨៤** :– សន្ធិសញ្ញា ១៨៦៣ មានការសមរម្យខ្លះ បំពោះព្រះរាជា និងរាស្ត្រខ្មែរទាំងអស់ ។ សន្ធិសញ្ញា ១៨៨៤ ជាទឹមពិតៗ មកលើកម្ពុជា ។ ទាំងព្រះរាជា ទាំងរាស្ត្រ គ្មានអំណាចអ្វីទាំងអស់ៗ ដើម្បីបង្ខំ ឲ្យព្រះរាជាឡាយព្រះហស្តលេខាលើសន្ធិសញ្ញានោះ បារាំងបានធ្វើការរំលោភយ៉ាងខ្លាំងទៅលើព្រះអង្គ ។ បន្ទាប់ពីសន្ធិសញ្ញា ១៨៨៤ នោះមក នៅប្រទេសមានការបះបោរ ដែលបារាំងដឹងថា ជាស្នាព្រហស្តព្រះរាជា តែរកចាប់ភស្តុតាងមិនបាន ។ លោករ៉េស៊ីដង់ស៊ុប៉េរីយ៉េរ ទៅជាសត្រូវនឹងព្រះមហាក្សត្រ ។ ព្រះមហាក្សត្រព្រះអង្គមានព្រះទ័យឈឺចាប់យ៉ាងខ្លាំង ។

**សន្ធិសញ្ញា ១៨៩៧**:– ដើម្បីដកហូតជាបង្ហើយ នូវអំណាចពីព្រះមហាក្សត្រ ដែលមាននៅសេសសល់បន្តិចបន្តួច បារាំងបានតម្រូវឲ្យព្រះរាជាឡាយព្រះហស្តលេខាលើសន្ធិសញ្ញាមួយទៀត គឺសន្ធិសញ្ញា ១៨៩៧ ។

**ស្នាព្រះហស្ត** – ព្រះបាទនរោត្តម ព្រះអង្គទ្រង់មានព្រះទ័យប្រឆាំងនឹងអាណានិគមបារាំងជានិច្ច ជាពិសេសប្រឆាំងនឹងសន្ធិសញ្ញា ១៨៨៤ៗ ព្រះអង្គតែងទាមទារឥតឈប់ឈរនូវដីកម្ពុជាក្រោម ។ ព្រះអង្គបានឲ្យរំលាយនូវ „វណ្ណៈ” ខ្ញុំគេ ។ ក្នុងកិច្ចការរដ្ឋ ព្រះអង្គបានបន្តរៀបចំការរដ្ឋបាលខេត្ត ដែលបានចាប់ផ្តើមក្នុងរជ្ជកាលព្រះបាទអង្គឌួង ។ ព្រះអង្គបានផ្លាស់ព្រះរាជធានី ពីឧដុង្គមកភ្នំពេញ ព្រះអង្គបានសាងព្រះ

វិហារព្រះកែវមរកត និង ព្រះបរមរាជវាំង ។ ព្រះអង្គទ្រង់ឈ្វេងយល់ច្បាស់នូវសារសំខាន់នៃពិពណ៌ផ្សេងៗ ។ ព្រះអង្គបានបញ្ជូនផលិតផលខាងជំនាងទៅតាំងនៅព្រៃនគរ នៅឆ្នាំ ១៨៦៦ ទៅតាំងនៅប៉ារីស នៅឆ្នាំ ១៨៦៨ ។ ព្រះអង្គទ្រង់ព្រះរាជបញ្ជាឲ្យល្បងដាំដំណាំសំខាន់ ៗ ដូចជាក្រវាញ កាំងគីណា កាហ្វេ ។ល។ នៅលើភ្នំខាងពោធិសាត់ ។

—oOo—

**សេចក្ដីសង្ខេបៈ**— នៅឆ្នាំ ១៨៥៩ កាលព្រះបាទអង្គឌួងសុគតទៅ ព្រះរាជបុត្រព្រះអង្គឡើងគ្រងរាជ្យ ហើយទ្រង់ព្រះនាម ព្រះបាទនរោត្តម ។ កាលនោះព្រះស៊ីវត្ថា ព្រះអនុជព្រះអង្គ បានបះបោរប្រឆាំងនឹងព្រះរាជា ។ តែដោយបានជំនួយពីសៀមផង ការបះបោរនោះក៏បានបង្ក្រាបស្ងប់ទៅវិញ ។ បារាំងបានបង្ខំព្រះអង្គ ឲ្យឡាយព្រះហស្តលេខាលើសន្ធិសញ្ញាបី ។ សន្ធិសញ្ញា ១៨៦៣ មានការសមរម្យខ្លះមកលើកម្ពុជាទាំងមូល ។ សន្ធិសញ្ញា ១៨៨៤ ជាទឹមពិត ៗ ជាក់មកលើកម្ពុជា ។ ឯសន្ធិសញ្ញា ១៨៩៧ បានដកហូតជាបង្គើយពីព្រះមហាក្សត្រ នូវសិទ្ធិអំណាចដែលសេសសល់បន្តិចបន្តួច ។

ព្រះបាទនរោត្តម ព្រះអង្គបានផ្លាស់ព្រះរាជធានីមកនៅភ្នំពេញ ព្រមទាំងសាងវិហារព្រះកែវមរកត និងព្រះបរមរាជវាំង ។ ព្រះអង្គទ្រង់បានបញ្ជូនផលិតផលជំនាង ទៅតាំងនៅបរទេស ។ ព្រះអង្គបានឲ្យល្បងគំរោងការដាំដំណាំនៅលើភ្នំខាងពោធិសាត់ ។

**សំណួរៈ**— នៅខាងដើមរជ្ជកាលព្រះអង្គ ហេតុអ្វីបានជាមានការបះបោរ? សន្ធិសញ្ញារវាងខ្មែរបារាំងទាំងបី ព្រះរាជាសព្វព្រះហឫទ័យនឹងឡាយព្រះហស្តលេខាទេ? សន្ធិសញ្ញាទាំងនោះបានសម្រេចឡើងដូចម្ដេច ? ចំពោះខ្មែរ សន្ធិសញ្ញានោះយ៉ាងម្ដេចដែរ ? ចូរនិយាយពីស្នាព្រះហស្តព្រះអង្គ ?

# ៥០–ព្រះបាទសម្តេចព្រះស៊ីសុវត្ថិនិងព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស

## «កម្ពុជាក្រោមអាណាព្យាបាលបារាំង»

ងរជ្ជកាលព្រះបាទស៊ីសុវត្ថិ ( ១៩០៥-១៩២៧ ) :— ព្រះបាទនរោត្តមសុគតទៅ ព្រះអនុជព្រះអង្គ ព្រះនាមស៊ីសុវត្ថិ ទ្រង់ឡើងគ្រងរាជ្យក្នុងព្រះជន្ម ៦៤ ព្រះវស្សា ។ ព្រះបាទស៊ីសុវត្ថិ ជាព្រះរាជាមួយអង្គ ប្រកបដោយព្រះហឫទ័យសប្បុរសល្អជាទីបំផុត ។ ព្រះអង្គតែងតែជាទីសក្ការៈរបស់ប្រជារាស្ត្ររបស់ព្រះអង្គ ហើយព្រះអង្គមាន ព្រះមនោសញ្ចេតនាប្រជាធិបតេយ្យ ដោយសុទ្ធចិត្ត គឺព្រះអង្គទ្រង់លុបចោលនូវអំពើទារុណកម្មលើរូបកាយ និងបោះបង់ចោលនូវរបបខ្ទះ ដែលទាក់ទងនឹងព្រះមហាក្សត្រ ។ ព្រះអង្គទ្រង់សម្រួលឲ្យអាណាប្រជារាស្ត្រខ្មែរអាចមានដីភូមិឬមានដីស្រែផ្ទាល់ខ្លួន ។ ព្រះអង្គមានព្រះហឫទ័យចង់ឲ្យតែប្រជារាស្ត្រព្រះអង្គរស់នៅក្នុងសន្តិភាព រៀនសូត្រ និងប្រកបដោយវិបុលភាព សុភមង្គលគ្រប់ប្រការ ។

ខ្មែរបានត្រឡប់មកខ្មែរវិញ :— ដោយសារអន្តរាគមបារាំង នៅឆ្នាំ១៩០៤ សៀមបានប្រគល់ខេត្តស្ទឹងត្រែង មូលព្រៃ និងទន្លេរពៅ ហើយនៅឆ្នាំ ១៩០៦ សៀមបានប្រគល់មកទៀតនូវខេត្តបាត់ដំបងនិងសៀមរាប ។ សៀមយកបានខេត្តសុរិន្ទ្រ បុរីរម និងគូខាន់ ។

**ក្នុងសង្គ្រាមលោកលើកទី១** (១៩១៤-១៩១៨) :— ព្រះបាទស៊ីសុវត្ថិក្នុងសង្គ្រាមលោកលើកទីមួយ ព្រះអង្គទ្រង់អនុញ្ញាតបើកឲ្យខ្មែរស្ម័គ្រចិត្តទៅធ្វើទាហានជួយច្បាំងបារាំង ។ ជាអនុស្សាវរីយ៍នៃព្រឹត្តិការណ៍នេះ គេបានសាងចេតិយមួយពីសំរិទ្ធនៅភ្នំពេញ ។

**ក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិមុនីវង្ស** (១៩២៧-១៩៤១) :— ព្រះបាទស៊ីសុវត្ថិសុគតទៅ ព្រះរាជបុត្រព្រះអង្គព្រះនាម ស៊ីសុវត្ថិ-មុនីវង្សទ្រង់ឡើងគ្រងរាជ្យ ព្រះអង្គមានឋានន្តរសក្តិជាវរសេនីយត្រីក្នុងកងទ័ពបារាំង ។ ព្រះអង្គជាព្រះមហាក្សត្រ មានព្រះហឫទ័យទុកដាក់នឹងវិន័យព្រះសង្ឃ តាំងការសិក្សានិងវប្បធម៌ ។ ព្រះរាជលក្ខណៈប្រជាធិបតេយ្យ របស់ព្រះអង្គ បានធ្វើឲ្យប្រជារាស្ត្រគួបគាប់ស្គាល់ព្រះអង្គ និងហ៊ានចូលគាល់ព្រះអង្គ ។

**សៀមយកបាត់ដំបង និងសៀមរាប**:— ក្នុងសង្គ្រាមលោកលើកទី ២ សៀមបានធ្វើអំពើឈ្លានពានមកលើខ្មែរ ។ ទ័ពបារាំងនិងខ្មែរបានធ្វើចម្បាំងទល់នឹងសៀម ។ តែនៅទីបំផុតសៀមយកដីបាត់ដំបងនិងសៀមរាបទៅវិញ ។

**កម្ពុជានៅក្រោមអាណាព្យាបាលបារាំង** :— តាំងពីឆ្នាំ ១៨៦៣ ជិតមួយសតវត្ស កម្ពុជានៅក្រោមអំណាចបារាំង ។ ក្នុងពេលនោះ កិច្ចការក្រៅប្រទេស គឺនយោបាយក្រៅប្រទេស និងការទាក់ទងនឹងបរទេស

ទូទៅ ស្ថិតនៅក្នុងកណ្ដាប់ដៃបារាំងទាំងអស់ ។ ក្នុងប្រទេស កិច្ចការរដ្ឋាភិបាល នៅក្នុងកណ្ដាប់ដៃបារាំងទាំងអស់ដែរ ។ មន្ត្រីខ្មែរទាំងឡាយ នៅក្រោមអំណាចមន្ត្រីបារាំង ។ មន្ត្រីបារាំងដែលធំជាងគេនៅកម្ពុជា គឺលោក រ៉េ.ស៊ីដង់ ស៊ុប៉េរីយ៉េរ (Résident Supérieur) ដែលមាន "ប៊ុយរ៉ូ" នៅភ្នំពេញ ។ នៅតាមខេត្ត មានរ៉េស៊ីដង់ម្នាក់ធ្វើការជាប់នឹងចៅហ្វាយខេត្តខ្មែរ ។ អំណាចទាហានបារាំងកាន់កាប់ ។ មេទាហានទាំងឡាយសុទ្ធតែបារាំង ។ ក្នុងកងទ័ព ខ្មែរមានមុខងារយ៉ាងធំណាស់ ជានាយទាហានរង ។ ខាងសេដ្ឋកិច្ច កសិកម្មជាផលិតកម្មសំខាន់ ។ ចំការកៅស៊ូមានខ្លះ តែជារបស់បារាំង ។ ខាងឧស្សាហកម្ម គេឃើញមានកម្មន្តសាលធ្វើបារី ម៉ាស៊ីនកិនស្រូវខ្លះ និងសុរាគារច្រើន ។ ក្នុងប្រទេស មានផ្លូវថ្នល់ទៅកាន់ខេត្តនានា ។ ផ្លូវរថភ្លើង មានមួយខ្សែពីភ្នំពេញ ទៅបាត់ដំបង ។ ភ្នំពេញជាកំពង់ផែតែមួយរបស់ខ្មែរ ។ សុខាភិបាលស្ដួចស្ដើងណាស់ ។ សម្រាប់ប្រជាជនប្រហែល ៤០០០០០០នាក់ មានវេជ្ជបណ្ឌិត បួនដប់នាក់ ។ ខាងការអប់រំ ក៏មានការទន់ខ្សោយ ។ សាលាធំ ៗ គឺវិទ្យាល័យមួយ សាលាបាលីជាន់ខ្ពស់មួយ សាលាច្បាប់មួយ សាលារចនាមួយ ។ វប្បធម៌បារាំងបានផ្សព្វផ្សាយនៅតាមគ្រប់សាលា ។ ឯវប្បធម៌ខ្មែរ ទៅជ្រកកោនតែនៅតាមវត្តអារាម ។

**សេចក្ដីសង្ខេប** :– ក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ ដោយសារអនុសញ្ញាបារាំងនៅឆ្នាំ១៩០៤ សៀមបានប្រគល់ដីស្ទឹងត្រែង មលូព្រៃ និងទន្លេរពៅ មកខ្មែរ ហើយនៅឆ្នាំ១៩០៦ សៀមបានប្រគល់បាត់ដំបងនិងសៀមរាបមកទៀត ។ ក្នុងសង្គ្រាមលោកលើកទី ១ ព្រះបាទស៊ីសុវត្ថិបានអនុញ្ញាតបើកឲ្យខ្មែរស្ម័គ្រចិត្តធ្វើទាហាន ទៅជួយច្បាំងបារាំង ។

ក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិមុនីវង្ស ក្នុងសង្គ្រាមលោកលើកទី ២ សៀមបានឈ្លានពានយកដីបាត់ដំបង និងសៀមរាបទៅវិញ ។

ក្រោមអាណាព្យាបាលបារាំង ជិតមួយសតវត្ស កិច្ចការទាក់ទងនឹងបរទេសទាំងឡាយ កិច្ចការរដ្ឋាភិបាល អំណាចទាហាន ស្ថិតនៅក្នុងកណ្ដាប់ដៃបារាំងអស់ ។ ខាងសេដ្ឋកិច្ចផ្នែកកសិកម្ម មានស្រូវជាផលិតកម្មធំ ឧស្សាហកម្ម មានបន្តិចបន្តួច ផ្លូវថ្នល់មានមធ្យមសម្រាប់ទៅកាន់ស្រុកទានា កំពង់ផែជំនួញ មានតែមួយ គឺភ្នំពេញ ។ ខាងសង្គមកិច្ច ផ្នែកសុខាភិបាល មិនមានគ្រប់គ្រាន់ ផ្នែកការអប់រំក៏ដូចគ្នាដែរ ។

**សំណួរ**:– ក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិសៀមបានប្រគល់ខេត្តណាខ្លះមកយើងវិញ?ខ្មែរទៅច្បាំងបារាំង ក្នុងសង្គ្រាមអ្វី? ក្នុងរជ្ជកាលព្រះរាជាអង្គណា សៀមយកបាត់ដំបង និងសៀមរាបទៅវិញ? ក្រោមអាណាព្យាបាលបារាំង កិច្ចការរដ្ឋយ៉ាងម្ដេចដែរ? សេដ្ឋកិច្ចមានដំណើរយ៉ាងម្ដេចដែរ? ចូរអធិប្បាយ ។ ចុះក្នុងសង្គមកិច្ច ។

* ចប់ *

*

បើអស់លោកត្រូវការផារសៀវភៅ **ប្រវត្តិសាស្ត្រ** នៃ **ប្រទេសកម្ពុជា** នេះ សូមទាក់ទងនិង :

**រោងពុម្ព វិចិត្រ**

លេខ ៣៧ A វិថីសម្តេចអៀម